ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ខ្ញុំយល់ថា  យើងទាំងអស់គ្នាមិនបានរៀនសូត្រពីការរំលោភបំពាន

◆ ៤០ឆ្នាំបន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ  តើកម្ពុជាបានដោះស្រាយ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៦  ខែមិថុនា  ឆ្នាំ២០១៥

ស្វែងរកការពិត

លេខ១៨៦ ខែមិថុនា ឆ្នាំ២០១៥

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ខ្ញុំយល់ថា យើងទាំងអស់គ្នាមិនបានរៀនសូត្រ.......១

### ផ្នែកឯកសារ

◆ ចម្លើយសារភាពរបស់ សាម ចន .......៣

◆ ចាប ហឿន និងផែនការបោសសម្អាត.......៩

◆ យុវជនយុវនារីបដិវត្តន៍យើងយកចិត្តទុកដាក់ .......១៤

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ ប្រវត្តិ និងសកម្មភាពសង្ខេបរបស់ សោ ភីម .......២១

◆ អ៊ូ សូធីម : យុវជនក្នុងរបបខ្មែរក្រហម.......២៤

◆ ជីវិតឪពុកខ្ញុំ ក្នុងរបបអង្គការខោអាវខ្មៅ.......២៦

◆ ជាភ័ព្វសំណាងរបស់ខ្ញុំឬ? .......៣២

◆ ម៉ៅ វ៉ាន់ អតីតកងអនុរាគមន៍ ចាប់ទូកនេសាទ .......៣៦

◆ ចាប់ពីរបបខ្មែរក្រហមដល់ទប្បត្តិហេតុ ហាំបាលី .......៣៩

### ផ្នែកច្បាប់

◆ សវនាការភ័ស្តុតាងស្តីពីការផ្តល់សក្ខីកម្មរបស់.......៤៨

### វេទិកាពិភាក្សាសាធារណៈ

◆ ៤០ឆ្នាំបន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ.......៥១

### ទំព័រស្រាវជ្រាវរកក្រួសារ

◆ រសាត់តាមខ្យល់.......៥៤

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ.......៥៨



សិស្សឡើងអានអក្សរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៨

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** សូ ហ្វារីណា, ឡុង ដានី, ស៊ាង ចិន្តា, ដួត រិទ្ធី, អេង កុកថាយ, ជី ទេរិទ្ធិ, គ្រី ស៊ុយហ៊ាង, ប៉ុក ប៉ុនសូម៉ាជ, ជា សីហា **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុន្និន្ទ និង ឌី សុជាតា **អ្នកបកប្រែ :** សុភ័ក្ត្រ ភាណា និង សាយ សូលីដា **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ :** ឆេង រ៉េង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com

# ខ្ញុំយល់ថា យើងទាំងអស់គ្នាមិនបានរៀនសូត្រ ពីការរំលោភបំពានផ្លូវភេទជំនាន់អ៊ុនតាក់នៅឡើយ

*ថ្មីៗនេះអ្នកយកព័ត៌មានការសែតភ្នំពេញប៉ុស្តិ៍ បឺណេត មូរ៉េយ បានសម្ភាសន៍ជាមួយអ្នកស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជា កញ្ញា សូ ហ្វារីណា ទាក់ទងនឹងភាពស្រដៀងគ្នារវាងការបំពានផ្លូវភេទរបស់កងរក្សាសន្តិភាពអង្គការសហប្រជាជាតិនាពេលបច្ចុប្បន្ន និងកាលពីអតីតកាល ។*

***តើមានកិច្ចខិតខំប្រឹងប្រែងច្រើនក្នុងការដោះស្រាយនូវឥរិយាបថបំពានផ្លូវភេទតាំងពីជំនាន់អ៊ុនតាក់ឬទេ?***

ខ្ញុំមិនគិតថា យើងរៀនសូត្រច្រើនពីជំនាន់អ៊ុនតាក់ទេ ហើយយើងត្រូវតែរង់ចាំមើលថាតើអ្វីដែលកំពុងកើតឡើងនៅប្រទេសហៃទីឬ សាធារណៈកុងហ្គោ ជាបញ្ហាថ្មី ឬថាតើវាជាបញ្ហាចាស់ដែលស្រដៀងនឹងជំនាន់អ៊ុនតាក់ កើតឡើងក្នុងបរិបទផ្សេងគ្នាឬយ៉ាងណា ។ ដូច្នេះយើងប្រហែលជាអាចប្រើប្រាស់មេរៀនដែលយើងទទួលបានពីអ៊ុនតាក់ដើម្បីដោះស្រាយនូវបញ្ហានេះ ។



ប្រជាជនក្នុងប្រទេសក្រោយជម្លោះរំពឹងថាកងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិមកជួយខ្លួន ដើម្បីដោះស្រាយនូវបញ្ហា ក៏ប៉ុន្តែនៅពេលនោះបែរជាមានកងរក្សាសន្តិភាពជាច្រើនបានប្រព្រឹត្តនូវបទឧក្រិដ្ឋ និងការរំលោភបំពានទៅវិញ ។ អ្វីៗត្រូវក្រឡាប់ចាក់ ដោយសារតែត្រឡប់ពីអ្នកជួយសង្គ្រោះទៅជាអ្នកបង្កបញ្ហា ។

***តើមានមូលហេតុដូចគ្នាច្រើនទេរវាងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងការរាយការណ៍ថ្មីៗនេះអំពីប្រទេសដទៃទៀត?***

ក្នុងករណីប្រទេសហៃទី កងរក្សាសន្តិភាពមួយចំនួនបានធ្វើការដោះដូរអាហារ និងថ្នាំសង្កូវជាមួយនឹងការរួមភេទ ហើយនេះជារឿងរ៉ាវដ៏គួរឲ្យភ័យខ្លាច ។ វាមានលក្ខណៈខុសគ្នាបន្តិចបន្តួចជាមួយនឹងករណីរបស់ប្រទេសកម្ពុជា ។ ក៏ប៉ុន្តែនាងខ្ញុំមិនអាចប្រាប់បានទេថា វាធ្ងន់ធ្ងរជាងមុនឬយ៉ាងណាទេ ។ តាមរយៈការអង្កេតរបស់នាងខ្ញុំ ទង្វើរបស់កងសន្តិសុខហាក់ដូចជាការជំរុញឲ្យមានពេស្យាចារ និងការជួញដូរផ្លូវភេទច្រើនជាងនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែដោយសារមានការផ្សព្វផ្សាយអំពីពេស្យាចារ រួមផ្សំនឹងការខ្វះខាតមធ្យោបាយចិញ្ចឹមជីវិត និងការយល់ដឹងធ្វើឲ្យយើងមិនបានយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា និងចូលរួមទប់ស្កាត់ឲ្យបានទាន់ពេលវេលា ។

***តើអាចមានមូលហេតុដូចគ្នាក្នុងករណីបំពានផ្លូវភេទក្នុងសម័យអ៊ុនតាក់ ទៅនឹងអ្វីដែលកើតឡើងនាពេលបច្ចុប្បន្នដែរទេ?***

ក្នុងអំឡុងសម័យអ៊ុនតាក់ (យ៉ាសូស៊ិ អាកាស៊ិ) គិតថា អំពើទាំងនោះគ្រាន់ជាតម្រូវការរបស់បុរស គឺបុរសត្រូវការរួមភេទ



កុមារកំព្រា ដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ នៅខេត្តសៀមរាប ។ កុមារទាំងនេះមានភារកិច្ចមើលប្អូនតូចៗរបស់ខ្លួន ដោយសារតែឪពុកម្តាយរបស់ពួកគេបានស្លាប់ក្នុងរបបខ្មែរក្រហម

ហើយករណីដូចគ្នានេះក៏បានកើតឡើងនៅប្រទេសដទៃទៀតដែរ ។ ជាលទ្ធផល ស្ត្រី និងក្មេងស្រីក្លាយជាជនរងគ្រោះ ។ ហេតុដូច្នេះ ដើម្បីដោះស្រាយបញ្ហាទាំងនេះ យើងត្រូវពិចារណាសាជាថ្មីថា តើវាជាតម្រូវការស្របច្បាប់របស់មនុស្សប្រុស ឬជាការបំពាន ។

***តើបទពិសោធន៍នៅប្រទេសកម្ពុជាអាចយកទៅប្រើប្រាស់នៅក្នុងប្រទេសផ្សេងទៀតនាពេលបច្ចុប្បន្ន ដែលកងរក្សាសន្តិភាពកំពុងធ្វើប្រតិបត្តិការបានដែរឬទេ?***

នៅក្នុងប្រទេសកម្ពុជា យើងធ្លាក់ទៅក្នុងភាពក្រីក្រនៅក្រោយពេលសង្គ្រាម ហើយប្រទេសនេះ ក៏នៅតែបន្តនូវជម្លោះ ។ ដោយហេតុតែយើងស្ថិតនៅក្នុងភាពស្រេកឃ្លានខាងសេដ្ឋកិច្ចទើបយើងមិនបានគិតថា វាជាការរំលោភបំពាន ឬប្រភេទបទល្មើសណាមួយនោះទេ ។ ទាំងអស់នេះគឺជាមូលហេតុដែលបង្កទៅជាបញ្ហានាពេលបច្ចុប្បន្ន ។ យើងត្រូវការកំណត់សាជាថ្មីថា តើការរំលោភបំពានជាអ្វី? មិនត្រឹមតែប្រជាជនក្នុងប្រទេស ឬតំបន់ប៉ុណ្ណោះទេ គឺទាំងកងរក្សាសន្តិភាពដទៃទៀត ព្រមទាំងមេដឹកនាំរបស់ពួកគេត្រូវតែធ្វើការលើកឡើង អំពីមេរៀននៅប្រទេសកម្ពុជា ។

***ជាញឹកញាប់មានគេលើកឡើងថា អង្គការសហប្រជាជាតិបាននាំយកមេរោគអេដស៍ មកប្រទេសកម្ពុជា ។ តើអ្នកគិតថា នេះគឺជាការពិតទេ?***

នាងខ្ញុំបានធ្វើការប្រៀបធៀបប្រទេសកម្ពុជាជាមួយនឹងប្រទេសដទៃទៀត ដែលមិនមានវត្តមានអ៊ុនតាក់ ប្រទេសទាំងនោះសុទ្ធតែមានការពាក់ព័ន្ធទៅនឹងវីរុសហ៊ីវ ឬជំងឺអេដស៍ ។ ក៏ប៉ុន្តែប្រទេសកម្ពុជាគឺមានលក្ខណៈតិចតួច បើគិតត្រឹមការមកដល់នៃកងរក្សាសន្តិភាពអ៊ុនតាក់ ។ ហេតុនេះទើបបណ្តាលឲ្យយើងមានជំនឿថា កងរក្សាសន្តិភាពបង្កបរិយាកាសកាន់តែខ្លាំងក្នុងការជំរុញឲ្យមានការរីករាលដាលនៅប្រទេសកម្ពុជា ។

ទោះបីជាយ៉ាងណា នាងខ្ញុំនៅតែមានមន្ទិលថា កម្រិតតិចតួចនៃការឆ្លង ឬរីករាលដាលនៃវីរុសហ៊ីវ ឬជំងឺអេដស៍ មិនត្រូវបានរាយការណ៍ឲ្យបានទូលំទូលាយ នៅមុនពេលការចូលមកដល់នៃអ៊ុនតាក់ ឬអ៊ុនតាក់ជាអ្នកនាំមកឬយ៉ាងណាទេ? តែនាងខ្ញុំអាចនិយាយបានថា ការដែលប្រជាជនលើកឡើងអំពីភ័ស្តុតាងដែលថាអ៊ុនតាក់នាំនូវជំងឺមកកាន់ប្រទេសកម្ពុជា គឺគួរឲ្យជឿជាក់ជាង ។

# ចម្លើយសារភាពរបស់ សាម ចន ប្រធានក្រុមវះកាត់ផ្នែកពេទ្យ ៣-១៧

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D២១២៥៩*

សាម ចន ភេទប្រុស អាយុ២៣ឆ្នាំ កើតនៅភូមិកំពង់គរ ឃុំពោធិ៍បាន ស្រុកកោះធំ តំបន់២៥ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មុនពេលចាប់ខ្លួន ចន មាននាទីជាប្រធានក្រុមវះកាត់នៅមន្ទីរពេទ្យព-១៧ ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចេញពីចម្លើយសារភាពរបស់ ចន៖

ពេលចម្រើនវ័យអាយុបាន១០ឆ្នាំ ចន បានចូលរៀនអក្សរសាស្ត្រនៅសាលាវត្តពិជ័យសាគរ ក្នុងស្រុកកោះធំ ខេត្តកណ្តាល ។ លុះរៀនបានដល់ថ្នាក់ទី១០ ក៏ឈប់រៀន ហើយមកប្រកបរបររកស៊ីធ្វើស្រែចម្ការដើម្បីចិញ្ចឹមឪពុកម្តាយវិញ ។ ខែកុម្ភៈ ឆ្នាំ១៩៧២ ចន បានចូលធ្វើកងឈ្លបនៅឃុំពោធិ៍បាន ។ ៦ខែក្រោយមក បានឡើងមកជាយោធានៅស្រុកកោះធំ ខេត្តកណ្តាល ។

ឆ្នាំ១៩៧៣ ឈ្មោះ តាំង អនុប្រធានពេទ្យតំបន់២៥ និងឈ្មោះ មោក ប្រធានពេទ្យតំបន់២៥ បានស្នើទៅប្រធានយោធាស្រុកឈ្មោះ ជឿន ដើម្បីសុំយក ចន ឲ្យមកបម្រើការងារជាពេទ្យនៅតំបន់២៥ ។ ពេលមកនៅមន្ទីរពេទ្យតំបន់បានបីថ្ងៃ ចន ត្រូវបាន មោក និង តាំង ចាត់តាំងឲ្យធ្វើជាប្រធានក្រុមផ្នែកវះកាត់ ។



នារីពេទ្យខ្មែរក្រហមកំពុងផលិតថ្នាំបុរាណ នៅក្នុងមន្ទីរពេទ្យមួយ ក្នុងរបបកម្ពុជាប្រជាជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

មិនតែប៉ុណ្ណោះ ចន បានទទួលរបស់របរប្រើប្រាស់ជាហូរហែពី មោក និង តាំង មានដូចជា ពិល និងនាឡិកាដៃជាដើម ថែមទាំងបានប្រគល់កាំភ្លើងខ្លីមួយដើមឲ្យទៅ ចន ទៀតដងទុកប្រើការ ហើយនៅពេលទៅណាមកណា មោក និង តាំង តែងយក ចន ទៅជាមួយជានិច្ច ហាក់ដូចជានីសាររបស់ខ្លួនពិតៗ ។ នៅឆ្នាំ១៩៧៣នេះដែរ មោក និង តាំង បានបញ្ចូល ចន ឲ្យបម្រើការក្នុងភ្នាក់ងារ សេ.អ៊ី.អា និងបានដាក់ផែនការឲ្យអនុវត្ត គឺសម្លាប់យុទ្ធជនដែលមានរបួសចូលមកសម្រាកនៅមន្ទីរពេទ្យ និងបំផ្លាញសម្ភារផ្សេងៗ មានថ្នាំពេទ្យស៊ីរាំងជាដើម ។ ក្រោយពីបានទទួលការចាត់តាំងនេះហើយ ចន រួមជាមួយ សុខ ឡាក់ (នារី) និង សឹម (នារី) បានធ្វើសកម្មភាពបំផ្លាញថ្នាំពេទ្យប៉េនីស៊ីលីនអស់៣០០ដប កម្ទេចស៊ីរាំងអស់ ៨៤ ដើម ហើយបានប្រើវិធីសម្លាប់យុទ្ធជនដែលមកសម្រាកនៅមន្ទីរពេទ្យដោយប្រើអាល់កុលចាក់បញ្ចូលតាមសរសៃឈាមធ្វើឲ្យយុទ្ធជនស្លាប់អស់៣នាក់ ។ បន្ទាប់មក មោក និង តាំង បានណែនាំ ចន និង សឹម ឲ្យស្គាល់ខ្សែរយៈ សេ.អ៊ី.អា មួយចំនួនទៀត ដែលខ្លួនទើបកសាងបានមានឈ្មោះ ផេង , ហួយ គណៈផ្នែកពាណិជ្ជកម្មរដ្ឋ, ហុង ប្រធានផ្នែកព្យាបាលពោះ, ភោគ យុទ្ធជនវះកាត់ និងនារី ភេទ ប្រធានក្រុមផ្នែកព្យាបាល ។

ខែមេសា ឆ្នាំ១៩៧៤ ចន បានមកនៅមន្ទីរពេទ្យ៣១១ ជាមួយ ភោគ, ហុង, នារី ភេទ, ហួយ, សឹម និង ផេង ដែលជាខ្សែរយៈរបស់ខ្លួន ។ ក្រោយមកឈ្មោះ សុវ៉ាន់ ដែលជាប្រធានពេទ្យ ៣១១ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) បាននិយាយប្រាប់ ចន ថា "កម្លាំងមកពីតំបន់២៥ មិត្តបានស្គាល់អស់ហើយ ឯកម្លាំងនៅក្នុងពេទ្យ៣១១ គឺមានខ្ញុំ (សុវ៉ាន់), ឡេង និង ភាព ។ ដូច្នេះត្រូវបន្តសហការគ្នាធ្វើសកម្មភាពតទៅទៀត ដើម្បីសម្លាប់កម្លាំងបដិវត្តន៍តាមវិធីចាក់ថ្នាំ និងបំផ្លាញសម្ភារពេទ្យ ដូចជា ម្ជុល ស៊ីរាំង និងថ្នាំពេទ្យជាដើម" ។ ក្រោយពីបានស្គាល់កម្លាំងដែលជាខ្សែរយៈនៅពេទ្យ៣១១ ហើយ ចន រួមជាមួយបក្ខពួកទាំងអស់ បានធ្វើសកម្មភាពរួមគ្នានៅផ្នែកវះកាត់ ដោយចាក់ថ្នាំស្ពឹកតាល់ឲ្យហួសកម្រិត ធ្វើឲ្យយុទ្ធជនដែលជាអ្នករបួសស្លាប់អស់៥នាក់ និងចាក់ថ្នាំគីនីនតាមសរសៃឈាម ធ្វើឲ្យអ្នកជំងឺស្លាប់ជាបន្តបន្ទាប់ ដុតបំផ្លាញប៉ាំងឃាត់ឈាមខូចអស់២០ យកម៉ាស៊ីនភ្លើងសម្រាប់បញ្ចេះពេលវះកាត់ ទៅទម្លាក់ចោលក្នុងទឹកខូចអស់២គ្រឿង យកសាលីសាឡាត់មកចាក់សម្លាប់អ្នកជំងឺស្លាប់អស់៤នាក់ ។ បន្ទាប់មក បានដុតបំផ្លាញឃ្លាំងដាក់សម្ភាររបស់ពេទ្យ៣១១ ឆេះអស់មួយឃ្លាំង ។ បន្ទាប់ពីដុតបំផ្លាញសម្ភារនៅក្នុងឃ្លាំងឆេះអស់មួយឃ្លាំងរួចមក ចន និងបក្ខពួកបានទទួលការណែនាំពីថ្នាក់លើរបស់ខ្លួនឲ្យផ្អាកធ្វើសកម្មភាពមួយរយៈពេលសិន ព្រោះខ្លាចបែកការណ៍នាំឲ្យមានគ្រោះថ្នាក់ដល់កម្លាំងក្នុងក្រុម ។

ចុងខែឧសភា ឆ្នាំ១៩៧៤ មោក បានដាក់ផែនការឲ្យ ចន, សុវ៉ាន់, និង ភាព ធ្វើសកម្មភាពឡើងវិញ ដោយឲ្យដាក់ថ្នាំបំពុលក្នុងបាយសម្លរបស់អ្នកជំងឺ និងសម្លាប់អ្នកជំងឺក្នុងពេលវះកាត់ ។ ម្យ៉ាងទៀត ត្រូវរកវិធីកាត់ដៃ កាត់ជើងអ្នករបួសឲ្យបានច្រើន និងធ្វើសកម្មភាពលួចសម្ភារផ្ទាល់ខ្លួនរបស់អ្នកជំងឺ ដើម្បីឲ្យអ្នកជំងឺអស់ជំនឿលើបុគ្គលិកពេទ្យ ។ ក្រោយពីបានទទួលផែនការហើយ ចន រួមជាមួយ ហួយ និង ភាព បានបន្តធ្វើសកម្មភាពយកថ្នាំពុលដេដេតេទៅដាក់ក្នុងពាងទឹកឲ្យសមូហភាពហូប ធ្វើឲ្យពុលស្លាប់អស់ចំនួន៦នាក់ ចំណែកអ្នកដែលពុលតែមិនស្លាប់ បានកើតជំងឺរាករូសប្រហែល



ជាង៣០នាក់ ។ មួយខែក្រោយមក ចន និង ភេទ បានដើរលួចអង្រឹង ខោអាវរបស់អ្នកជំងឺដែលសម្រាកនៅក្នុងមន្ទីរពេទ្យ យកទៅដុតបំផ្លាញចោល ដែលជាហេតុធ្វើឲ្យអ្នកជំងឺមានការខ្វះសម្ភារ ថ្នាំងថ្នាក់ ស្អប់បុគ្គលិកពេទ្យគ្រប់ៗគ្នា ។ ក្រោយមកទៀត ចន បានទាក់ទងជាមួយ ភារ ហើយបានធ្វើសកម្មភាពសម្លាប់អ្នកបួសស្លាប់អស់ ៥នាក់ ។ ក្រោយមកអង្គការបានចាត់តាំងឲ្យ ចន និងបក្ខពួកបើកអង្ករពីពេទ្យ៣១១ យកទៅឲ្យមន្ទីរ១៤ ពេលនោះ ចន និងបក្ខពួកបានធ្វើឲ្យអង្ករធ្លាក់ចូលទៅក្នុងទឹកទន្លេខូចអស់១០បាវ ហើយបានដាក់ថ្នាំ អង់ទ្រីនបំពុលជ្រូកធំងាប់អស់៧ក្បាល និងកូនជ្រូកងាប់អស់ ១០០ក្បាល ហើយថែមទាំងបានបំផុសយុទ្ធជនយុទ្ធនារីឲ្យធ្វើខុសសីលធម៌នៅក្នុងអង្គភាពដែលជាហេតុធ្វើឲ្យអង្គភាពមានភាពច្របូកច្របល់ ។

ខែមករា ឆ្នាំ១៩៧៥ ចន បានទៅមើលថែអ្នកជំងឺនៅភូមិសាបានឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល ហើយបានជួប មោក នៅទីនោះដែរ ។ ចន ក៏បានរាយការណ៍ប្រាប់ មោក ពីសកម្មភាពដែលខ្លួន និងបក្ខពួកបានធ្វើកន្លងមកជាហូរហែ ។ ក្រោយពីស្ដាប់សេចក្ដីរាយការណ៍របស់ ចន ហើយ មោក បានដាក់ផែនការមួយចំនួនទៀតឲ្យ ចន និងបក្ខពួកធ្វើសកម្មភាពបន្តទៀតគឺ ដុតបំផ្លាញឃ្លាំងសម្ភាររបស់មន្ទីរពេទ្យតំបន់២៥ និងដុតបំផ្លាញរោងចិញ្ចឹមទាចោល ។ ក្រោយពីទទួលផែនការពី មោក ហើយ ចន និង ភោគ បានធ្វើសកម្មភាពដុតភ្លើងធ្វើឲ្យរាលឆេះសម្ភារអស់មួយឃ្លាំង ហើយបានដុតរោងចិញ្ចឹមទា ធ្វើឲ្យឆេះទាងាប់អស់២០០ក្បាលថែមទៀតផង ។ មិនតែប៉ុណ្ណោះ នៅពេលមកមន្ទីរពេទ្យវិញ បានសម្លាប់អ្នកជំងឺអស់បីនាក់ ដោយចាក់ថ្នាំឲ្យលើសកម្រិត ។ ខែមិថុនា ចន, ភោគ និង ហួយ បានមកនៅមន្ទីរពេទ្យ៣១១វិញ ហើយបានភ្ជាប់ខ្សែជាមួយ សុវ៉ាន់ ដែលជាខ្សែរយៈចាស់ ព្រោះនៅពេលនោះ សុវ៉ាន់ បានទទួលនាទីជាប្រធានផ្នែកវះកាត់នៅមន្ទីរពេទ្យ៣១១ ។ ខែមេសា ចន និង ភោគ ត្រូវបានចាត់តាំងឲ្យទៅនៅរោងចក្រតាខ្មៅ មានឈ្មោះ ដេង (ជាខ្សែរយៈ សេ.អ៊ី.អា ចាស់) ជាអ្នកគ្រប់គ្រង ។ ដេង បានណែនាំឲ្យ ចន, ភោគ និង ហួយ ឲ្យខិតខំពង្រឹងកម្លាំង សេ.អ៊ី.អា ឡើងវិញ និងបានដាក់ទិសឲ្យបន្តធ្វើសកម្មភាពនៅអង្គភាពនេះជាបន្តទៅទៀត ដោយឲ្យបំផ្លាញថ្នាំពេទ្យដែលប្រមូលយកមកពីទីក្រុង និងធ្វើការអុកឡុកនៅកន្លែងយុទ្ធនារីពិការ ធ្វើឲ្យមានភាពច្របូកច្របល់នៅក្នុងអង្គភាពដើម្បីងាយស្រួលអូសទាញប្រមូលកម្លាំង សេ.អ៊ី.អា ។ ចន និងបក្សពួកបានទៅប្រមូលយកថ្នាំពេទ្យនៅក្បាលថ្នល់ដាក់ក្នុងបាវលើកអុកៗ ធ្វើឲ្យថ្នាំរបើកខូចអស់៦បាវ ហើយបានបោះថ្នាំចោលតាមផ្លូវជាហូរហែអស់ថ្នាំជាច្រើនទៀត ។ ខែមិថុនា សុវ៉ាន់ បានណែនាំឲ្យ ចន ស្គាល់កម្លាំង សេ.អ៊ី.អា ថ្មីមួយចំនួនទៀតដែលខ្លួនទើបតែកសាងបាននៅក្នុងមន្ទីរពេទ្យព-១៧ មានឈ្មោះ ដាត យុទ្ធជនផ្នែកព្យាបាលនៅពេទ្យព-១៧, ឈ្មោះ ថន ប្រធានពួកផ្នែកព្យាបាលនៅពេទ្យព-១៧ បច្ចុប្បន្ននៅផ្នែកបង្កើនផលតាខ្មៅ, នារី ខុន ប្រធានពួក ផ្នែកព្យាបាលជំងឺនៅមន្ទីរពេទ្យព-១៧, នារី ដាន សមាជិកក្រុមព្យាបាលនៅមន្ទីរពេទ្យព-១៧ ។ រហូតមកដល់ខែតុលា ចន នៅមិនទាន់បានធ្វើការទាក់ទងជាមួយកម្លាំងដែលបានរៀបរាប់ខាងលើនៅឡើយទេ តែ ចន ខ្លួនឯងកសាងកម្លាំងថ្មីបានពីរនាក់មានឈ្មោះ នារី មុំ ប្រធានពួកផ្នែកព្យាបាលវះកាត់នៅមន្ទីរពេទ្យព-១៧ និងនារី ណេង ជាយុទ្ធនារីផ្នែកវះកាត់នៅមន្ទីរពេទ្យព-១៧ ។ ក្រោយមក ចន រួមជាមួយ នារី ណេង និងនារី មុំ ធ្វើសកម្មភាពចាក់ថ្នាំសម្លាប់យុទ្ធជនរបួសស្លាប់អស់៦នាក់ ដោយប្រើថ្នាំម៉ុកឃ្វីន ឲ្យលើសកម្រិត ។ បន្ទាប់ពីបានសម្លាប់យុទ្ធជនរបួសហើយ ចន និង ថន បានរួមគ្នាដុតបំផ្លាញសម្ភារនៅក្នុងឃ្លាំងខាងក្រោយមន្ទីរពេទ្យព-១៧ ឆេះខូចអង្ករអស់ជាង១០បាវ និងឆេះសម្ភារផ្សេងៗមួយចំនួនទៀត ។

នៅដើមខែវិច្ឆិកា ក្រោយពីបានទទួលការផែនការពី សុវ៉ាន់ ហើយ ចន រួមជាមួយនារី ណេង និងនារី មុំ នៅជាន់ខាងលើផ្នែកព្យាបាលអ្នកជំងឺក្រោយពីការវះកាត់រួច បានធ្វើសកម្មភាពយកថ្នាំអង់ទ្រីន ដាក់ចូលក្នុងបាយសម្ល រួចហើយយកទៅឲ្យអ្នកជំងឺហូប បណ្ដាលឲ្យអ្នកជំងឺខ្លះមានអាការៈរាក-ក្អួត ទន់ដៃ ទន់ជើង ហើយបណ្ដាលឲ្យស្លាប់អស់១៣នាក់ ។ ចំណែក ថន, ខុន និង ដាន នៅជាន់ខាងក្រោមបានចាក់ថ្នាំសម្លាប់យុទ្ធជនរបួសស្លាប់អស់១៧នាក់ ។

ឆ្នាំ១៩៧៦ ចាប់ពីខែកុម្ភៈ ដល់ខែមេសា ចន មិនបានចូលរួមធ្វើសកម្មភាពជាមួយបក្ខពួករបស់ខ្លួនទេ ព្រោះជាប់រៀនផ្នែកបច្ចេកទេសជំងឺទូទៅ និងផ្នែកវះកាត់នៅសាលាត-១២ ។ ក្រោយ

ពីរៀនចប់ ចន បានវិលត្រឡប់មកអង្គភាពផ្នែកវះកាត់វិញ ហើយបានបន្តធ្វើសកម្មភាពជាមួយ ផាត តាមការចាត់តាំងរបស់ សុវ៉ាន់ និងបានធ្វើសកម្មភាពបំផ្លាញឧបករណ៍ប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ មានម៉ាស៊ីនវាស់បេះដូង៦គ្រឿង ម៉ាស៊ីនឃាត់ឈាម៦គ្រឿង ម៉ាស៊ីនជំនួយដង្ហើម១គ្រឿង និងម៉ាស៊ីនសន្ទប់៣គ្រឿង ហើយបានមួលក្បាលដបអុកស៊ីសែន បញ្ចេញខ្យល់ចោលអស់១០ ប្រើការលែងកើត ។ បន្ទាប់មក សុវ៉ាន់ បានចាត់តាំងឲ្យ ចន និងបក្ខពួកធ្វើការតាមដានរាល់សកម្មភាពរបស់មិត្ត ពឿន បើមានឱកាសឲ្យដាក់ថ្នាំបំពុលក្នុងបាយសម្លសម្លាប់ចោល ។ ក្រោយមក មានសិក្ខាកាមមួយចំនួនបានមកបើកវគ្គរៀនសូត្រនៅក្នុងមន្ទីរពេទ្យ ចំណែក ចន មានភារកិច្ចជួយដាំបាយនៅខាងចុងភៅ ។ ឆ្លៀតក្នុងឱកាសនោះ ចន បានយកថ្នាំអង់ទ្រីនមកដាក់ក្នុងសម្ល ដើម្បីបំពុលសិក្ខាកាមដែលបានមករៀននៅទីនេះ រួមជាមួយមិត្ត ពឿន ម្នាក់ដែរ ។ នៅពេលសិក្ខាកាមទាំងអស់ហូបបាយ បណ្ដាលឲ្យពុលគ្រប់គ្នា ក្នុងនោះស្លាប់ចំនួន៦នាក់ ចំណែកអ្នកផ្សេងទៀត ត្រូវបានជួយសង្គ្រោះទាន់ពេលវេលា ។ រីឯមិត្ត ពឿន វិញមិនបានត្រូវថ្នាំពុលទេ ព្រោះបានចេញទៅហូបបាយជាមួយគ្រួសារនៅខាងក្រៅ ។ ដូច្នេះផែនការបំពុលមិត្ត ពឿន មិនបានសម្រេចទេនៅពេលនោះ ។

ខែមករា ឆ្នាំ១៩៧៧ សុវ៉ាន់ ត្រូវទៅចម្ការនៅឯដីដុះខាងលិចអ្នកលឿង ។ ចំណែក ចន បានមករៀននៅសាលាបច្ចេកទេសពេទ្យត-១២រយៈពេលពីរខែ ។ ពេលនោះ ចន បានទាក់ទងជាមួយ ភោគ ដែលជាអ្នកមករៀនសូត្រវគ្គជាមួយគ្នា និងបានរួមគ្នាធ្វើសកម្មភាពដាក់ថ្នាំអង់ទ្រីនចូលទៅក្នុងធុងទឹកឲ្យសិក្ខាកាមទាំងអស់ផឹក បណ្ដាលឲ្យស្លាប់អស់៣នាក់ ។ នៅពេលនោះដែរ ចន បានខូចសីលធម៌ជាមួយនារី ឈ្មោះ សឹម ។ ខែមេសា ឆ្នាំ១៩៧៧ សុវ៉ាន់ បានហៅ ចន, ភោគ, ហួយ និង ផាត មកជួបជុំគ្នានៅខាងកើតកន្លែងវះកាត់ ហើយបាននិយាយថា “ចាប់ពីពេលនេះតទៅ ខ្ញុំនឹងបែកពីមិត្តទាំងអស់គ្នាហើយ គឺត្រូវទៅនៅមន្ទីរដ-៨ ដែលជាអង្គភាពថ្មី ការបែកគ្នានេះ គឺបែករហូតមិនវិលមកវិញទេ តែមុននឹងបែក ខ្ញុំសូមជំរាបអ្នកទាំងអស់គ្នាថា អ្នកដែលមកដឹកនាំបន្តនៅទីនេះមានឈ្មោះ រី មុនឆ្នាំ១៩៧៥ នៅពេទ្យព-២៧ បច្ចុប្បន្នប្រធានវះកាត់ផ្នែកពោះនៅមន្ទីរពេទ្យព-១៧ ។ បើមានកិច្ចការអីសូមធ្វើការទាក់ទងជាមួយមិត្ត រី ចុះ” ។ បន្ទាប់មក សុវ៉ាន់ បានណែនាំកម្លាំងរបស់មិត្តសីមួយចំនួនទៀតឲ្យពួកយើងបានស្គាល់មានឈ្មោះ នារី វន ប្រធានផ្នែកវះកាត់រួមនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៨) សឿន អនុប្រធានផ្នែកវះកាត់រួមនៅពេទ្យព-១៧ (អង្គការចាប់ខ្លួនហើយ), សយ សមាជិកគណៈផ្នែកវះកាត់រួមនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៧), ដូល គណៈផ្នែកធ្មេញនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៧), នារី សុស អនុប្រធានផ្នែកធ្វើធ្មេញនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅចុងឆ្នាំ១៩៧៧), ប៉ោ គណៈបច្ចេកទេសជំងឺទូទៅនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៨), ធឿន គណៈផ្នែកខាងមើលប្រមុះនៅពេទ្យព-១៧ (អង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៨), ម៉េត ប្រធានក្រុមថត-ឆ្លុះ នៅមន្ទីរពេទ្យព-១៧ (អង្គការចាប់ខ្លួននៅដើមឆ្នាំ១៩៧៨) ។

ចុងខែមេសា ឆ្នាំ១៩៧៧ រី បានហៅ ចន, ភោគ, ណោង និង ផាត ទៅប្រជុំនៅបន្ទប់របស់ខ្លួនខាងជើងកន្លែងវះកាត់ ។ នៅពេលជួបជុំគ្នាហើយ រីបានដាក់ផែនការមួយចំនួនឲ្យអនុវត្តគឺ ទី១ ពេល តា ជួន ជឿន ចូលបន្ទប់វះកាត់ ត្រូវធ្វើឲ្យដបខ្យល់អុកស៊ីសែន និងបំពង់ប្រូតូស៊ីតរលំផ្ទុះឆេះបន្ទប់វះកាត់ ដើម្បីឲ្យឆេះតា ជួន ជឿន ស្លាប់នៅទីនោះ ទី២ ត្រូវធ្វើសកម្មភាពបំផ្លាញម៉ាស៊ីនចំហុយសម្ភារវះកាត់ និងទី៣ ត្រូវបំផ្លាញម៉ាស៊ីនត្រួតពិនិត្យភ្នែក និងម៉ាស៊ីនផ្សេងៗទៀតនៅគ្រប់ផ្នែកទាំងអស់ដែលប្រើប្រាស់ជាប្រចាំនៅក្នុងមន្ទីរពេទ្យ ។ ផែនការនេះត្រូវយកទៅអនុវត្តឲ្យបានសម្រេចនៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ខាងមុខនេះ ។ បន្ទាប់ពីបានទទួលផែនការហើយក៏បំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។ នៅដើមខែឧសភា ចន និង ផាត បានអនុវត្តតាមផែនការខាងលើ គឺនៅពេលដែលតា ជួន ជឿន កំពុងធ្វើការវះកាត់អ្នកឲ្យរបួស ចន និងបក្ខពួកបានប្រានដបអុកស៊ីសែន និងបំពង់ប្រូតូស៊ីតឲ្យដួលរលំ ក្នុងគោលបំណងឲ្យផ្ទុះឆេះនៅក្នុងបន្ទប់វះកាត់ និងឆេះតា ជួន ជឿន ស្លាប់នៅក្នុងបន្ទប់នោះដែរ ។ តែផែនការនេះមិនបានសម្រេចទេ ព្រោះនៅពេលបំពង់អុកស៊ីសែនរលំមិនទាន់ឆេះចេញអណ្ដាតភ្លើងផង តា ជួន ជឿន បានរត់ចេញទៅក្រៅបាត់ទៅហើយ ។ ក្រោយពីថ្ងៃធ្វើឲ្យរលំបំពង់អុកស៊ីសែនមក ចន និង ផាត បានបំផ្លាញម៉ាស៊ីនចំហុយប្រដាប់វះកាត់ឲ្យខូចប្រើការលែងកើត

អស់២គ្រឿង ។ បន្ទាប់មក រី បានដាក់ផែនការឲ្យ ចន និងបក្ខពួកអនុវត្តបន្តទៀតគឺ ត្រូវចាប់បង្ខំនារីពេទ្យរំលោភ ធ្វើឲ្យកើតមានសភាពច្របូកច្របល់នៅក្នុងមន្ទីរពេទ្យទាំងមូល បើមានគេឃើញ ឬគេទាន់ត្រូវឆ្លើយដាក់ទៅលើពួកយោធា ត្រូវលាក់កាំភ្លើងឲ្យបានគ្រប់កន្លែងនៅក្នុងអគ្គភាពដើម្បីត្រៀមប្រយុទ្ធជាមួយពួកយោធាដែលមកចាប់ពួកយើង ។ បន្ទាប់ពីបានទទួលផែនការ ហើយយើងក៏បានបំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។ ក្រោយមក ចន និង ផាត បានចាប់បង្ខំនារីពេទ្យរំលោភជាបន្តបន្ទាប់ដែលជាហេតុធ្វើឲ្យមានភាពចលាចលនៅក្នុងអគ្គភាព ។ បន្ទាប់មកថ្នាក់លើ បានណែនាំឲ្យបក្ខពួករបស់ ចន ផ្អាកធ្វើសកម្មភាពអុកឡុកចាប់នារីពេទ្យរំលោភមួយរយៈសិន ហើយបានណែនាំឲ្យបន្តធ្វើសកម្មភាពផ្សេងទៀតដូចជា បំផ្លាញម៉ាស៊ីន និងសម្ភារវះកាត់នៅជាន់ទី២ ត្រូវយកចិត្តទុកដាក់កសាងកម្លាំងមហាជនដែលនៅធ្វើការជាមួយគ្នាឲ្យបានច្រើនចូលបម្រើក្នុងចលនា សេ.អ៊ី.អា ។ ក្រោយពីបានទទួលការណែនាំផែនការហើយ ចន និង ផាត បានធ្វើសកម្មភាពបោះបាតធុងចំហុយសម្ភារធ្វើឲ្យខូចប្រើការលែងកើត ហើយបានកាត់បណ្តាញខ្សែភ្លើងនៅកន្លែងវះកាត់ធ្វើឲ្យស្ទះដល់ការងារវះកាត់ និងកសាងកម្លាំងបានបីនាក់ទៀតមានឈ្មោះ ទ្រី យុទ្ធជនលីសែងនៅពាណិជ្ជកម្មរដ្ឋ, ហាន ប្រធានក្រុមផ្នែកលីសែងនៅពាណិជ្ជកម្មរដ្ឋ និង ថា ប្រធានពួកផ្នែកលីសែងនៅពាណិជ្ជកម្មរដ្ឋ ឲ្យចូលរួមបម្រើការក្នុងចលនា សេ.អ៊ី.អា ។

ខែតុលា ឆ្នាំ១៩៧៧ រី បានហៅ ចន, ផាត និង ថន ឲ្យទៅជួបនៅផ្ទះបាយចាស់ ។ នៅពេលជួបជុំគ្នាហើយ រី បាននិយាយថា «យើងបានផ្អាកធ្វើសកម្មភាពផ្នែកអុកឡុក ចាប់បង្ខំនារីពេទ្យរំលោភអស់មួយរយៈកន្លងមកហើយ តែឥឡូវ យើងត្រូវបន្តធ្វើផ្នែកនេះជាបណ្តើរៗតទៅទៀត តែត្រូវរក្សាការសម្ងាត់ឲ្យបានដាច់ខាត ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមជម្រាបថា បង សី និង បង សាត ត្រូវបានអង្គការដកយកទៅបាត់ហើយ ប្រហែលជាចាប់ខ្លួនផងក៏មិនដឹង ។ តែយើងមិនបាច់គិតអ្វីច្រើនទេ ចេះតែបន្តធ្វើសកម្មភាពទៅក្រោមការដឹកនាំរបស់អ្នកដឹកនាំថ្មីឈ្មោះ ឃន» ។ ក្រោយពីបានទទួលការណែនាំពី រី ហើយ ចន, ផាត និង ថន បានធ្វើសកម្មភាពអុកឡុកនារីពេទ្យបន្តទៀត ដោយដើរគប់ផ្ទះដែលនារីពេទ្យស្នាក់នៅ ដើរគាស់ជញ្ជាំងចាប់ទាញជើងនារីដែលកំពុងសម្រាក ហើយបានលួចយកនំប័ុងរបស់នារីៗមកចែកគ្នាហូបតាមផ្លូវទៀតផង ។ រីឯខាងផ្នែកក្រុមវះកាត់ឆ្អឹង ចន បានដឹកនាំកម្លាំង ដែលទើបកសាងបានមានឈ្មោះនារី ខុម និងនារី វុន ធ្វើយ៉ាងណាវះកាត់ឲ្យដាច់សរសៃឈាម ដាច់សរសៃប្រសាទរបស់អ្នកជំងឺ ហើយយកលែះកាត់ដៃ កាត់ជើងរបស់អ្នកជំងឺចោលតែម្តង ។

ខែមករា ឆ្នាំ១៩៧៨ ចន និង ផាត បានមករៀនសូត្រផ្នែកនយោបាយនៅសាលាផ-៥ ។ មុនពេលមករៀន រី បានណែនាំដាក់ផែនការឲ្យធ្វើសកម្មភាពយកអង់ទ្រីនទៅដាក់ក្នុងទឹកក្តៅដើម្បីបំពុលសិក្ខាកាមផង និងបំពុលអ៊ំ អៀង ធិរិទ្ធ ផងព្រោះគាត់ទៅខទ្វេសនាមនៅទីនោះដែរ ។ ផែនការមួយទៀត គឺ ឲ្យបំផ្លាញសាកសពដែលត្រាំទឹកហ្វូកម៉ូលទុកសម្រាប់ធ្វើការពិសោធន៍ចោល ។ បានទទួលការណែនាំហើយ ចន និង ផាត បានយកអង់ទ្រីនលាយជាមួយទឹករំចេកដាក់ក្នុងបាឡូយកទៅជាមួយ តែត្រូវបានអ្នកយាមនៅតាមផ្លូវឆែកឆេរឃើញ ហើយបានដកហូតយកអស់ទៅ ។ ដូច្នេះផែនការដាក់ថ្នាំបំពុលមិនបានអនុវត្តទេនៅពេលនោះ តែបានអនុវត្តផែនការមួយទៀតគឺបើកបង្ហូរទឹកត្រាំសាកសពហ្វូកម៉ូលចោល ហើយបញ្ចូលទឹកម៉ាស៊ីនធម្មតាជំនួសវិញ ធ្វើឲ្យសាកសពរលួយខូចអស់៦ ។ បន្ទាប់ពីរៀនចប់ ចន បានវិលមកអគ្គភាពដើមវិញហើយបានរួមសកម្មភាពជាមួយនារី ខុម និងនារី វុនដាក់ថ្នាំក្នុងបាយសម្លបំពុលអ្នកជំងឺស្លាប់អស់បីនាក់ ។

ខែឧសភា ឆ្នាំ១៩៧៨ រី បានហៅ ចន, ខុម, វុន និង មុំ ទៅជួបនៅបន្ទប់វះកាត់ជាន់ទី១ ។ ពេលនោះ រី បាននិយាយថា «កន្លងមកកម្លាំងយើងបានបែកខ្ញែកអស់ច្រើនណាស់ គឺត្រូវអង្គការចាប់ខ្លួនផង ត្រូវដកទៅអគ្គភាពផ្សេងៗផង ហេតុនេះ ដើម្បីរួមគ្នាបន្តធ្វើសកម្មភាពទៀត ខ្ញុំសូមណែនាំឲ្យមិត្តទាំងអស់ស្គាល់កម្លាំងថ្មីរបស់យើងចំនួនបីនាក់ទៀតមានឈ្មោះ អុយ ប្រធានពួកខាងទទួលថ្នាំសន្លប់, សុត ប្រធានពួកខាងវះកាត់ក្បាល, និង ចាន់ ប្រធានក្រុមផ្នែកព្យាបាលជំងឺក្រោយពីវះកាត់ហើយ» ។ បន្ទាប់ពីណែនាំឲ្យស្គាល់គ្នាហើយ រី បានដាក់ផែនការថ្មីឲ្យអនុវត្តគឺ ត្រូវបំផ្លាញចង្កៀងឆ្លុះសម្រាប់វះកាត់ដើម្បីរារាំងដល់ការងារវះកាត់ បំផ្លាញម៉ាស៊ីនបឺតខ្ទុះ-ឈាម ម៉ាស៊ីនវាស់ជីពចរ និងប្រដាប់វាស់ឈាម ។ ក្រោយពីបានទទួលផែនការហើយ ចន, សុត, អុយ និង ចាន់ បានធ្វើសកម្មភាព

រួមគ្នាបំផ្លាញចង្កៀងផ្ទុះសម្រាប់វះកាត់ កាត់បណ្ដាញខ្សែភ្លើង និងដុំភ្លើងចោល ធ្វើឲ្យចង្កៀងប្រើការលែងកើតអស់ពីរគ្រឿង និងបំផ្លាញម៉ាស៊ីនប៊ឹតធុនធំអស់បីគ្រឿង ។

ខែមិថុនា ឆ្នាំ១៩៧៨ រី បានហៅ ចន និងបក្ខពួកមកប្រជុំ ហើយបានដាក់ផែនការឲ្យអនុវត្តចាប់ពីចន្លោះខែមិថុនា ដល់ខែសីហា ត្រូវសម្លាប់អ្នករបួសឲ្យបានចំនួន១០នាក់ ក្រៅពីនេះត្រូវបំផ្លាញសម្ភារប្រើប្រាស់ឲ្យបានយ៉ាងតិច១០មុខ ត្រូវខិតខំកសាងកម្លាំងឲ្យបានច្រើន ម្យ៉ាងទៀតពេលទាក់ទងគ្នាធ្វើសកម្មភាព ត្រូវប្រយ័ត្នប្រយែងលាក់ការណ៍សម្ងាត់ឲ្យបានខ្ពស់បំផុត ។ ក្រោយពីបានទទួលការណែនាំពី រី ហើយ ចន និងបក្ខពួកបានសម្លាប់អ្នករបួសដែលមកព្យាបាលនៅក្នុងមន្ទីរពេទ្យនេះជាបន្តបន្ទាប់ ។ ជាក់ស្តែងកាលណោះមានអ្នករបួសមកពីភូមិភាគបូព៌ាជាច្រើននាក់ក្នុងនោះមានអ្នកជំងឺម្នាក់ពិបាកដកដង្ហើម ចន និងបក្សពួកមិនបានជួយសង្គ្រោះអ្នកជំងឺនោះឲ្យទាន់ពេលវេលាទេ បែរជាទុកអ្នកជំងឺម្នាក់នោះចោលរហូតដល់ស្លាប់តែម្តង ។ មានករណីមួយទៀត អ្នកជំងឺត្រូវរបួសបញ្ចិតឆ្អឹងជំនីត្រូវការពេទ្យសង្គ្រោះបន្ទាន់ ចន និងបក្សពួកបានយកថ្នាំពីរមុខលាយបញ្ចូលគ្នា ហើយចាក់តាមសរសៃឈាមឲ្យអ្នកជំងឺនោះ ជាងកន្លះម៉ោងក្រោយមក អ្នកជំងឺម្នាក់នោះក៏ស្លាប់បាត់ទៅ ។ ចន និងបក្ខពួកបានធ្វើសកម្មភាពបំផ្លាញកម្លាំងបដិវត្តន៍ជាបន្តបន្ទាប់ តាមរយៈការចាក់ថ្នាំសម្លាប់តាមរយៈការវះកាត់ឲ្យហូរឈាមច្រើន ហើយយកថ្នាំសន្លប់មកចាក់ឲ្យស្លាប់តែម្តង តាមរយៈការទុកអ្នកជំងឺចោលមិនយកចិត្តទុកដាក់ជួយសង្គ្រោះឲ្យបានទាន់ពេលវេលាជាដើម ។

ខែសីហា ឆ្នាំ១៩៧៨ ចន និងបក្ខពួកបានទៅប្រជុំនៅសាលាខាងជើងកន្លែងវះកាត់ ។ ពេលនោះ រី បាននិយាយថា "សភាពការណ៍នៅក្នុងអង្គភាពដែលក្រុម សេ.អ៊ី.អា បានធ្វើឲ្យមានការស្មុគស្មាញ និងច្របូកច្របល់នោះ ឥឡូវនេះត្រូវបានអង្គការដោះស្រាយឲ្យមានសភាពធម្មតាវិញហើយ ដូច្នេះសុំស្នើមិត្តទាំងអស់ខិតខំធ្វើយ៉ាងណាប្រមូលកម្លាំងមហាជនឲ្យចូលមកខាងយើងឲ្យបានច្រើន ជាពិសេសកម្លាំងចាស់ៗដែលយើងធ្លាប់ស្គាល់កន្លងមក ។ ចំណែកមិត្ត មុី ជាបុគ្គលម្នាក់ដែលត្រូវបានសង្ស័យថា ជារនុកក្នុង ជាអ្នករាយការណ៍ទៅឲ្យខាងគណៈមន្ទីរ ហើយមិត្ត មុី នេះមានជំងឺពោះវៀនដុះខ្នែងចង់មកធ្វើការវះកាត់នៅកន្លែងយើង ។ ហេតុនេះ ចន និង ខុម ត្រូវធ្វើការងារនេះជាមួយគ្នា គឺធ្វើយ៉ាងណាសម្លាប់ មិត្ត មុី នេះឲ្យបាននៅពេលធ្វើការវះកាត់ បើទុកមិត្ត មុី នេះនាំឲ្យបែកការណ៍ និងមានគ្រោះថ្នាក់ដល់ក្រុម សេ.អ៊ី.អា ជាមិនខាន ។ ក្រោយពេលប្រជុំចប់ យើងក៏បែកគ្នាទៅកន្លែងរៀងៗខ្លួន ។ ក្រោយមក គណៈផ្នែក និងគណៈមន្ទីរត្រូវផ្លាស់មនុស្សមកថ្មី ។ ពេលនោះ រី បានមកទទួលដឹកនាំផ្នែកវះកាត់ខាងពោះវិញ ។ ចំណែក ចន រយៈពេលជាងមួយខែកន្លងមកនេះ គឺខិតខំយកចិត្តយកថ្លើម អែបអបគណៈផ្នែកថ្មីក្នុងគោលបំណងចង់ក្តាប់យកមុខតំណែងខាងយុវជនផ្នែកវះកាត់ ។

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៨ មិត្ត មុី បានស្នើសុំធ្វើការវះកាត់ខ្នែងពោះវៀនរបស់ខ្លួន ។ ពេលនោះ ចន និង ខុម បានរៀបចំប្រដាប់ប្រដាសម្រាប់វះកាត់ឲ្យមិត្ត មុី តាមការគ្រោងទុក ។ ការវះកាត់នេះ គឺត្រូវវះឲ្យឆ្ងាយពោះវៀនតូចនៅផ្នែកខាងក្នុងពោះ ហើយមិនត្រូវដេរពោះវៀនដែលដែលឆ្ងាយនោះឲ្យជិតវិញទេ ធ្វើបែបនេះមិនយូរប៉ុន្មាន មេរោគនឹងបង្កឲ្យទៅជាខ្ទុះនៅផ្នែកខាងក្នុងពោះ ធ្វើឲ្យមិត្ត មុី ឈឺចុកចាប់ស្លាប់ជាមិនខាន ។ ក្រោយពីធ្វើការវះកាត់តាមគំរោងផែនការរួចរាល់ហើយ មិត្ត មុី ឈឺក្នុងពោះជាប់រហូត ។ មិត្ត មុី បានស្លាប់នៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៨ ក្រោយពីធ្វើការវះកាត់រួចបានប៉ុន្មានថ្ងៃ ។ បន្ទាប់ពីមិត្ត មុី ស្លាប់បានរយៈពេលពីរថ្ងៃ ចន ក៏ត្រូវបានអង្គការចាប់ខ្លួនតែម្តង គឺចាប់ខ្លួននៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨ ។

ចន មានឪពុកឈ្មោះ សាម សេង អាយុ៨៨ឆ្នាំ នៅរស់ ម្តាយឈ្មោះ សុខ ហួយ អាយុ៦៦ឆ្នាំនៅរស់ ។ នៅក្នុងចម្លើយសារភាព ចន មិនបានសរសេររៀបរាប់អំពីឈ្មោះ និងចំនួនបងប្អូនបង្កើត និងប្រពន្ធកូនរបស់ខ្លួនទេ ។

ចន ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៨ ពីបទចូលរួមក្នុងចលនា សេ.អ៊ី.អា ក្បត់នឹងបដិវត្តន៍ ហើយបានបញ្ជូនខ្លួនមកមន្ទីរសន្តិសុខស-២១ ។ ចម្លើយសារភាពរបស់ ចន ជាឯកសារវាយអង្គុលីលេខមានចំនួន៣១ទំព័រ ធ្វើនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៨ ។ នៅចុងបញ្ចប់នៃចម្លើយសារភាព មានចុះហត្ថលេខា និងស្នាមផ្តិតមេដៃរបស់ ចន និងមានហត្ថលេខារបស់អ្នកសួរចម្លើយឈ្មោះ សេង ។ **ឆេង ទ៉េង**

# ចាប ហឿន និងផែនការបោសសម្អាតប្រជាជនថ្មី នៅតំបន់៤១ ភូមិភាគកណ្តាល

ចាប ហឿន មុនអង្គការចាប់ខ្លួនមាននាទីជាប្រធានវរសេនាតូច កងពល១៧៧ ភូមិភាគកណ្តាល តំបន់៤១ ។ នៅក្នុងឯកសារចម្លើយសារភាពដែលមិនទាន់សរសេរចប់របស់ ចាប ហឿន ដែលវាយជាអង្គុលីលេខឡើងវិញ មានចំនួន២៨ទំព័រ និងចុះកាលបរិច្ឆេទនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ព្រមទាំងមានហត្ថលេខាអ្នកសួរចម្លើយឈ្មោះ ឡាច មៀន។ ហឿន បានសរសេររៀបរាប់យ៉ាងលម្អិតអំពីរបៀប និងផែនការបោសសម្អាតប្រជាជន៧៥ ឬហៅថា ប្រជាជនថ្មី នៅក្នុងតំបន់៤១ ដែលគ្រប់គ្រងដោយលេខាតំបន់ឈ្មោះ អាន។ នៅក្នុងសំណេររបស់ ហឿន បានឲ្យដឹងថា ប្រជាជនថ្មីចំនួន២៣៩១នាក់ ត្រូវអង្គការតំបន់៤១ សម្រេចបោសសម្អាតជាដាច់ខាតឲ្យរួចរាល់ ក្នុងរយៈពេលតែបីខែប៉ុណ្ណោះ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ចាប ហឿន ដែលដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១៦៩៩ និងសកម្មភាពរបស់សាម៉ីខ្លួនៈ

ហឿន មានស្រុកកំណើតនៅភូមិក្រាំងម្តេង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត ។ ហឿន បានចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧០ នៅស្រុកឈូក ជាកងទ័ពប្រចាំស្រុក ដោយមាននាទីជាយុទ្ធជន ។ ក្រោយមកក៏ផ្លាស់មកនៅទ័ពតំបន់ បានរយៈពេលមួយឆ្នាំ ហើយនៅឆ្នាំ១៩៧២ ហឿន ត្រូវអង្គការផ្លាស់មកនៅកងទ័ពភូមិភាគនិរតីវិញ ដោយមាននាទីជាយុទ្ធជនដដែល ។ នៅឆ្នាំ១៩៧៣ ហឿន ត្រូវបានអង្គការបញ្ចូលទៅក្នុងកងពលទី២ ។ រហូតមកដល់ឆ្នាំ១៩៧៣ ឈ្មោះ កាន ប្រធានវរសេនាតូច បានដក ហឿន ឲ្យទៅ



ឧបករណ៍សម្រាប់ធ្វើទារុណកម្មអ្នកទោស នៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

ធ្វើជានីរសារវិញ ។

ក្រោយថ្ងៃរំដោះ ឆ្នាំ១៩៧៥ កាន បានហៅ ហឿន មកធ្វើការអប់រំពីរដង ដោយបាននិយាយថា អាមេរិកាំងមិនចាញ់សង្គ្រាមនោះទេ គឺគេដកថយដើម្បីមកវាយយើងម្ដងទៀត ។ កាន បានប្រាប់ ហឿន ទៀតថា ដូច្នេះ គួរតែនាំគ្នាចូលទៅខាងអាមេរិកាំងវិញ ព្រោះគេមានអាវុធទំនើបៗ ហើយបើគេវាយឈ្នះបដិវត្តន៍ យើងនឹងរៀបចំប្រទេសដូចដើម រកស៊ីឯកជន តាមចិត្ត មានប្រាក់ខែ មានផ្ទះថ្មនៅជាដើម ។

នៅឆ្នាំដដែល កាន បានណែនាំ ហឿន ឲ្យស្គាល់ឈ្មោះ ឃឹម នៅកងពលភាគកណ្ដាល (បាញ់ខ្លួនឯងស្លាប់) និង សាន នៅកងអនុសេនាធំ (ត្រូវយួនបាញ់ស្លាប់ នៅក្នុងឆ្នាំ១៩៧៦) ឲ្យរួមគ្នាធ្វើសកម្មភាពបង្កទំនាស់ជាមួយកងផ្សេងៗ និងវាយប្រហារដោយពាក្យសម្ដី ។

នៅឆ្នាំ១៩៧៦ អង្គការបានផ្លាស់ កាន និង ហឿន មកនៅមូលដ្ឋានស្រុក៥៥ តំបន់៣៣ វិញ ។ មួយខែក្រោយមក ឃឹម បានមកជួប កាន នៅឃុំអង្គាញ់ និងមានបំណងជួបបងប្អូនឈ្មោះ ហ៊ាង, ហ៊ាប និងស្រី ដែលអ្នកទាំងបីជាគណៈឃុំអង្គាញ់ផង ។ នៅពេលយប់ កាន ហៅអ្នកទាំងអស់គ្នាមកប្រជុំអប់រំនយោបាយធ្វើយ៉ាងណាឲ្យប្រជាជនប្រឆាំងនឹងបដិវត្តន៍ អស់ជំនឿលើអង្គការ ។ អ្នកទាំងអស់គ្នាបានឯកភាពលើសកម្មភាពនេះ ។

ក្រោយមក អង្គការបានផ្លាស់ ហឿន និង កាន ទៅកន្លែងផ្សេង ។ ពេលនោះ កាន បានហៅ ហ៊ាប, ហ៊ាង និង ស្រី មកប្រាប់ថាពេលនេះអង្គការបានផ្លាស់គាត់ចេញមិនដឹងទៅទីណាទេ ហើយឲ្យ ហ៊ាប ទាក់ទងបន្តសកម្មភាពជាមួយ ឃឹម តទៅទៀត ។ នៅថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៧៧ ហឿន និង កាន បានចេញដំណើរពីឃុំអង្គាញ់ មកត្រាំខ្នា ព្រោះឡានភូមិភាគនៅចាំទទួលមកភ្នំពេញ ទៅដល់ក៏បានជួបនឹង បងភឹម, បងម៉ុន, បងស៊ុម, អ៊ុំអាន និង បងណៃម រួចធ្វើដំណើរមកភ្នំពេញជាមួយគ្នា ។ មកសម្រាកនៅភ្នំពេញបានមួយអាទិត្យ អង្គការបានប្រជុំចាត់តាំងណែនាំ ព្រមទាំងប្រាប់ពីសភាពការណ៍នៅភូមិភាគកណ្ដាល ពីសកម្មភាពរបស់ខ្មាំងបង្កប់ស៊ីរូងបានច្បាស់លាស់ ហើយបានឲ្យអ្នកទាំងអស់គ្នាចេញដំណើរពីភ្នំពេញទៅកំពង់ចាម ។ ទៅដល់កំពង់ចាម សម្រាកបាន ១៥ថ្ងៃ ឆ្លៀតពេលនោះ កាន បានណែនាំ ហឿន ថាមកដល់ទីនេះគឺដាច់ខ្សែចាត់តាំងនៅឃុំអង្គាញ់អស់ហើយ តែសភាពការណ៍នៅភូមិភាគកណ្ដាលនេះ គឺមានការចាប់ពួកខ្មាំងស៊ីរូងច្រើន គឺពួក ធុច តាំងពីគណៈភាគដល់សហករណ៍ ហេតុនេះត្រូវនឹងនរ ចាំដល់ទៅកន្លែងណាដែលក្ដាប់ភូមិសាស្ត្រ ក្ដាប់សភាពការណ៍ប្រជាជនបាននៅកន្លែងនោះ ចាំរៀបផែនការតាមជាក់ស្ដែងនៅមូលដ្ឋាននោះ ។

នៅខែកុម្ភៈ ឆ្នាំដដែល ឈ្មោះ ពក បានហៅអ្នកដែលទៅពីនិរតីទាំងអស់នោះទៅប្រជុំនៅកន្លែងគាត់ ហើយចាត់ឲ្យអ្នកទាំងអស់គ្នាចេញទៅតាមមូលដ្ឋាន គឺទៅតំបន់៤១ ដោយចាត់តាំងឲ្យឈ្មោះ ស៊ុម ធ្វើជាលេខាស្រុកព្រៃឈរ, ភឹម ធ្វើជាលេខាស្រុកបាធាយ, កាន ធ្វើជាលេខាស្រុកកង មាស និង ណៃម ធ្វើជាអនុលេខាស្រុកព្រៃឈរ ហើយឈ្មោះ អាន ធ្វើជាលេខាតំបន់៤១ និងជាអនុលេខាភូមិភាគផង ។

ពេលចូលដល់មូលដ្ឋានបានរយៈពេល២ខែ ក្រោយពីបានក្ដាប់ភូមិសាស្ត្រ ទឹកដី ប្រជាជនបានហើយ កាន បានហៅ ហឿន មកណែនាំសាជាថ្មី ដោយចាត់ឲ្យ ហឿន ពិនិត្យមើលខ្សែរបស់ឈ្មោះ ធុច មាននៅប៉ុន្មាន ឋានៈជាអ្វីខ្លះ បក្សជនប៉ុន្មាន អង្គការស្នូលប៉ុន្មាន ដែលគេចាត់តាំងពីមុន? ហឿន បានធ្វើគម្រោងស្ថិតិតាមការណែនាំរបស់ កាន ប្រមូលគ្រប់ឃុំមកសរុប ឃើញនៅសល់បក្សជនចាស់ដែលពួក ធុច ចាត់តាំង៥ នាក់ អង្គការស្នូល៧នាក់ អ្នកទាំងអស់មាននាទីជាប្រធានកងធំនៅតាមភូមិ ។

ហឿន បានបញ្ជូនស្ថិតិឲ្យមកតំបន់ រយៈពេលពីរថ្ងៃក្រោយមកបានឃើញសំបុត្រពីតំបន់មកវិញ ឲ្យហៅអ្នកទាំងនោះមកប្រជុំដើម្បីចាត់តាំងកម្មាភិបាលជាថ្មី ។ ពេលប្រជុំ កាន បាននិយាយថាអង្គការចាត់តាំងឲ្យអ្នកទាំងអស់គ្នា បន្តភារកិច្ចរបស់ខ្លួនបន្តទៀត ព្រោះនៅស្រុកនេះ ខ្វះកម្មាភិបាលដឹកនាំច្រើនណាស់ ។ កាន បានអប់រំលើកម្មាភិបាលទាំងនេះ ត្រូវបន្តរៀបចំមាគ៌ាសកម្មភាពដែលធ្លាប់បានអនុវត្ត បញ្ហារៀបចំធ្វើការងារ កម្មវិធីក្ដៅជាប់ បើមានប្រជាជនណាប្រឆាំងនឹងមាគ៌ាបក្ស ត្រូវមានវិធានការ ដូចជា បញ្ហាលួចពោត ដំឡូង ត្រូវចាប់បញ្ជូនទៅមន្ទីរសន្តិសុខ ។ ប្រមូលសម្ភារប្រជាជន ដូចជា ចាន ឆ្នាំង ស្លាបព្រា មាន់ ទា ជ្រូក គោក្របី សេះ ត្រូវប្រមូលយកមកដាក់ឃ្លាំង ធ្វើបញ្ជីឲ្យបានច្បាស់លាស់ ។ បញ្ហា

មួយទៀត បើមានបាតុភាពអីកើតឡើងត្រូវរាយការណ៍ភ្លាម ដូចដែលពួកគេធ្លាប់រាយការណ៍ពីមុនមក ដើម្បីងាយស្រួលចាត់វិធានការ ។

ក្រោយមកបានពីរថ្ងៃ ឃើញសំបុត្រខាងតំបន់ហៅ កាន ទៅប្រជុំការងារនៅមន្ទីរតំបន់ ក្នុងខែមេសា ឆ្នាំ១៩៧៧ ។ រយៈពេលបីថ្ងៃ ទើបឃើញ កាន មកវិញ ហើយពេលយប់ កាន បានហៅ ហឿន ទៅប្រាប់ឲ្យសរសេរសំបុត្រហៅប្រធានឃុំគ្រប់ឃុំមកប្រជុំនៅមន្ទីរស្រុក ។ ពេលនោះ កាន លាន់មាត់ថា "ខ្ញុំស្មានថា បងអាន គាត់គ្មានជំហរអីប្រឆាំងបដិវត្តន៍ទេ តែឥឡូវគាត់នៅជាមួយយើងដែរ បញ្ហារើសកម្មាភិបាលអីក៏ឲ្យយកពួកដែលចាត់តាំងជំនាន់ អាធុច ធ្វើកម្មាភិបាលដែរ" ។ ហឿន បញ្ជាក់ថា កាលណោះ អ៊ឹ អាន (ហឿន ហៅ) ជាអនុលេខាភូមិភាគ និងជាលេខាតំបន់៤១ តែក្រោយមកក្លាយជាសមាជិកភូមិភាគ និងមាននាទីជាលេខាតំបន់៤១ដដែល ហើយ ស៊ឹម ក្លាយជាអនុលេខាភូមិភាគ និងជាលេខាតំបន់៤៣វិញ និង កាន ក្លាយជាសមាជិកតំបន់៤១ និង ជាលេខាស្រុកកងមាស ។ ការប្រជុំជាមួយប្រធានឃុំទាំងអស់ ផ្តោតទៅលើបញ្ហាចំនួនបីគឺ ៈ

១) តាមគណៈឃុំទាំងអស់បានលើកថា ផែនការកន្លងមកគឺធ្វើសកម្មភាពបំភ្លើសបំភ្លៃមាគ៌ាក្នុងការដឹកនាំប្រជាជន ។

២) ប្រជាជនកន្លងមកមិនជ្រះស្រឡះ និងផែនការភាគច្រើនមានគេចវេះមិនធ្វើការងារ ។

៣) សម្ភារកន្លងមកប្រមូលបានខ្លះ នៅសល់ខ្លះតាមផ្ទះ ដូចជាឆ្នាំង ចាន មាននៅតាមផ្ទះ ។

ចុងបញ្ចប់នៃការប្រជុំ កាន បានប្រកាសប្រាប់កម្មាភិបាលចាត់តាំងឲ្យដឹងពីកម្មាភិបាលនៅក្នុងតំបន់ គឺគណៈតំបន់មាន បងអាន ជាលេខា, បងស៊ឹម ជាអនុលេខា និងសមមិត្ត ភឹម ជាសមាជិក ។ បន្ទាប់មក កាន បានប្រកាសពីផែនការដែលត្រូវអនុវត្តតទៅមុខ ដែលអង្គការតំបន់ដាក់មក គឺ

១) ផែនការប្រមូលប្រជាជន ៧៥ (បោសសម្អាត)

២) ផែនការប្រមូលអាណិកជនចិនដាក់មួយកន្លែង ដើម្បីតាមដានសកម្មភាព ។

៣) ផែនការប្រមូលអាណិកជនចាម ដាក់មួយកន្លែង ដើម្បីតាមដានសកម្មភាព ។

៤) បញ្ហាទាហានជំនាន់ចាស់ ជំនាន់ លន់ នល់ ត្រូវធ្វើស្ថិតិប្រវត្តិរូបឲ្យច្បាស់ដើម្បីរៀបចំចាត់តាំងឲ្យធ្វើជាប្រធានក្រុមខ្លះ នៅតាមឃុំនានា ។

នៅខែឧសភា អ៊ឹ អាន (ហឿន ហៅឈ្មោះ អាន) បានចុះមកធ្វើមីទ្ទីងម្តង នៅស្រុកកងមាស ដោយបានប្រមូលប្រជាជនបីឃុំមកធ្វើរួមគ្នា គឺឃុំរកាគយ, ឃុំព្រែកក្របៅ និងឃុំអង្គរបាន ។ ពេលនោះ កាន ឡើងប្រកាសកម្មវិធីគឺ ៈ

១) សេចក្តីថ្លែងការរបស់គណៈតំបន់៤១

២) ការចាប់អារម្មណ៍របស់តំណាងស្រុកកងមាស ។

ក្រៅពីនោះ ពេលបើក និងបិទកម្មវិធី អ៊ឹ អាន បានលើកយកបញ្ហាបីមកនិយាយគឺ ៈ

១) សភាពការណ៍ខ្មាំងខាងក្នុង និងខាងក្រៅ ។

២) អំពីសភាពការណ៍បដិវត្តន៍សង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ។

៣) មិនអនុញ្ញាតឲ្យប្រជាជនដើរចេញចូល ទៅណាមកណា ធ្វើការនៅកន្លែងណា នៅកន្លែងហ្នឹង ដាច់ខាតមិនឲ្យដើរឆ្លងកាត់ទេ ។

បន្ទាប់ពី អ៊ឹ អាន បានថ្លែងការណ៍ចប់ កាន ឡើងចាប់អារម្មណ៍ពីសេចក្តីថ្លែងការណ៍របស់ អ៊ឹ អាន ដែលបានលើកឡើង និងធ្វើការប្តេជ្ញាខិតខំតាមដានសកម្មភាពខ្មាំងដែលធ្វើសកម្មភាពប្រឆាំងផែនការអង្គការ ហើយបោសសម្អាតខ្មាំងឲ្យអស់ពីក្នុងស្រុកទាំងមូលដាច់ខាត ។ បន្ទាប់ពីការធ្វើមីទ្ទីង អ៊ឹ អាន បានមកហូបបាយនៅផ្ទះ កាន ហើយពេលនោះគាត់និយាយជាមួយ កាន ថា "យើងនិយាយឃោសនាជាមួយប្រជាជន យើងនិយាយស្របច្បាប់ដូចជាបញ្ហាស្លូងស្រូវ បញ្ហាសកម្មភាពខ្មាំងលួចរត់ លួចដំណាំបន្តិចបន្តួចក្តី យើងលើកថា នេះជាសកម្មភាពខ្មាំងប្រឆាំងនឹងមាគ៌ា តែបើយើងអនុវត្តឲ្យក្តៅតែម្តងមិនបានទេ ។ ឥឡូវប្រជាជនកាន់តែយល់ ធ្វើខ្លាំងចំហមិនបានទេ ត្រូវស្របមាគ៌ាដែលអង្គការដាក់ទើបបាន តែមិត្ត កាន ឯងត្រូវចុះពិនិត្យតាមដានឃុំឲ្យបានញឹកញាប់ផង ក្រែងកម្មាភិបាលតាមឃុំយកផែនការទៅកប់ចោល ឬអនុវត្តពាសវាលពាសកាល នាំឲ្យអន្តរាយដល់ការងាររបស់យើង ត្រូវប្រយ័ត្នប្រយែង បើមិនប្រុងប្រយ័ត្នទេ គ្រោះថ្នាក់ធំហើយ" ។ បន្ទាប់មក អាន ក៏ត្រឡប់ទៅកន្លែងតំបន់ខ្លួនវិញ ។

នៅខែកក្កដា ឆ្នាំ១៩៧៧ កាន បានទៅធ្វើមីទីងនៅឃុំគាណើងមួយព្រឹក តែ ហឿន មិនបានចូលរួម ហើយក៏មិនដឹងថាខ្លឹមសារយ៉ាងម៉េចដែរ ។ តែដល់ពេល កានមកវិញ បានចាប់ប្រជាជនបីនាក់ មកជាមួយ ដែលមិនចូលរួមមីទីង ហើយ កាន បានឲ្យ ហឿន សរសេរសំបុត្របញ្ជូនទៅតំបន់ថា ប្រជាជនបីនាក់នេះ មិនទៅចូលរួមមីទីង ដោយពួននៅនឹងផ្ទះ ។ ហឿន ក៏ធ្វើតាមការណែនាំ ។ នៅខែកក្កដា ឆ្នាំ១៩៧៧នេះដែរ ឃើញសំបុត្រពីតំបន់ហៅ កាន ទៅប្រជុំនៅមន្ទីរតំបន់ ។ ពីរថ្ងៃក្រោយ កាន បានត្រឡប់មកវិញ ហើយបានប្រាប់ ហឿន ឲ្យសរសេរសំបុត្រហៅប្រធានឃុំមកប្រជុំ ឲ្យយកបញ្ជីប្រជាជនថ្មីមកផង ។ ហឿន បានសរសេរសំបុត្រហៅគណៈឃុំតាមការណែនាំ ។

នៅខែសីហា ការប្រជុំចាប់ផ្តើមនៅម៉ោង ៧ព្រឹក កាន បើកកម្មវិធីប្រជុំដោយលើកបញ្ហាពីរ មកនិយាយក្នុងអង្គប្រជុំមានៈ

ទី១) គណៈឃុំរាយការណ៍អំពីសកម្មភាពខ្មាំង គណៈឃុំរាយការណ៍ពីសភាពការណ៍ខ្មាំងនៅតាមមូលដ្ឋានថា ឥឡូវមានលេចចេញជាចលនាក្បាត់ចេញទៅស្រុកនានា និងសកម្មភាពលួច ហើយសកម្មភាពនេះត្រូវបានបោសសម្អាតជាបន្តបន្ទាប់ ។

ទី២) រាយការណ៍អំពីចំនួនប្រជាជនដែលមាន ។ ចំពោះបញ្ហាទី២ នៅចំនួនប្រជាជនថ្មីសរុបមក មាន២៣៩១នាក់ ។

បន្ទាប់មក កាន បានឡើងមានមតិ និងឯកភាពតាមសេចក្តីរាយការណ៍ដែលគណៈឃុំទាំងអស់បានលើកឡើង ។ តមកទៀត កាន បានយកផែនការរបស់តំបន់មកប្រកាសជូនអង្គប្រជុំ ដោយលើកថា ផែនការតំបន់ពេលនេះ មានបញ្ហាពីរគឺ ទី១) ប្រមូលប្រជាជន៧៥ បោសសម្អាត ហើយទី២) ផែនការនេះឲ្យហើយរយៈពេលបីខែ គឺដល់ខែវិច្ឆិកាឲ្យហើយ ។ កាន បានបញ្ជាក់អំពីគម្រោងផែនការនេះដូចតទៅៈ

កាលប្រមូលប្រជាជននេះត្រូវប្រើវិធីស្របច្បាប់ គឺយើងអប់រំថា ប្រជាជនថ្មី អង្គការត្រូវប្រមូលឲ្យទៅនៅភូមិរៀបចំថ្មី គឺប្រជាជនចាស់ដាក់ដោយឡែក ហេតុនេះ សូមបងប្អូនកុំមានសតិអារម្មណ៍អី ហើយសម្ភារផ្ទាល់ខ្លួនរៀបចំយកទៅជាមួយទាំងអស់ តែយកទៅបន្តបន្ទាប់ ហើយឃុំដែលនៅឆ្ងាយៗចាំកាណូតទៅដឹកឯឃុំនៅជិតដើរមក ចាំមកដល់ផ្សារពាមជីកងនេះ ចាំឲ្យនៅក្នុងផ្ទះថ្មយប់ឡើងឡានតំបន់មកយក ។ ដូច្នេះត្រូវរៀបចំឲ្យបានត្រឹមត្រូវល្អ ហើយស្ងាត់ស្ងៀម ម្យ៉ាងទៀតពេលដែលយើងឃោសនាអប់រំហើយប្រជាជនណាបំផុសចលនាត្រូវចាប់ក្បាម ហេតុនេះសូមមិត្តរៀបចំឲ្យតាមផែនការនេះ ។

ស្អែកឡើង កាន បានប្រាប់ ហឿន ឲ្យរាយការណ៍ចំនួនប្រជាជនថ្មី និងការរៀបចំផែនការរួចស្រេចហើយ ។ ហឿន បានរាយការណ៍ទៅ អ៊ឹ អាន (ហឿន ហៅ) តាមការណែនាំរបស់គាត់ ។

ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧៧ ហឿន បានឃើញសំបុត្រពីតំបន់មកឲ្យយកប្រជាជនថ្មីនេះចំនួន៥០០នាក់ កាន បានឲ្យ ហឿនសរសេរសំបុត្រទៅសុំគណៈឃុំព្រែកកុយ និងឃុំស្តៅរៀបចំប្រជាជន៥០០នាក់ ។ កាន បានយកកាណូត៣ទៅដឹកប្រជាជនទាំងនេះ ។ យប់ថ្ងៃ២៧ កាណូតបានមកដល់វិញ ពេលនោះឡានខាងតំបន់ក៏មក៤គ្រឿងដែរ ហឿន ក៏បានចូលរួមចងប្រជាជនទាំងនោះដាក់ឡានដែរ ។ ថ្ងៃ១៥ ខែកញ្ញា ឆ្នាំ១៩៧៧ សំបុត្រខាងតំបន់ឲ្យយក៥០០នាក់ទៀត គឺ យកឃុំកងតាណឹង និងរការអា ។ ថ្ងៃ២៥ ខែកញ្ញា ឆ្នាំ១៩៧៧ យក៥០០ទៀត គឺឃុំខ្ចៅ ឃុំសូគង និង ឃុំអង្គរបាន ។ ថ្ងៃទី២១ ខែតុលា សំបុត្រខាងតំបន់ឲ្យយក៥០០នាក់បន្ថែមទៀតគឺឃុំរាយប៉ាយ និងឃុំព្រែកក្របៅ ។ ថ្ងៃទី២២ ប្រជាជនបានមកដល់ ហឿន បានហៅប្រជាជនចូលក្នុងផ្ទះថ្ម ម៉ោងប្រហែល៧យប់ ឡានខាងតំបន់មកដល់ ហឿន បានចងប្រជាជនដាក់លើឡាន ហើយប្រមូលសម្ភារទុក ។ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ សំបុត្រតំបន់ឲ្យយកប្រជាជនដែលនៅសល់៣៩១នាក់បានទៅដល់ ហើយ ហឿន បានឲ្យសំបុត្រទៅឃុំរកាគយឲ្យនាំប្រជាជនមក ព្រោះដល់ពេលយកហើយ ។ ថ្ងៃ២៤ ប្រជាជនមកដល់ ហឿន ក៏នាំប្រជាជននេះទៅទុកកន្លែងផ្ទះថ្ម ពេលឡានមកដល់ ហឿន បានចងប្រជាជនដាក់លើឡាន ។ ហឿន បានបញ្ជាក់ថាផែនការប្រមូលប្រជាជនថ្មីទៅឲ្យសន្តិសុខតំបន់បោសសម្អាត បានចប់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ចំពោះប្រជាជនចម្រុះមិនថាសមាសភាពណាទេគឺឲ្យតែថ្មី ។

អំពីផែនការប្រមូលប្រជាជននេះ ហឿន បានចូលរួមចងប្រជាជនដាក់ឡាន ហើយឈ្មោះ កាន ជាអ្នកឈរបញ្ជានៅកន្លែងផ្ទាល់ ។ ពេលចងប្រជាជនមានអ្នកចូលរួម៥នាក់គឺ ឆឿន, គិន, ទន,

ម៉ែន និង សៅ ។ អ្នកទាំង៥នេះជាតែកុងកាណូត នៅមន្ទីរស្រុកកងមាស រួមជាមួយនីរសាររបស់ កាន ពីរនាក់ទៀត ។

នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ខាងតំបន់បានហៅ កាន ទៅប្រជុំនៅមន្ទីរតំបន់ ។ កាន បានទៅប្រជុំរយៈពេលមួយថ្ងៃ ហើយត្រឡប់មកវិញ ដោយប្រាប់ ហឿន ថាសភាពការណ៍មានការប្រែប្រួល ព្រោះយួនមានផែនការវាយកម្ពុជា ដូច្នេះអង្គការរើសទ័ពរើសយុវជនយកពីអាយុ១៧ទៅ ហើយ ហឿនក៏ត្រូវអង្គការតំបន់ស្នើទៅដែរ ។

យប់ឡើង កាន បានហៅ ហឿន ទៅប្រាប់ថា «ស្អែកនេះ មិត្តឯងរៀបចំទៅតំបន់ ព្រោះបង អាន ដកមិត្តទៅទ័ពតំបន់» ។ ស្អែកឡើង ហឿន ជិះឡានទៅតំបន់ ហើយក៏បានជួបនឹងឈ្មោះ អួន ប្រធានមន្ទីរតំបន់ ។ ពេលនោះ អាន មិននៅទេ គឺទៅប្រជុំនៅមន្ទីរភូមិភាគបាត់ទៅហើយ ។ ពេលល្ងាច អាន មកដល់ និងបានជួបសួរសុខទុក្ខ ហឿន ព្រមទាំងបានសួរ ហឿន ថា «មិត្តអាចកាន់ទ័ពបានទេ មួយរយពីររយនាក់? ហឿន ឆ្លើយថា «មិនយ៉ាងម៉េចទេ ខ្ញុំមិនធ្លាប់ដឹកនាំគេផង» ហើយ អាន ប្រាប់ថា «ឥឡូវរៀនសូត្រដកពិសោធន៍ទៅ» ។

រួចហើយថ្ងៃក្រោយ អ៊ឹ អាន (ហឿន ហៅ) បានរៀបចំចាត់តាំងកងទ័ពប្រចាំតំបន់៤១ មួយកងវរសេនាតូច មាន៣អនុសេនាធំ ។ អាន ប្រកាសចាត់កម្មាភិបាលប្រចាំតំបន់កងទ័ពមានៈ

១) អួន ជាប្រធានកងវរសេនាតូច និងទទួលប្រធានមន្ទីរតំបន់ផង ។ ឈ្មោះ អួន នេះ គឺនៅជាមួយ អាន ផ្ទាល់តែម្តង ។

២) ហឿន (ម្ចាស់ចម្លើយសារភាព) ជាបញ្ជាការកងវរសេនាតូច

៣) សុខ ជាអនុបញ្ជាការវរសេនាតូច ។ ឈ្មោះ សុខ នេះក៏ជាកម្លាំង និងនៅផ្ទាល់ជាមួយ អាន ម្នាក់ដែរ ។

ក្រោយប្រកាសចាត់តាំងហើយ អាន និយាយបន្តទៅកាន់ទ័ពថា «មិត្តជាកងទ័ព ជាឧបករណ៍ផ្តាច់ការ ត្រូវគោរពវិន័យឲ្យបានដាច់ខាត ប្រគល់ភារកិច្ចត្រូវតែធ្វើឲ្យបាន» ។

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៨ អាន បានហៅ ហឿន ទៅប្រជុំនៅមន្ទីរតំបន់៤១ ជាមួយកងវរៈទាំងបីនាក់ទៀត ដោយលើកឡើងថា អង្គការឲ្យតំបន់រៀបចំកម្លាំងលើកទំនប់មួយឈ្មោះ ទំនប់កំណើតឆ្នាំ១៧ របស់បក្សកុម្មុយនីស្តកម្ពុជា ។ តែត្រូវរៀបចំផែនការដើម្បីឲ្យទំនប់ស្ទះឃើតមិនហើយ តាមផែនការនៅតាមមូលដ្ឋាន ហឿន ឲ្យស្រុករៀបចំកម្លាំងមក តែកម្លាំងណាខ្សោយៗ ដូចជា អ្នកមានកូនតូចតាចក្តី ហើយទ័ពត្រូវយកមួយអនុសេនាធំទៅប្រចាំការកន្លែងនោះ ដើម្បីតាមដានប្រជាជនដែលគេចវេស ឈឺញ៉ឹក និយាយរឿងធ្វើការហត់នឿយ ឬគ្មានពេលសម្រាក ត្រូវចាប់បញ្ជូនទៅឲ្យ តាឈិន ដែល អាន បានចាត់តាំងឲ្យទទួលរួមនៅទំនប់ដើម្បីបញ្ជូនទៅសន្តិសុខតំបន់ ។ ចំពោះផែនការ គឺម្នាក់ៗក្នុងមួយថ្ងៃរែកដីឲ្យបានបីម៉ែត្រគូបកន្លះ បើធ្វើមិនបានក្នុងរយៈបីថ្ងៃត្រូវចាប់បញ្ជូនដែរ ឯតារាងឈ្មោះធ្វើមួយថ្ងៃ នៅលើតា ឈិន តា ឈិន ឲ្យចាប់មួយណាចាប់មួយហ្នឹង ។ ចំពោះបញ្ហាទាក់ទងធ្វើការនៅការដ្ឋានគឺមានទាក់ទងតាមរយៈគណៈកម្មាធិការមុខព្រួញ ដូចជាខាងសំណង់មានឈ្មោះ សៀន និងទី ។ ខាងមុខព្រួញទំនប់មានឈ្មោះ ដូ និងដួង ឯខាងមុខព្រួញសម្ភារមានឈ្មោះ សៅ និង ម៉ៅ ។ អ្នកទាំង៦នេះ អាន ចាត់តាំងហើយប្រកាសឲ្យនៅតាមការដ្ឋានប្រគល់ឲ្យនៅតាមមុខព្រួញ ដើម្បីឲ្យផែនការទៅអនុវត្តតាមផ្នែកមួយៗ ។

ខែមីនា ឆ្នាំ១៩៧៨ អាន បានទៅការដ្ឋានតំបន់ យប់ឡើងគាត់បានហៅឈ្មោះអ្នកដែលគាត់ចាត់តាំងនៅតាមមុខព្រួញមកប្រជុំទាំងអស់គ្នា ។ កិច្ចប្រជុំនោះនិយាយអំពីបញ្ហាបី គឺៈ

១) ស្នើមុខព្រួញរាយការណ៍

២) ផែនការរៀបចំបានយ៉ាងម៉េច?

៣) បញ្ហាធ្វើស្រែប្រាំង

ដើមខែមេសា ឆ្នាំ១៩៧៨ អាន បាន ហៅ ហឿន និង តាឈិន មកប្រជុំនៅកន្លែងគាត់នៅមន្ទីរតំបន់ ពេលនោះ ក៏មានវត្តមានឈ្មោះ អួន និង សុក មកប្រជុំដែរ ។ ការប្រជុំនេះ អាន បានលើកឡើងអំពីបញ្ហាពីរមានៈ

១) បញ្ហាបុណ្យខួប ១៧ មេសា គឺអង្គការឲ្យសម្រាកបីថ្ងៃបីយប់នៅការដ្ឋានតែម្តង មិនអនុញ្ញាតឲ្យទៅណានោះទេ ។

២) បញ្ហាបាយទឹកសម្រាប់ការដ្ឋាន គឺដាំបាយមួយពេល បបរមួយពេល កាប់គោជ្រូកតាមធម្មតា ។ ចំពោះកងទ័ពគឺត្រូវឃ្លាមការប្រជាជនមិនឲ្យគេចប្តូរត់ទៅផ្ទះ ឬអង្គុយប្រជុំគ្នា បើមានបាតុភាពទាំងនេះត្រូវ ចាប់ខ្លួនភ្លាមតែម្តង ។ **ឆាង សារៈមុនិន្ទ**

# យុវជនយុវនារីបដិវត្តន៍យើងយកចិត្តទុកដាក់វាយកម្ទាត់គោលជំហរគ្រប់គ្រាន់និយម ហើយខិតខំរៀនសូត្រកសាងខ្លួនឱ្យរីកចម្រើនជានិច្ច ដើម្បីប្រយុទ្ធនឹងខ្មាំងសត្រូវខ្លាំងក្លា ប្រយុទ្ធនឹងធម្មជាតិខ្លាំងក្លា ប្រយុទ្ធការពារប្រទេស កសាងប្រទេសក៏ខ្លាំងក្លា

*អត្ថបទដកស្រង់ចេញពីទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍ លេខ១០ ខែតុលា ឆ្នាំ១៩៧៨*

## ១) សភាពការណ៍បដិវត្តន៍កម្ពុជាបច្ចុប្បន្ន

រហូតមកទល់សព្វថ្ងៃនេះ បដិវត្តន៍កម្ពុជាយើងស្ថិតក្នុងសភាពការណ៍ល្អប្រសើរគ្រប់ផ្នែក ទាំងផ្នែកការពារប្រទេស ទាំងផ្នែកកសាងប្រទេស ទាំងក្នុងការដោះស្រាយ និងលើកស្ទួយជីវភាពប្រជាជនយើងឲ្យរីកចម្រើនឡើងជាលំដាប់ ។

ខាងផ្នែកការពារប្រទេស រហូតមកទល់ថ្ងៃនេះ ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា បានប្រយុទ្ធវាយកម្ទាត់ និងវាយកម្ទេចនូវរាល់សកម្មភាពវិទ្ធង្សនាប៉ុនប៉ងធ្វើរដ្ឋប្រហារ និងការវាយលុកឈ្លានពានដណ្តើមយកកម្ពុជាទៅវិញរបស់ខ្មាំងសត្រូវគ្រប់ទិសទី ។



រថក្រោះរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម កំពុងបើកតាមបាញ់កងទ័ពវៀតណាម នៅលើសមរភូមិ (រូបថត ៖ ឆ្នាំ១៩៧៨)

◆ នៅខាងលិច យើងបានវាយបំបាក់យុទ្ធសាស្ត្រ វាយដណ្តើមយកកម្ពុជាទៅវិញរបស់ពួកចក្រពត្តិនិយមដែលមានចក្រពត្តិអាមេរិកជាមេក្លោង និងបក្ខពួកវាឲ្យបរាជ័យ និងរលំរលាយលែងមានលទ្ធភាពវាយយើង ឬលេបយើងបានទៀត ។

◆ នៅខាងកើត យើងបានវាយបំបាក់ការវាយលុកឈ្លានពានរបស់ខ្មាំងយួន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ ដែលមានពួកវាតទីនិយមសូវៀតជួយគាំទ្រផង ឲ្យវាបរាជ័យរលំរលាយវិនាសខ្ចាត់ខ្ចាយអស់ពីលើទឹកដីយើងយ៉ាងអាម៉ាស់ កាលពីថ្ងៃ៦ មករា ១៩៧៨ និងនៅថ្ងៃជាបន្តបន្ទាប់មកទៀត ។

ដូច្នេះ យើងការពារកម្ពុជាប្រជាធិបតេយ្យ ការពារបក្សកុម្មុយនីស្តកម្ពុជា ការពាររដ្ឋអំណាចបដិវត្តន៍របស់វណ្ណៈកម្មករ កសិករ និងការពារជ័យផលបដិវត្តន៍បានទាំងស្រុង និងដោយម្ចាស់ការពេញទី ។ យើងការពារបានដោយម្ចាស់ការ ទាំងព្រំដែនគោក ទាំងព្រំដែនទឹក ទាំងដែនសមុទ្រ និងកោះ ។ យើងការពារដោយម្ចាស់ការបានទាំងព្រំដែនខាងលិច ទាំងព្រំដែនខាងកើត ។ ដូច្នេះ យើងម្ចាស់ការទាំងស្រុងក្នុងភារកិច្ចការពារប្រទេសកម្ពុជាប្រជាធិបតេយ្យរបស់យើង ។ យើងការពារនេះ ក្នុងឋានៈវាយសម្រុកទៅលើខ្មាំងសត្រូវគ្រប់ទិសទី ទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ច ទាំងការទូត ។ ដាក់ស្តែងក្នុងការវាយបំបាក់យុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់ខ្មាំងយួនវាតទីលេបទឹកដីយើង មិនត្រឹមតែវាយកម្ទេច និងវាយកម្ចាត់វាឲ្យបរាជ័យវិនាសខ្ចាត់ខ្ចាយ ខាងយោធាតែនៅលើសមរភូមិប្រយុទ្ធលើទឹកដីកម្ពុជាប៉ុណ្ណោះទេ តែការបរាជ័យរបស់វា ខាងយោធានៅលើសមរភូមិប្រយុទ្ធនេះ នៅបានជះបច្ច័យអាក្រក់ជាច្រើនទៅលើនយោបាយ យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ នៅក្នុងប្រទេសវាទៀត ។ ដូច្នេះ យើងបានវាយឲ្យខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី វាលំបាកលំបិនស្មុគស្មាញវណ្តុកដោះពុំរួច ហើយនឹងកាន់តែវិវត្តទៅកាន់តែលំបាកស្មុគស្មាញធ្ងន់ធ្ងរថែមទៀត ទាំងនយោបាយ យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ រហូតដល់រលំរលាយបាក់ស្រុបនៅទីចុងបំផុតមិនខានឡើយ ។ នៅលើឆាកអន្តរជាតិ ខ្មាំងយួន និងបក្ខពួកវាត្រូវបែកមុខស្អុយឈ្មោះអាសោច ថាជាអ្នកឈ្លានពានកម្ពុជា ។ ប្រជាជនសកលលោកដែលស្នេហាឯករាជ្យ សន្តិភាព យុត្តិធម៌ គេបរិហារថ្កោលទោសវាប្រឆាំងជំទាស់ការឈ្លានពានកម្ពុជារបស់វាកាន់តែខ្លាំងឡើងៗ នៅសព្វទិសទី ។ ដូច្នេះ ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី ស្ថិតក្នុងសភាពកាន់តែឯកោឡើងៗ នៅលើឆាកអន្តរជាតិ ។ ហើយតទៅទៀត យួន និងកាន់តែបាត់ឥទ្ធិពលឡើងថែមទៀត បើវានៅតែបន្តនយោបាយឈ្លានពានកម្ពុជាតទៅទៀត ។ ឯបដិវត្តន៍កម្ពុជាយើង កាន់តែវាយ កាន់តែឈ្នះ កាន់តែមានពិសោធ កាន់តែមានកម្លាំងខ្លាំងក្លាឡើង ហើយកាន់តែឈ្នះធំៗថែមទៀត ។ ព្រមជាមួយនេះ យើងកាន់តែដណ្តើមកម្លាំងមិត្តភក្តិនៅលើសកលលោកបានច្រើនថែមទៀត ក្នុងពេលដែលខ្មាំងយួនកំពុងតែបាត់បង់កម្លាំងថែមទៀតជាបន្តបន្ទាប់ ។ ជាទស្សនៈអនាគតបើបច្ចុប្បន្ន យួនលេបយើងមិនបានតទៅមុខទៀត ដែលយើងកាន់តែខ្លាំងឡើង យួនកាន់តែខ្សោយចុះ យួនរិតតែពិបាកលេបយើងរិតតែធ្វើអីយើងមិនបានទៅទៀត ។ នេះហើយជាមហាជ័យជម្នះរបស់យើង ខាងផ្នែកការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ។

ខាងកសាងប្រទេស ក្នុងរយៈពេលជាងបីឆ្នាំកន្លងទៅនេះ យើងបានប្រយុទ្ធស្តារសេដ្ឋកិច្ច កសាងប្រទេសបានរីកចម្រើនលោតផ្លោះលើគ្រប់ផ្នែក ទាំងខាងផ្នែកកសិកម្ម ទាំងខាងផ្នែកឧស្សាហកម្មសិប្បកម្ម ទាំងខាងផ្នែកសេដ្ឋកិច្ច សុខាភិបាល វប្បធម៌សិក្សាអប់រំ ។ មហាជ័យជម្នះដែលលេចធ្លោជាងគេ គឺខាងផ្នែកកសិកម្ម ពិសេសស្រូវស្រែ និងសំណង់ចាត់ចែងទឹក ។ ខាងសំណង់ចាត់ចែងទឹក រហូតមកដល់បច្ចុប្បន្ននេះ យើងអាចម្ចាស់ការលើបញ្ហាទឹកបានមួយកម្រិតសំខាន់ហើយ ។ យើងមានទំនប់អាងទឹកធំៗរាប់រយលានម៉ែត្រត្រីគុណនៅតាមគ្រប់ភូមិភាគ ។ យើងមានទំនប់អាងទឹកមធ្យម ចំណុះច្រើនសិបលានម៉ែត្រត្រីគុណ នៅតាមគ្រប់តំបន់ ហើយមានទំនប់អាងទឹកតូចៗ ចំណុះរាប់លាន ម៉ែត្រត្រីគុណ ស្អេកស្កះគ្រប់ទីកន្លែងនៅតាមគ្រប់ស្រុក និងគ្រប់សហករណ៍ទៀត ។ ក្រៅពីនេះ យើងមានប្រព័ន្ធភ្លឺស្រែថ្មី ខ្វាត់ខ្វែងជាក្រឡាឈើគ្រង់ មានព្រែកជីក ប្រឡាយតូចធំ វែងខ្លី តាំងពីច្រើនសិបគីឡូម៉ែត្រ រហូតដល់រាប់គីឡូម៉ែត្រ ខ្វាត់ខ្វែងកាត់ផ្ទៃស្រែនៃជនបទយើងពាសពេញ ធ្វើឲ្យជនបទកម្ពុជាយើងឥឡូវប្រែក្លាយពីសភាពក្រៀមក្រោះស្វិតក្រញង់ ទៅជាស្រស់បំព្រងខ្ពបប្រាំងខ្ពបវស្សា ។ ព្រមជាមួយនេះ យើងមានដីស្រែធ្វើម្តង និងដីស្រែធ្វើពីរដងក្នុងមួយឆ្នាំរាប់លានហិកតាទៀត ។

ដូច្នេះ រហូតមកទល់បច្ចុប្បន្ននេះ យើងមានស្រូវឧបត្ថម្ភខ្លួន

ដោយឯករាជ្យម្ចាស់ការ និងនៅមានសល់ស្រូវនាំចេញទៅលក់ក្រៅប្រទេសបានមួយចំនួនទៀតផង ។

ក្រៅពីដំណាំស្រូវ ដំណាំខស្បៀងហកម្ម ជាកៅស៊ូ ពោត សណ្ដែក កប្បាស ក្រចៅ អំពៅ ។ល ។ និងដំណាំឈើហូបផ្លែ បន្លែបន្ការសព្វសារពើ ក៏មានការរីកចម្រើនលោតផ្លោះនៅតាមគ្រប់ភូមិភាគ និងតំបន់ដែរ ។

ខាងផ្នែកខស្បៀងហកម្ម ក៏យើងបានរៀបចំដំណើរការប្រព័ន្ធខស្បៀងហកម្មស្រាល ដែលបម្រើកសិកម្ម និងបម្រើជីវភាពប្រជាជនបានជាខ្សែសង្វាក់ ហើយកំពុងតែរីកចម្រើនឡើងជាលំដាប់ ឥតឈប់ឈរទៀត ។ ទន្ទឹមនឹងនេះ នៅតាមគ្រប់សហករណ៍ សិប្បកម្មគ្រប់ផ្នែក (ឈើ ដែក តម្បាញ ។ល ។) ក៏មានការរីកចម្រើន លោតផ្លោះយ៉ាងឆាប់រហ័ស ដែលអាចដោះស្រាយសេចក្ដីត្រូវការនៅក្នុងសហករណ៍នីមួយៗ បានជាអតិបរមា និងដោយឯករាជ្យម្ចាស់ការ ។

ខាងវិស័យសង្គមកិច្ច សុខាភិបាល ក៏មានការរីកចម្រើនលោតផ្លោះជាទូទៅដែរ ។ នៅតាមគ្រប់ស្រុក គ្រប់សហករណ៍ យើងមានមន្ទីរពេទ្យ មានមន្ទីរផលិតថ្នាំជាតិ មានមណ្ឌលកុមារ និងទារកសម្រាប់ព្យាបាលជំងឺ និងថែទាំសុខភាពប្រជាជនយើង បានជិតដល់ជាប់ជាប្រចាំ ។ ការនេះធ្វើឲ្យប្រជាជនយើងមានសុខភាពកាន់តែមាំទាំល្អឡើងជាលំដាប់ អាចវាយសម្រុកបំពេញភារកិច្ចសព្វបែបយ៉ាងបានកាន់តែខ្លាំងក្លា ។

ខាងផ្នែកវប្បធម៌ សិក្សាអប់រំ ក៏ប្រជាជនយើងទាំងអស់មិនថា ស្រី ប្រុស ចាស់ឬក្មេងឡើយ សុទ្ធតែបានរៀនសូត្រវប្បធម៌ រៀនលេខ អក្សរ រៀនបច្ចេកទេសវិទ្យាសាស្ត្រ ជាបឋម និងរៀនសូត្រនយោបាយ បង្កើនសមត្ថភាពខ្លួន ជាលំដាប់លំដោយគ្រប់ៗគ្នា ។

តាមរយៈនៃការរីកចម្រើន លោតផ្លោះខាងផ្នែកកសាងប្រទេសគ្រប់ផ្នែកនេះ ជីវភាពប្រជាជនយើង ក៏ត្រូវបានលើកស្ទួយ និងរីកចម្រើនឡើងមួយកម្រិតខ្ពស់ថែមទៀត ។ បច្ចុប្បន្ននេះ ក្នុងរយៈតែជាងបីឆ្នាំក្រោយសង្គ្រាមមហាវិនាសកម្មប៉ុណ្ណោះ ដែលប្រទេសជាតិ និងប្រជាជនយើងត្រូវវិនាសហិនហោចខ្ទេចខ្ទាំគ្រប់ទិសទី ឥឡូវប្រជាជនយើងមានបាយហូបគ្រប់គ្រាន់តាមរបបបក្សកំណត់ មានជម្រកជ្រកនៅសមរម្យគត់ហ្មត់ មានសម្លៀកបំពាក់បិទបាំងកាយជិតសមរម្យ មានថ្នាំសង្កូវសម្រាប់ការពារ និងព្យាបាលជំងឺផ្សេងៗ ។ល ។

ទាំងនេះជាសភាពការណ៍ល្អប្រសើររបស់យើងខាងផ្នែកកសាងប្រទេស និងលើកស្ទួយជីវភាពប្រជាជន ។

សរុបមកវិញ ឃើញថាសភាពការណ៍បដិវត្តន៍កម្ពុជាយើងបច្ចុប្បន្ននេះ ស្ថិតក្នុងសភាពល្អប្រសើរគ្រប់ផ្នែក ទាំងអត្តនោម័តិ


ក្រោយពីវាយប្រយុទ្ធនៅលើសមរភូមិជាមួយកងទ័ពវៀតណាម កងទ័ពបដិវត្តន៍ និងយុទ្ធនារ

ទាំងសត្យានុម័តិ ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ ។

ប៉ុន្តែ ទន្ទឹមនឹងមហាជ័យជម្នះរបស់យើងទាំងអស់នេះ យើងក៏ត្រូវឃើញ សភាពលំបាកខាងផ្នែកខ្មាំងសត្រូវ ដែលវានៅតែបន្តនយោបាយ និងមហិច្ឆិតាលោភលន់ប៉ុនប៉ងវាយដណ្ដើមយកកម្ពុជាទៅធ្វើជារណបវាវិញជាប់ជាប្រចាំ ។

ចក្រពត្តិអាមេរិក ចាញ់យើងជាយុទ្ធសាស្ត្រហើយ តែវានៅតែបន្តវាយយើងតាមរូបភាពផ្សេងៗ ជាវិទ្ធ្វំសនកម្ម ជាចារកម្ម ជា

បំផ្លិចបំផ្លាញ ។ល ។ តទៅទៀត ។

ឯខាងខ្មាំងយួន ដែលមានពួកវាតទីនិយមសូវៀតគាំទ្រ វាត្រូវបរាជ័យជាបន្តបន្ទាប់ បែកមុខស្អុយអាសោចពាសពេញសកលលោក ហើយព្រមជាមួយនេះ វាមានការលំបាក ទាំងសេដ្ឋកិច្ច ទាំងនយោបាយ ទាំងយោធាជាងឆ្នាំមុនៗ ថែមទៀតក៏ពិតមែន តែវាក៏នៅតែបន្តវាយយើងតទៅទៀត ទាំងយោធា ទាំងនយោបាយ



រីកងចល័តនៅតាមព្រំដែន បានរួមគ្នាវាយសម្រុកច្រូតកាត់ និងប្រមូលផលស្រូវ

ទាំងសេដ្ឋកិច្ច ទាំងការទូត ។

យើងត្រូវឃើញសភាពលំបាកខាងខ្មាំងនេះជាប់ជាប្រចាំ មិនមែនដើម្បីខ្លាចខ្មាំង ឬវាយតម្លៃខ្មាំងខ្ពស់ហួសហេតុនោះទេ តែគឺដើម្បីយើងប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច ត្រៀមវាយកម្ទេចនូវការវាយលុកឈ្លានពានរបស់វា ឲ្យបានម្ចាស់ការជាមុនស្រេចគ្រប់ពេលវេលា ។

ព្រមជាមួយ និងភារកិច្ចការពារប្រទេសយ៉ាងមមាញឹកនេះ យើងក៏ត្រូវវាយសម្រុកកសាងប្រទេសឲ្យខ្លាំងក្លាបំផុត ឲ្យលឿនមហាលោតផ្លោះ ម្យ៉ាងដើម្បីកុំឲ្យខ្មាំងតាមទាន់ កុំឲ្យវាអាចលូកដៃលូកជើងមកដល់យើងបាន ។ តែម្យ៉ាងទៀត យើងខំកសាងប្រទេសឲ្យលឿន ឲ្យខ្លាំង ក៏ដើម្បីការពារប្រទេសឲ្យខ្លាំង និងកាន់តែស័ក្តិសិទ្ធិថែមទៀត ។ ដូច្នេះ ក្នុងសភាពការណ៍ថ្មីនេះ ដើម្បីវាយសម្រុកការពារប្រទេសឲ្យបានខ្លាំងក្លា កសាងប្រទេសក៏ឲ្យបានលឿនលោតផ្លោះ មិត្តយុវជន យុវនារីបដិវត្តន៍ យើងក៏ដូចជាប្រជាជនយើងទូទាំងប្រទេសដែរ ត្រូវវាយសម្រុកធ្វើការងារទ្វេមួយជាពីរ ជាបី ជាបួនដង ។ យើងពុំអាចធ្វើក្នុងសន្ទាក់ធម្មតា បែបសន្តិភាពនិយម កសាងនិយមបានឡើយ ។ ដើម្បីវាយសម្រុកធ្វើការងារបានខ្លាំងក្លាតាមសំណូមពរខាងលើនេះ យុវជន យុវនារីបដិវត្តន៍យើងត្រូវមានសមត្ថភាពបដិវត្តន៍គ្រប់ផ្នែក កាន់តែខ្ពង់ខ្ពស់ឡើងជានិច្ច ។ សមត្ថភាពបដិវត្តន៍ខ្ពង់ខ្ពស់នេះគឺ ខាងគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងបដិវត្តន៍រឹងប៉ឹងគ្រប់ផ្នែក សមត្ថភាពការងារក៏ឈ្លាសវៃច្នៃប្រឌិតគំនិតផ្តើមរស់រវើក និងសន្សំបែខ្ពស់ជាប់ជានិច្ច សមត្ថភាពវប្បធម៌ បច្ចេកទេស-វិទ្យាសាស្ត្រ ក៏រីកចម្រើន និងកាន់តែខ្ពង់ខ្ពស់ឡើងជាលំដាប់ ។

ដើម្បីបង្កើនសមត្ថភាពបដិវត្តន៍ គ្រប់ផ្នែកយ៉ាងនេះបាន យុវជនយុវនារីបដិវត្តន៍យើង ចាំបាច់យកចិត្តទុកដាក់ខិតខំរៀនសូត្រជារួមក្តី រៀនសូត្រតាមបុគ្គលក្តី រៀនសូត្រក្នុងចលនាជាក់ស្តែងក្តី ឲ្យបានទៀតទាត់ ហ្មត់ចត់ជាប់ជាប្រចាំ ។

## ២) កម្ចាត់គោលជំហរគ្រប់គ្រាន់និយមដាច់ខាត

ក្នុងចលនាបដិវត្តន៍សង្គមនិយមបច្ចុប្បន្ននេះ និយាយរួមមិត្តយុវជន យុវនារីបដិវត្តន៍យើងបានហ៊ឹកហ៊ឺនលត់ដំកសាងខ្លួនក្នុងចលនាមហាជនបានល្អ ហើយកសាងខ្លួនរីកចម្រើនឆាប់រហ័សណាស់ គឺរីកចម្រើនទាំងខាងគោលជំហរនយោបាយ រីកចម្រើនទាំងខាងគោលជំហរសតិអារម្មណ៍អធនរបស់បក្ស រីកចម្រើនទាំងខាងគោលជំហរចាត់តាំង ហើយបង្កើនបានទាំងសមត្ថភាពការងារបដិវត្តន៍ តូចធំ សព្វសារពើ ។ ព្រមជាមួយនេះ យុវជន យុវនារីបដិវត្តន៍យើង ក៏បានយកចិត្តទុកដាក់ខិតខំរៀនលេខអក្សរ និងរៀនសូត្របច្ចេកទេសវិទ្យាសាស្ត្រផ្សេងៗ បង្កើនសមត្ថភាពខ្លួនបានយ៉ាងឆាប់រហ័ស ។ ដូច្នេះមិត្តយុវជន យុវនារីបដិវត្តន៍យើង បានរួមប្រយុទ្ធ

វាយកម្ទេចខ្មាំងនៅសមរភូមិមុខក៏ខ្លាំងក្លា រួមប្រយុទ្ធបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងក៏បានស្អាត ហើយរួមវាយសម្រុកបង្កបង្កើនផលសព្វបែបយ៉ាង ក៏ក្លៀវក្លាស្វាហាប់ ។ ព្រមជាមួយនេះ មិត្តយុវជន យុវនារីបដិវត្តន៍យើងមួយចំនួន ក៏បានទទួលនាទីដឹកនាំនៅតាមអង្គភាព និងផ្នែកការងារផ្សេងៗជាបន្តបន្ទាប់ ហើយបានប្រកាន់តួនាទីដឹកនាំរបស់បក្សបានល្អ រឹងប៉ឹង ខ្លាំងក្លា និងមានប្រសិទ្ធភាពកាន់តែខ្ពស់ឡើងដែរ ។

ប៉ុន្តែ ទន្ទឹមនឹងគុណសម្បត្តិជាមូលដ្ឋានខាងលើនេះ ក៏នៅមានមិត្តយុវជន យុវនារីបដិវត្តន៍យើងមួយចំនួន (ចំនួនតិចទេ) មិនត្រឹមតែមិនបានកសាងខ្លួនឲ្យរីកចម្រើនលោតផ្លោះ ទៅតាមមហាចលនាបដិវត្តន៍របស់មហាជនប៉ុណ្ណោះទេ តែនៅមានសភាពយឺតយ៉ាវ ហើយខ្លះទៀតរហូតដល់ធ្លាក់ថយចុះវិញផង ។

មូលហេតុនៃការកសាងខ្លួន មិនបានចម្រើនលូតលាស់ទៅមុខ ឬក៏មានសភាពយឺតយ៉ាវនេះមានច្រើន ។ ប៉ុន្តែមូលហេតុសំខាន់ខាងសតិអារម្មណ៍ គឺមកពីមានគោលជំហរគ្រប់គ្រាន់និយម ។

ឧទាហរណ៍ទី១ៈ មានមិត្តយុវជន យុវនារីយើងខ្លះ មានមតិថា «បើឲ្យធ្វើការងារជាក់ស្ដែង ធ្វើអីក៏ធ្វើដែរ ធ្វើច្រើនប៉ុណ្ណាក៏ធ្វើបានដែរ តែបើឲ្យខ្ញុំរៀនសូត្រដូចជាទៅមិនរួចទេ ព្រោះពិបាកគិតគួរណាស់» ។ មិត្តយើងនិយាយយ៉ាងនេះត្រូវម្យ៉ាង តែខុសជាមូលដ្ឋាន ព្រោះបើធ្វើតែការងារជាក់ស្ដែង មិនរៀនសូត្រទ្រឹស្ដីនយោបាយសតិអារម្មណ៍ចាត់តាំងរបស់បក្សយើងគ្មានពន្លឺទេ ។ មិនដឹងជាធ្វើយ៉ាងម៉េចខុស មិនដឹងជាធ្វើយ៉ាងម៉េចត្រូវ ។ ហើយជួនកាល ធ្វើខុសហើយក៏មិនដឹង ធ្វើត្រូវហើយក៏មិនដឹង ។ ដូច្នេះ ដកពិសោធកែលម្អលើការងារជាក់ស្ដែងមិនបានឬមិនបានត្រឹមត្រូវ ។ ដូច្នោះ ធ្វើម៉េចនឹងជំរុញការងារជាក់ស្ដែងបានលឿន បានខ្លាំងក្លាទៅរួច ។ ហើយបើយើងចេះតែធ្វើ ធ្វើដោយពុំបានដកពិសោធកែលម្អ បង្កើនការត្រូវបន្ថយការខុសឆ្គងឲ្យបានជាអតិបរមាទេ យូរៗទៅមុខជាស្ទះ មុខជាខ្មោងនឹងតែរកច្រកចេញពុំរួចឡើយ ។ ដូច្នេះ មិត្តយើងនឹងធ្លាក់ទៅក្នុងទុទិដ្ឋិនិយមអស់សង្ឃឹមរហូតដល់បាត់ទិសការងារ ក្ដាប់ភារកិច្ចមិនជុំ ទីចុងបំផុតក៏សុំដកខ្លួនថយចេញពីភារកិច្ចនេះ ។

ដូច្នេះ ដើម្បីធ្វើការងារជាក់ស្ដែង សម្រេចភារកិច្ចបដិវត្តន៍បានខ្លាំងក្លា និងលឿនឆាប់រហ័ស ហើយបម្រើចលនាបដិវត្តន៍បានកាន់តែសក្តិសិទ្ធ មិត្តយុវជន យុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវរៀនសូត្រទ្រឹស្ដី ជាមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំងរបស់បក្សឲ្យជាប់ជាប្រចាំ ដើម្បីជាពន្លឺឆ្លុះបញ្ចាំងមើលការអនុវត្តភារកិច្ចប្រចាំថ្ងៃរបស់យើងជាប់ជានិច្ច ។ ធ្វើយ៉ាងនេះ ទើបមិត្តយើងរីកចម្រើនទាំងទស្សនៈគោលជំហរ ទាំងការយល់ដឹង ទាំងសមត្ថភាពការងារកាន់តែខ្ពង់ខ្ពស់ថែមទៀត ។

ឧទាហរណ៍ទី២ៈ មិត្តយើងខ្លះមានទស្សនៈថា «ខ្លួនចេះដឹងល្មមគ្រប់គ្រាន់ហើយ ព្រោះជាប់ចលនាបដិវត្តន៍គ្រប់ជំនាន់យូរមកហើយ មិនចាំបាច់រៀនសូត្រអីច្រើនទៀតទេ ព្រោះមាគ៌ារបស់បក្សជាមូលដ្ឋាន គឺត្រឹមត្រូវដដែល ។ បើខ្មាំងពីសម័យបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ មកសម័យបដិវត្តន៍សង្គមនិយម កសាងសង្គមនិយមបច្ចុប្បន្ននេះ ក៏នឹងនៅតែខ្មាំងទៀត ព្រោះបានឆ្លងកាត់សម័យមុនដែលតឹងតែងស្លាប់រស់ជាង ក៏យើងនៅតែប្រយុទ្ធធ្វើបាន ។ ដូច្នេះសម័យឥឡូវរឹតតែធ្វើបានណាស់ទៅទៀត» ។

មិត្តយើងយល់យ៉ាងនេះ ក៏ត្រូវមួយជ្រុងដែរ តែក៏ខុសជាមូលដ្ឋាន ព្រោះចលនាបដិវត្តន៍ពីជំនាន់មុនក៏ដូចជាជំនាន់ឥឡូវ ចេះតែវិវត្តទៅមុខលឿនស្ទើរឥតឈប់ឈរ ។ ដូច្នេះ លេចចេញពិសោធថ្មីៗជាបន្តបន្ទាប់ឥតឈប់ឈរ ។ បើសិនជាមិត្តយើងមិនរៀនសូត្រមាគ៌ា មិនរៀនសូត្រពីចលនា មិនដកពិសោធលើការងារជាបន្តបន្ទាប់ទេ នោះមិត្តយើងអាចដាច់ពីចលនា អាចតាមចលនាមិនទាន់ ។ ដូច្នេះមិនយល់ចលនាបដិវត្តន៍ថ្មីៗទេ ។

ឧបមា ពីសម័យបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ យើងវាយខ្មាំងជាចក្រពត្តិអាមេរិក បរិវារ និងពួកអាក្បត់ជាតិ លន់ នល់ ដើម្បីរំដោះជាតិ និងរំដោះប្រជាជន ។ ប៉ុន្តែក្នុងសម័យបន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសបច្ចុប្បន្ននេះ យើងនៅតែវាយខ្មាំងទៀត ប៉ុន្តែវាយខ្មាំងណាសំខាន់ជាងគេ? គឺវាយខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដីបំបាត់ពូជសាសន៍ ដើម្បីការពារទឹកដី ការពារប្រទេសជាតិ ការពារជ័យផលបដិវត្តន៍ ។ល ។ តែបើយើងមិនរៀនសូត្រមាគ៌ារបស់បក្ស មិនរៀនសូត្រពីចលនាមហាជនទេ យើងវាយខ្មាំងមិនចំខ្មាំងសត្រូវដែលមានគ្រោះអាសន្នបំផុតនោះឡើយ ។ វាយទៅប៉ះតែអាបន្ទាប់បន្សំ ។ ដូច្នេះនាំឲ្យប៉ះពាល់ដល់ការប្រមូលកម្លាំង ហើយក៏ប៉ះពាល់ដល់កិច្ចការពារប្រទេសពុំខាន

ឡើយ ។ ដូច្នេះ ខ្ញុំផងយួនដែលចាំតែឱកាសចាំតែយើងប្រហែស នឹងអាលលោតសង្គ្រប់ត្របាក់លេបយើង នោះវានឹងសម្រេចសំណូមពរវាមិនខានឡើយ ។ ដូច្នេះ គ្រោះថ្នាក់ធំណាស់ដែលបណ្តាលមកពីទស្សនៈគ្រប់គ្រាន់និយម ខ្ជិលរៀនសូត្រ ខ្ជិលតាមដានចលនាបដិវត្តន៍របស់មហាជន ។

ឧទាហរណ៍ទី៣ៈ មានមិត្តយុវជន យុវនារីបដិវត្តន៍យើងខ្លះទៀតយល់ថា «ឥឡូវប្រទេសជាតិយើងបានរំដោះហើយ យើងឯករាជ្យហើយ យើងសន្តិភាពហើយ ទៅគិតគូររវល់អីច្រើន គិតតែពីកសាងប្រទេសទៅបក្សឲ្យធ្វើអីធ្វើហ្នឹងទៅ ចាំបាច់ទៅរៀនសូត្រធ្វើអី យើងគ្មានទៅចង់ឡើងធ្វើជាអ្នកធំដូចមុនទៀតទេ» ។

បើនិយាយជាគោលជំហរ គោរពអង្គការវិន័យដោយឥតលក្ខខណ្ឌឃើញថាមិត្តយើងល្អ គោរពជឿជាក់លើការដឹកនាំរបស់បក្ស ទោះបីបក្សចាត់តាំងឲ្យធ្វើអីក៏ធ្វើដែរ គ្មានសតិអារម្មណ៍ស្មុគស្មាញអីទេ ។ ប៉ុន្តែ តើបក្សនៅឯណា គឺនៅលើបក្ខជនមួយរូបៗ នៅលើកម្មាភិបាលមួយរូបៗ ដែលទទួលខុសត្រូវនៅតាមគ្រប់អង្គភាពទូទាំងប្រទេស ហើយលើសពីនេះទៅទៀត អ្នកដែលអនុវត្តភារកិច្ចការពារប្រទេសកសាងប្រទេសបានខ្លាំងក្លា ឬមិនខ្លាំងក្លាក៏អាស្រ័យនៅលើមហាជនទាំងអស់ នៅលើមិត្តយុវជនយុវនារីបដិវត្តន៍យើងរាល់រូបដែលធ្វើការនៅតាមគ្រប់អង្គភាព គ្រប់មូលដ្ឋាននេះហើយ ។ បើមិត្តយើងដែលជាអ្នកអនុវត្តភារកិច្ចនៅគ្រប់ទិសទី មិនរៀនសូត្រឲ្យជ្រួតជ្រាបមាគ៌ាគ្រប់ផ្នែករបស់បក្សទេ នោះអនុវត្តភារកិច្ចតូចក្តីធំក្តី ក៏មិនបានខ្លាំងក្លាដែរ ហើយមិនត្រឹមតែមិនខ្លាំងក្លា អាចធ្វើខុសជាបន្តបន្ទាប់ទៀត ដែលជាហេតុនាំឲ្យទទួលគ្រោះថ្នាក់ ឬរហូតដល់ទទួលបរាជ័យថែមទៀតផង គឺចំពោះខ្លួនក៏គ្មានការរីកចម្រើន ចំពោះភារកិច្ចបដិវត្តន៍ ក៏អាចស្ទះគាំង ។ ដូច្នេះសម្រេចភារកិច្ចបដិវត្តន៍មិនបានល្អ មិនបានលឿនទេ ។

ឧទាហរណ៍ទី៤ៈ មានមិត្តយុវជនយុវនារីយើងខ្លះ មានទស្សនៈថា «ខ្ញុំរួមធ្វើបដិវត្តន៍វាយរំដោះប្រទេសជាតិ រំដោះប្រជាជនហើយជាការស្រេច ។ ឥឡូវបានឯករាជ្យហើយ ខ្ញុំអត់ចង់បានអីទៀតទេសុំតែកសាងគ្រួសារ មានប្តី មានប្រពន្ធ មានកូនហើយជាការស្រេច ។ ខ្ញុំគ្មានចង់ឡើងធ្វើធំអីទៀតទេ ។ ដូច្នេះចាំបាច់រៀនសូត្រធ្វើអីទៀត» ។ នៅក្នុងបដិវត្តន៍មិនចោទពីបញ្ហាធ្វើធំ ធ្វើតូចអីទេ ។ វាចោទតែភារកិច្ចដែលប្រទេសជាតិ ប្រជាជន និងបក្សប្រគល់ជូនប៉ុណ្ណោះ ។ គឺសម្រេចបានឬមិនបាន?

ពីមុនយើងប្រយុទ្ធ វាយកម្រេចខ្មាំងជាចក្រពត្តិអាមេរិកបរិវារ និងពួកអាក្បត់ លន់ នល់ ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជន ។ ឥឡូវយើងរំដោះប្រទេសជាតិ រំដោះប្រជាជនបានយើងដណ្តើមបានឯករាជ្យ១០០ភាគរយហើយ វាចោទបញ្ហាថាតើការពារបានឬមិនបាន? ក្នុងឋានៈ យើងជាកុលបុត្រ កុលធីតាកម្ពុជា យើងអាចឆ្លើយភ្លាមថា ត្រូវតែការពារឲ្យបានដាច់ខាត ។ មិនត្រឹមតែការពារឲ្យបានគង់វង្សស្ថិតស្ថេរជារៀងរហូតប៉ុណ្ណោះទេ តែត្រូវវាយសម្រុកកសាងប្រទេសជាតិយើងឲ្យរីកចម្រើនលោតផ្លោះ ដើម្បីឈានទៅសម្បូរសប្បាយថ្កុំថ្កើនរុងរឿងយ៉ាងឆាប់បំផុត ។ នេះជាភារកិច្ចដ៏ធ្ងន់ធ្ងរតែឧត្តុង្គឧត្តមថ្លៃថ្លាបំផុតរបស់យើងជាកុលបុត្រកុលធីតាគ្រប់រូប ។ ដើម្បីសម្រេចភារកិច្ចនេះបានជោគជ័យ យើងត្រូវប្រយុទ្ធពុះពារឧបសគ្គតូចធំគ្រប់បែបយ៉ាង ជម្នះលើការលំបាក និងការខ្វះខាតសព្វគ្រប់ ហើយយកឈ្នះលើខ្មាំងសត្រូវគ្រប់ទិសទីឲ្យបានដាច់ខាតដើម្បីប្រយុទ្ធដណ្តើមបានជ័យជម្នះយ៉ាងនេះ យុវជន យុវនារីបដិវត្តន៍យើង ចាំបាច់រៀនសូត្របង្កើនសមត្ថភាពខ្លួនជាប់ជានិច្ច ហ៊ឹកហ៊ឺនខ្លួនក្នុងចលនាបដិវត្តន៍របស់មហាជនកសាងពង្រឹងពង្រីកគោលជំហរបដិវត្តន៍គ្រប់ផ្នែករបស់ខ្លួន ឲ្យរឹងប៉ឹងឡើងជាលំដាប់ ។ល ។

ដូច្នេះ សរុបមកវិញ ក្នុងកាលៈទេសៈណាក៏ដោយ ហើយទោះបីយើងមានឋានៈជាអ្វីក៏ដោយ យុវជន យុវនារីបដិវត្តន៍យើងសុទ្ធតែមានភារកិច្ច ដែលត្រូវបំពេញជូនប្រទេសជាតិប្រជាជន ជូនបក្ស និងវណ្ណៈក្រីក្រយើងជារៀងរហូត ។ ចលនាបដិវត្តន៍ពីរយៈកាលមួយទៅរយៈកាលមួយទៀត ពីមួយឆ្នាំទៅមួយឆ្នាំ ពីមួយខែទៅមួយខែ ចេះតែវិវត្តន៍ទៅមុខជានិច្ច ហើយវិវត្តន៍លឿនស្ទើរទៀតផង ។ ដូច្នេះ ពិសោធថ្មីៗ ក៏លេចចេញជាបន្តបន្ទាប់ ចំណេះវិជ្ជាបដិវត្តន៍ថ្មីៗ ប្លែកៗក៏ផុសចេញជាបន្តបន្ទាប់ជាប់ជាប្រចាំ ។ ដូច្នេះបើមិត្តយុវជន យុវនារីយើងមិនយកចិត្តទុកដាក់រៀនសូត្រ ដកពិសោធពីចលនាបដិវត្តន៍របស់មហាជន និងពីការងារប្រចាំថ្ងៃរបស់ខ្លួនជាប់ជាប្រចាំទេ នោះយើងអាចមិនយល់ចលនា តាមចលនាមិនទាន់ ហើយចង់ឬមិនចង់ គឺដាច់ពីចលនា ធ្លាក់ពីចលនាហើយ

ព្រោះតាមច្បាប់សម្ភារអ្វីៗទាំងអស់សុទ្ធតែវិវត្ត បើមិនវិវត្តទៅមុខគឺវិវត្តថយក្រោយ ។ ដូច្នេះគ្មានអ្វីនៅហ្នឹងថ្កល់ទេ ។ ឯខ្លួនយើងក៏មិននៅហ្នឹងថ្កល់ដែរ បើមិនរីកចម្រើនទៅមុខបានសេចក្តីថា យើងធ្លាក់ថយក្រោយហើយ ។ ដូច្នេះ ទស្សនៈគ្រប់គ្រាន់និយម មិនត្រឹមត្រូវតាមច្បាប់សម្ភារឡើយ ។ គ្រប់គ្រាន់និយមគឺនៅហ្នឹងថ្កល់ ។ បើច្បាប់សម្ភារថាគ្មានអ្វីនៅហ្នឹងថ្កល់ ដូច្នេះគ្រប់គ្រាន់និយម បានសេចក្តីថា ថយក្រោយហើយ ។

នៅក្នុងចលនាបដិវត្តន៍យើង គ្មានអ្វីគ្រប់គ្រាន់និយមទេ ព្រោះចលនាបដិវត្តន៍ ចេះតែវិវត្តន៍ទៅមុខជានិច្ច ហើយជនបដិវត្តន៍គ្រប់រូប ត្រូវតែប្រយុទ្ធទៅមុខជានិច្ច ដើម្បីពុះពារជម្នះឧបសគ្គតូចធំគ្រប់បែបយ៉ាង ទាំងឧបសគ្គធម្មជាតិ ទាំងឧបសគ្គក្នុងការងារបច្ចេកទេស ទាំងឧបសគ្គជាខ្មាំងត្រូវ ទាំងឧបសគ្គខាងសតិអារម្មណ៍ ។ យុវជនយុវនារីបដិវត្តន៍យើង ត្រូវពុះពារយកឈ្នះលើឧបសគ្គទាំងប៉ុន្មានខាងលើនេះ ជាបន្តបន្ទាប់ ទើបឈានទៅមុខបានលឿនលោតផ្លោះ ។ ដើម្បីយកឈ្នះលើឧបសគ្គ ទាំងនេះបាន យុវជន យុវនារីបដិវត្តន៍យើងត្រូវប្រយុទ្ធរៀនសូត្រ ជារៀងរហូត គ្មានពេលណាចប់ឡើយ គ្មានពេលណាថាគ្រប់គ្រាន់បានឡើយ ។ ដូច្នេះ នៅក្នុងចលនាបដិវត្តន៍យើង ពាក្យគ្រប់គ្រាន់និយម បានន័យថា ចុះចាញ់និយម សារភាពនិយម សម្ញុំសុខ ។ យុវជន យុវនារីបដិវត្តន៍យើង មិនត្រូវយកពាក្យនេះមកប្រើប្រាស់សម្រាប់ខ្លួន ហើយក៏រឹតតែមិនត្រូវមានទស្សនៈគោលជំហរគ្រប់គ្រាន់និយមឡើយ ។

មិត្តយុវជន យុវនារីបដិវត្តន៍ទាំងឡាយ មិត្តកំពុងស្ថិតក្នុងវ័យយុវភាព ដែលប្រៀបដូចបុប្ផាកំពុងរីកស្គុះស្គាយ ។ ក្នុងវ័យយុវភាពនេះ មិត្តកំពុងអង់អាចក្លៀវក្លាណាស់ ។ ខ្លាំងក្លាទាំងកម្លាំងកាយ ក្លៀវក្លាទាំងកម្លាំងចិត្ត ហើយមានសតិបញ្ញាក៏ឈ្លាសវៃឆាប់ក្តាប់បានឆាប់ក្រេបជញ្ជក់បាននូវអ្វីៗដែលជាធាតុថ្មី ។ ដូច្នេះ មិត្តមិនត្រូវបណ្តែតបណ្តោយឲ្យវ័យយុវភាពនេះ កន្លងផុតហួសទៅដោយឥតប្រយោជន៍ឡើយ ។ មិត្តត្រូវយកចិត្តទុកដាក់ខិតខំរៀនសូត្រកសាងខ្លួន ឲ្យបានរីកចម្រើនរឹងប៉ឹងខ្លាំងក្លាឡើងជានិច្ច ដើម្បីវាយសម្រុកសម្រេចភារកិច្ច ការពារប្រទេសឲ្យបានខ្លាំងក្លា កសាងប្រទេសក៏ឲ្យបានខ្លាំងក្លា និងឆាប់រហ័យ ។

## តើរៀនសូត្រអំពីអ្វី?

១) រៀនសូត្រមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ មាគ៌ាចាត់តាំងរបស់បក្ស ។ រៀនសូត្រ តាមសាលា តាមវគ្គវែងខ្លី ឬរៀនសូត្រជាបុគ្គលដោយអានឯកសារនៅពេលទំនេរពីភារកិច្ចស្នូលក្តី ។

២) រៀនសូត្រតាមការដកពិសោធ លើការងារជាក់ស្តែងប្រចាំថ្ងៃ ឬឆ្លុះបញ្ចាំងមើលខ្លួន យើងទៅជាមួយនិងមហាចលនាបដិវត្តន៍របស់មហាជន ដែលកំពុងផុសផុលសន្ធោសន្ធៅនៅគ្រប់ទីកន្លែង ។

៣) រៀនសូត្រ វប្បធម៌ លេខ អក្សរ ដើម្បីបង្កើនសមត្ថភាពវប្បធម៌ឲ្យខ្លួនខ្ពស់ឡើងជានិច្ច ដើម្បីឈានទៅយល់មាគ៌ាគ្រប់ផ្នែករបស់បក្ស និងដើម្បីឈានទៅក្រេបជញ្ជក់វិជ្ជា បច្ចេកទេសវិទ្យាសាស្ត្រសព្វសារពើដើម្បីវាយសម្រុកបំពេញភារកិច្ចការពារប្រទេស និងកសាងប្រទេសឲ្យបានកាន់តែល្អ កាន់តែខ្លាំងក្លាឡើងជានិច្ច ។

៤) រៀនសូត្របច្ចេកទេសវិទ្យាសាស្ត្រផ្សេងៗ ដែលនិយមនៅកម្ពុជាយើង ហើយដែលប្រទេសជាតិយើងត្រូវការចាំបាច់ ទោះជាបច្ចេកទេស លើកទំនប់ ធ្វើភ្លឺក្តី បច្ចេកទេសបង្កបង្កើនផលក្តី បច្ចេកទេសវាយកម្ទេចខ្មាំងក្តី បច្ចេកទេសរោងចក្រម៉ាស៊ីន និងគ្រឿងចក្រតូចធំក្តី បច្ចេកទេសពេទ្យក្តី បច្ចេកទេសសំណង់ក្តី រហូតដល់បច្ចេកទេសដាំស្ល ចិញ្ចឹមថែទាំទារក ថែទាំកុមារ ។ល ។

វិជ្ជាទាំងអស់នេះ សុទ្ធតែមានសារសំខាន់ខ្ពង់ខ្ពស់ណាស់ ក្នុងកិច្ចការពារប្រទេស ក៏ដូចក្នុងកិច្ចកសាងប្រទេសយើងដែរ ។ បើមិត្តយុវជនយុវនារីបដិវត្តន៍យើងគ្រប់រូប ខិតខំរៀនសូត្រសព្វវិជ្ជា ជាប់ជាប្រចាំយ៉ាងនេះ នោះគោលជំហរបដិវត្តន៍គ្រប់ផ្នែករបស់មិត្តយើងក៏នឹងចេះតែបានពង្រឹងពង្រីកឡើងជាលំដាប់ សមត្ថភាពការងារគ្រប់ផ្នែក ក៏នឹងចេះតែបានបង្កើនឡើងជាប់ជានិច្ច ហើយមិត្តយើង ក៏នឹងមានពិសោធថ្មីៗជាបន្តបន្ទាប់ទៀតដែរ ។ ដូច្នេះ មិត្តយើងអាចបំពេញភារកិច្ចអ្វីក៏បានសម្រេចជោគជ័យ ការពារប្រទេសក៏ខ្លាំងក្លា កសាងប្រទេសក៏ខ្លាំងក្លានិងលឿនលោតផ្លោះ ។ តាមរយៈនេះ កម្ពុជាប្រជាធិបតេយ្យយើងពិតជានឹងសម្បូរសប្បាយថ្កុំថ្កើងរុងរឿង ហើយស្ថិតស្ថេរចេរកាលក្នុងឯករាជ្យ អធិបតេយ្យ ក្នុងកិត្តិយសឧត្តុង្គឧត្តមថ្លៃថ្លា និងក្នុងក្របខ័ណ្ឌនៃបូរណភាពដែនដីដ៏ពិសិដ្ឋរបស់យើងជារៀងរហូតទៅ ។

**ឆេង ទ៉េង**

# ប្រវត្តិ និងសកម្មភាពសង្ខេបរបស់ សោ ភឹម លេខាភូមិភាគបូព៌ា


សោ ភឹម

សោ ភឹម មានស្រុកកំណើតនៅភូមិចិនឃុំគគីរសោម ស្រុករំដួល ខេត្តស្វាយរៀង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ភូមិចិនត្រូវបានប្តូរទៅជាភូមិសង្គម ឃុំគគីរសោម ស្រុកប្រសូត្រ តំបន់២៣ ។ ចំណែកសព្វថ្ងៃនេះ ភូមិសង្គម ស្ថិតនៅក្នុងឃុំគគីរសោម ស្រុកស្វាយទៀប ខេត្តស្វាយរៀង ។

សោ ភឹម មានឪពុកឈ្មោះ ប្រាក់ និងម្តាយឈ្មោះ មុំ ។ សោ ភឹម មានបងប្អូនបង្កើត៤នាក់ ដែលបងទី១ឈ្មោះ ប្រាក់ ដុំ ភេទប្រុស, បងទី២ឈ្មោះ ប្រាក់ ឈុន ភេទស្រី ទី៣គឺសោ ភឹម ផ្ទាល់ និងប្អូនពៅឈ្មោះ ប្រាក់ ឌុល ហៅ ប្រាក់ ទិត ភេទប្រុស ។ ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ បងស្រីរបស់ សោ ភឹម ឈ្មោះ ប្រាក់ ឈុន ត្រូវបានតែងតាំងជាប្រធានសហករណ៍នៅក្នុងភូមិសង្គម ស្រុកប្រសូត្រ ដែលភូមិកំណើតរបស់សោមភឹម ។ ចំណែកប្អូនប្រុសពៅរបស់ សោ ភឹម ឈ្មោះ ប្រាក់ ទិត ត្រូវបានតែងតាំងជាគណៈស្រុកប្រសូត្រ និងក្រោយត្រូវផ្លាស់មកទទួលជាគណៈស្រុកក្រូចឆ្មារវិញ ។

សោ ភឹម មានឈ្មោះកំណើតថា ប្រាក់ ចាម ។ ចាម បានកើតនៅអំឡុងដើមឆ្នាំ១៩២០ កាលពីនៅក្មេង ចាម បានចូលបួសជាសាមណេរជាមួយប្រុសឈ្មោះ ដុំ នៅវត្តឈើទាលក្នុងភូមិកំណើត ។ ចាម មានជុំងខាងចម្លាក់ កាលជំនាន់នោះញាតិមិត្តរបស់ ចាម តែងតែមកពឹងពាក់ឲ្យជួយឆ្លាក់រូបភាពផ្សេងៗ ជាពិសេសឆ្លាក់នៅលើដងកាន់កកណ្តៀវសម្រាប់ច្រូតស្រូវ ។ នៅចុងឆ្នាំ១៩៤០ ចាម បានលាចាក់សិក្ខាបទ និងបានចូលរួមតស៊ូជាមួយពួកខ្មែរឥស្សរៈ ដើម្បីប្រឆាំងជាមួយអាណានិគមនិយមបារាំងនៅព្រៃលើភ្នំប្រមាំខាងជើងស្រុករមាសហែក ខេត្តស្វាយរៀង ។ នៅខណៈនោះមេខ្មែរឥស្សរៈប្រចាំភូមិភាគបូព៌ាមានឈ្មោះ សឺន ស៊ីចាន់ ។ ពួកខ្មែរឥស្សរៈតែងតែចូលមកក្នុងស្រុកភូមិ ដើម្បីគៀងគរប្រជាជនឲ្យចូលរួមតស៊ូជាមួយក្រុមខ្លួន ។ យូរៗម្តងពួកខ្មែរឥស្សរៈក៏បានចូលមកចាប់រាជការខ្មែរដែលបម្រើឲ្យបារាំងយកទៅព្រៃលើភ្នំនៅក្បែរស្រុករមាសហែកដែរ ។ ក្នុងនោះក៏មាន ណៃ សារ៉ាន ហៅ យ៉ា មានស្រុកកំណើតនៅភូមិចិនឃុំគគីរសោមជាមួយ សោ ភឹម ដែរ ។ យ៉ា មានឈ្មោះកំណើតហៅថា សាំុ ធ្វើជាស្មៀនប្រចាំនៅឃុំគគីរសោម ។ ស្មៀន សាំុ ត្រូវបានពួកខ្មែរឥស្សរៈចូលមកចាប់នាំយកទៅព្រៃលើភ្នំ ។ ក្រោយមកស្មៀន សាំុ ក៏បានចូលរួមជាមួយខ្មែរឥស្សរៈ និងបានដូរឈ្មោះជាច្រើនដូចជា ម៉ែន សាន, អាចារ្យសៀង, ណៃ សារ៉ាន់ ហៅ យ៉ា ជាដើម ។ យ៉ា ជា អតីតលេខាភូមិភាគឦសានរហូតដល់ខ្មែរក្រហមចាប់ខ្លួននៅចុងឆ្នាំ១៩៧៦ ។

បន្ទាប់ពីចូលរួមតស៊ូជាមួយខ្មែរឥស្សរៈ ចាម ក៏បានផ្លាស់ឈ្មោះជាច្រើនដូចជា សុវណ្ណ, សោ យ៉ាន, ០៩ និង សោ ភឹម ។ នៅដើមឆ្នាំ១៩៥០ សោម ភឹម បានរៀបការជាមួយនារីឈ្មោះ ប្រែង ហៅយាយ ការ៉ូ ។ យាយការ៉ូ មានស្រុកកំណើតនៅភូមិជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

ចាប់តាំងពីរៀបការមក សោ ភឹម មានកូនប្រុសស្រីចំនួន ៤នាក់ កូនទី១ស្រីឈ្មោះ ស៊ី, កូនទី២ប្រុសឈ្មោះ ណាគ កូទី៣ស្រីឈ្មោះ កាដេវ និងកូនទី៤ប្រុសឈ្មោះ ឃុច ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ សោ ភឹម បានស្នាក់នៅដោយឡែកពីប្រពន្ធ និងកូន ។ សោ ភឹម ស្នាក់នៅមន្ទីរភូមិភាគបូព៌ាដែលនៅស្ថិតទីក្រុងសួង ។ ចំណែក យាយការ៉ូ បានស្នាក់នៅនិងគ្រប់គ្រងមន្ទីរកសិដ្ឋានភូមិភាគបូព៌ា នៅទួលសំរោងក្នុងស្រុក


រូបពីស្តាំមកឆ្វេង ៖ សោ ភឹម, ប៉ុល ពត, នួន ជា, អៀង សារី និង វ៉ន វេត នៅក្នុងកិច្ចប្រជុំមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជា

ពញាក្រែក តំបន់២០ ។ កូនស្រីច្បងរបស់ សោ ភឹម ឈ្មោះ ស៊ី បានរៀបការជាមួយកូនប្រុសច្បងរបស់ រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យ ឈ្មោះ ជាល នៅមន្ទីរទួលសំរោងក្នុងឆ្នាំ១៩៧៦ ។ បន្ទាប់ពីរៀបការហើយ ស៊ី បានផ្លាស់ទៅរស់នៅជាមួយប្តីក្នុងភូមិភាគពាយ័ព្យ ។ ចំណែកកូនប្រុសទី២ឈ្មោះ ណាត ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរពេទ្យព-២ របស់ភូមិភាគបូព៌ា ដែលស្ថិតនៅក្នុងស្រុកអូររាំង ។

សោ ភឹម មានសប្បុរសណ្ឋែកបាយរាងទាប ធាត់ និងមានកដៃកជើងតូចៗ ។ សោ ភឹម កើតមានជំងឺកមរមាស់នៅលើក្បាល ។ ពេលសម្រាកនៅផ្ទះ សោ ភឹម តែងតែស្លៀកសារ៉ុងសូត្រ និងអាវយឺតពណ៌ស ។ ពេលធ្វើដំណើរ ឬធ្វើការគាត់តែងតែស្លៀកខោខ្មៅ និងអាវសដៃខ្លី ។ សោ ភឹម ហាក់មានជំងឺប្រចាំកាយ ពីព្រោះគាត់មានពេទ្យនៅប្រចាំការ ។ ជារៀងរាល់ខែមានពេទ្យឡើងពីភ្នំពេញមកជួសឈាម និងយកលាមកទៅពិនិត្យនៅទីក្រុងភ្នំពេញ ។

នៅដើមឆ្នាំ១៩៧៦ សោ ភឹម បានទៅទស្សនកិច្ចនៅច្រកព្រំដែននៅបាវិត ។ ខណៈពេលនោះ សោ ភឹម បានឆ្លៀតចូលទៅលេងស្រុកកំណើតរបស់គាត់នៅឃុំគគីរសោម និងបានដើរសួរសុខទុក្ខសាច់ញាតិ នៅក្នុងឃុំនេះ ។ បន្ទាប់ពី សោ ភឹម វិលត្រឡប់វិញបានប្រហែលជា៤-៥ថ្ងៃ ក៏មានរថយន្តរបស់មន្ទីរភូមិភាគបូព៌ាចុះមកជ្រើសរើសយកសាច់ញាតិ និងកូនក្មួយរបស់ សោ ភឹម ចំនួន៩នាក់យកទៅមន្ទីរភូមិភាគ ។ ដំបូងអ្នកទាំង៩នាក់នេះត្រូវទៅមន្ទីរយោយការ៉ូ នៅទួលសំរោង រយៈពេលប្រមាណជា១០ថ្ងៃ ទើបបញ្ជូនទៅមន្ទីរកងការពារនៅសួង ។ ពេលទៅដល់មន្ទីរកងការពារនៅសួង យុវជនទាំង៩នាក់ បានជួបផ្ទាល់ជាមួយ សោ ភឹម ។ នៅខណៈពេលនោះ សោ ភឹម បានសួរនាំអំពីប្រវត្តិផ្ទាល់ខ្លួន និងឪពុកម្តាយរបស់យុវជនទាំង៩នាក់ បន្ទាប់មកទើប សោ ភឹម ឲ្យចូលទៅក្នុងកងការពារ ដើម្បីហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ពរយៈពេល៣ខែ ។ កងការពារចាស់ៗមួយចំនួនត្រូវបាន សោ ភឹម រំសាយ និងបញ្ជូនឲ្យទៅដឹកនាំនៅតាមមូលដ្ឋានដូចជា លេខា និងអនុលេខាស្រុកជាដើម ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ កងការពារ សោ ភឹម មានប្រមាណជា៦០នាក់ ។ ចំណែកប្រធានកងការពារ ឈ្មោះ ប្រាក់ ជឿក ក៏ជាប់ជាកូនក្មួយជាមួយ សោ ភឹម ម្នាក់ដែរ ។ ក្នុងក្រុមកងការពារ សោ ភឹម ក៏មានពេទ្យម្នាក់, ចុងភៅម្នាក់ និងអ្នកបើកបររថយន្តពីរនាក់ ។ ពេលចុះទៅធ្វើការងារ ឬប្រជុំទៅតាមតំបន់ និងស្រុកផ្សេងៗក្នុងភូមិបូព៌ា សោ ភឹម តែងតែយកពេទ្យ និងចុងភៅទៅជាមួយ ។ សោ ភឹម ចូលចិត្តហូបសម្លខ្មែរមួយចំនួន ដូចជា សម្លកកូរ សម្លប្រហើរ, សំឡក់ ត្រីអាំង ជាដើម ។ សោ ភឹម គាត់មិនចូលចិត្តហូបសម្លការី សម្លចាប់ឆាយឡើយ ។ ក្នុងរយៈពេល២សប្តាហ៍ ទៅមួយខែ ទើប សោ ភឹម ទៅលេងប្រពន្ធកូននៅមន្ទីរទួលសំរោងម្តង ។ ពេលទៅម្តងៗ សោ ភឹម តែងតែស្នាក់នៅ ២-៣ ថ្ងៃ, ៤-៥ថ្ងៃ ឬ១សប្តាហ៍ ។ ប៉ុន្តែមានពេលខ្លះ សោ ភឹម ទៅលេងតែមួយភ្លែតហើយគាត់ត្រឡប់មកមន្ទីរភូមិភាគនៅសួងវិញ ។ ជាទូទៅ សោ ភឹម ស្នាក់នៅ និងហូបចុកតែម្នាក់ឯង ។ សោ ភឹម ស្នាក់នៅក្នុងមន្ទីរកងការពារ ដែលស្ថិតនៅក្បែរនឹងមន្ទីរភូមិភាគ ។ នៅពេលយប់កងការពារបានដាក់វេនគ្នាយាមនៅខាងក្រោមកន្លែងស្នាក់នៅរបស់ សោ ភឹម រហូតទល់ភ្លឺ ។

រស់ ញឹម ដែលជាជន្ទងរបស់ សោ ភឹម បានខស្សរាហ៍ចេញ

ចូលមកជួបជាមួយ សោ ភឹម និងយាយការ៉ូ ជាញឹកញាប់ ។ ចំណែកមេដឹកនាំសំខាន់ៗដូចជា ប៉ុល ពត ក៏ធ្លាប់ឡើងទៅជួប និងធ្វើការជាមួយ សោ ភឹម នៅភូមិភាគបូព៌ាម្តង ។ នួន ជា បានចុះទៅជួប និងធ្វើការជាមួយ សោ ភឹម ប្រហែល៣ទៅ៤ដង ។ វន វ៉េត និង ខៀវ សំផន ក៏ធ្លាប់ឡើងទៅធ្វើការជាមួយ សោ ភឹម នៅភូមិភាគបូព៌ាដែរ ។ សុន សេន និង កែ ពក មានតួនាទីប្រចាំការនៅសមរភូមិខាងបូព៌ា ក៏បានជួប និងធ្វើការជាមួយ សោ ភឹម ជាញឹកញាប់ ។ ចំណែកជំនាញការចិន និងកូរ៉េខាងជើង ក៏ធ្លាប់បានទៅទស្សនកិច្ច និងជួបធ្វើការជាមួយ សោ ភឹម នៅភូមិភាគបូព៌ាដែរ ។

សោ ភឹម ជាមនុស្សលំដាប់ទី៤ ក្នុងបក្សកុម្មុយនីស្តកម្ពុជា បន្ទាប់ពី ប៉ុល ពត មនុស្សទី១ , នួន ជា ជាមនុស្សទី២ និង អៀង សារី ជាមនុស្សទី៣ ។ សោ ភឹម តែងតែចុះមកចូលរួមប្រជុំគណៈអចិន្ត្រៃយ៍បក្សនៅមន្ទីរ៨៧០ ក្នុងទីក្រុងភ្នំពេញក្បែរព្រះបរមរាជវាំងជារៀងរាល់២ដង ក្នុងមួយខែ ។ ពេលខ្លះមកឡាន១មានកងការពារ៣នាក់ និងអ្នកបើកឡានម្នាក់ ។ ពេលខ្លះមកឡាន២ គឺមានកងការពារ៦នាក់ និងអ្នកបើកឡាន២នាក់ ។ ពេលខ្លះប្រជុំចប់ត្រូវត្រឡប់ទៅភូមិភាគបូព៌ាវិញភ្លាម និងពេលខ្លះទៀតត្រូវស្នាក់នៅទីក្រុងភ្នំពេញរយៈពេល២-៣ថ្ងៃ ទើបត្រឡប់ទៅវិញ ។ ចំណែកកងការពារ បើ សោ ភឹម ប្រជុំចប់ត្រឡប់ទៅវិញភ្លាមនោះ កងការពារត្រូវរង់ចាំនៅមន្ទីរនីរសាររបស់ភូមិភាគបូព៌ានៅវត្តខណ្ឌលោម បើសិនជា សោ ភឹម ត្រូវស្នាក់នៅភ្នំពេញរយៈ២-៣ថ្ងៃនោះ គឺឡាន និងកងការពារត្រឡប់មកភូមិភាគបូព៌ាវិញភ្លាម បន្ទាប់ពីជូន សោ ភឹម មកដល់ភ្នំពេញ និងមកទទួលយកនៅថ្ងៃដែល សោ ភឹម ត្រូវត្រឡប់ទៅវិញ ។

នៅអំឡុងខែឧសភា ឬមិថុនា ឆ្នាំ១៩៧៨ បន្ទាប់ពីមានព្រឹត្តិការណ៍កម្មាភិបាលនៅភូមិភាគបូព៌ាត្រូវបានចាប់ខ្លួនជាច្រើនបន្តបន្ទាប់មក ខាងមជ្ឈិមបានស្នើឲ្យ សោ ភឹម ទៅធ្វើការនៅភ្នំពេញ ប៉ុន្តែ សោ ភឹម បានបដិសេធចំនួន២លើក ខាងមជ្ឈិមបានបញ្ជាឲ្យកងទ័ពបាញ់ផ្លោងដាក់កន្លែង សោ ភឹម ស្នាក់នៅ នៅមន្ទីរភូមិភាគបូព៌ា ។ បន្ទាប់មក សោ ភឹម និងកងការពារបានភៀសខ្លួនមកមន្ទីរកសិដ្ឋានទួលព្រាប នៅក្នុងស្រុកអូររាំង រយៈពេល២ថ្ងៃ ទើបធ្វើដំណើរមកមន្ទីរសេនាធិការរបស់ភូមិភាគបូព៌ា នៅទីរួមខេត្តព្រៃវែង ។ ខណៈពេលមកដល់ព្រៃវែង សោ ភឹម បានជួបនឹង សមមិត្ត រិន ដែលជាប្រធានកងពលទី៤របស់ភូមិភាគបូព៌ា ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរសេនាធិការនៅក្រុងព្រៃវែង ។ សោ ភឹម បានប្រាប់ រិន ឲ្យប្រមូលកងទ័ព និងកម្មាភិបាលដែលនៅសេសសល់នៅព្រៃវែង មកប្រជុំ សោ ភឹម បានប្រាប់ រិន និងកងទ័ពទាំងអស់នោះថា ឥឡូវខាងមជ្ឈិមបានចោទខាងបូព៌ាយើងថាក្បត់ហើយ ដូច្នេះយើងមានផ្លូវចំនួន២ត្រូវជ្រើសរើស ៖ ទី១គឺចុះចូលជាមួយគេ នោះគេនឹងចាប់យើងយកទៅសម្លាប់ទាំងអស់ ។ ចំណែកផ្លូវទី២ គឺយើងងើបឡើងតស៊ូប្រឆាំងនឹងគេវិញ ផ្លូវនេះ យើងអាចសង្ឃឹមថានឹងបានរស់ខ្លះ ។ កងទ័ព និងកម្មាភិបាលស្ទើរតែទាំងអស់បានសម្រេចជ្រើសរើសយកផ្លូវតស៊ូប្រឆាំងនឹងខាង ប៉ុល ពត វិញ ។ បន្ទាប់មក សោ ភឹម បានផ្តាំ រិន ថា «ខ្ញុំត្រូវធ្វើដំណើរទៅទីក្រុងភ្នំពេញដើម្បីដោះស្រាយបញ្ហាមួយចំនួនជាមួយមជ្ឈិម បើរយៈពេល១សប្តាហ៍បាត់ដំណឹងខ្ញុំមិនឃើញត្រឡប់មកវិញ គឺខ្ញុំស្លាប់ហើយ រិន ឯងចូលព្រៃតស៊ូទៅ» ។ បន្ទាប់មក សោ ភឹម និងកងកាពារបានបើកឡានពីព្រៃវែងកាត់តាមព្រែកតាមាក់ចុះមកខាងអរិយក្សត្រ ។ ពេលមកដល់អរិយក្សត្រទល់មុខទីក្រុងភ្នំពេញ សោ ភឹម បានបញ្ជានីរសារឲ្យយកសំបុត្រទៅប្រគល់ជូន ប៉ុល ពត នៅភ្នំពេញ ដើម្បីមកទទួលគាត់ឲ្យចូលទៅទីក្រុងភ្នំពេញ ប៉ុន្តែសំណើ សោ ភឹម ត្រូវបានបដិសេធចំនួន២ដង ។ នៅយប់នោះ ប៉ុល ពត បានបញ្ជាឲ្យនីរសារក្រុងមកឡោមព័ទ្ធចាប់ សោ ភឹម នៅអរិយក្សត្រ ប៉ុន្តែសំណាងល្អបានក្រុមនីរសារ និងកងកម្លាំងស្រុកល្វាឯមជួយសង្គ្រោះ សោ ភឹម ទាន់ពេល ដោយយក សោ ភឹម មកមន្ទីរស្រុកល្វាឯម និងបន្តទៅមន្ទីរស្រុកខ្សាច់កណ្តាល ។ ចុងក្រោយ សោ ភឹម និងកងការពារបានទៅដល់មន្ទីរស្រុកស្រីសន្ធរនៅព្រែកពោធិ៍ ។ នៅទីនោះ សោ ភឹម បានកោះប្រជុំកម្មាភិបាលនៅស្រុកល្វាឯម, ស្រុកខ្សាច់កណ្តាល និងស្រុកស្រីសន្ធរ ។ ក្រោយមកកង ទ័ពមជ្ឈិមបានឡោមព័ទ្ធចាប់ សោ ភឹម នៅព្រែកពោធិ៍ម្តងទៀត ។ លើកនេះ សោ ភឹម និងកងការពារអស់លទ្ធភាពនឹងគេចខ្លួនទៀតហើយ សោ ភឹម ក៏សម្រេចចិត្តធ្វើអត្តឃាតជាមួយ និងកងការពាររបស់គាត់នៅទីនោះតែម្តង ។

**ឡុង ដានី**

# អ៊ូ សូធីម : ការងារចាត់តាំងក្នុងរបបខ្មែរក្រហម


អ៊ូ សូធីម

សូ ធីម មានវ័យជាង២០ឆ្នាំ នៅសម័យ លន់ នល់ ។ គាត់មិនបានរៀនសូត្របានចប់ចុងចប់ដើមនោះទេ ដោយសារតែសង្គ្រាម គាត់បានរៀនត្រឹមថ្នាក់ទី៧ចាស់ប៉ុណ្ណោះ ។ ធីម បានរៀបការនៅឆ្នាំ១៩៧២ និងរស់នៅជុំជាមួយបងប្អូន និងគ្រួសារដែលមានសមាជិក៦នាក់ នៅភូមិកោះដាច់ ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិស្រុកដែល ធីម រស់នៅ ។ បន្ទាប់មកខ្មែរក្រហមក៏បានជម្លៀសអ្នកភូមិទាំងអស់ទៅរស់នៅខាងព្រែកពោធិ៍ និងស្រុកពារាំង ក្នុងនោះ ក៏មានគ្រួសារគាត់ដែរ ។

ការជម្លៀសប្រជាជននេះ គឺមកពីពេលនោះ មានប្រជាជនក្នុងភូមិតែងតែលួចរត់ចេញទៅភ្នំពេញ ហេតុនេះ ខ្មែរក្រហមក៏ធ្វើការជម្លៀសប្រជាជនទៅឆ្ងាយទៀត ដើម្បីចៀសវាងការលួចរត់ ។ ធីម ដឹងថា ពេលដែលខ្មែរក្រហមចូលដំបូងមកឆ្នាំ១៩៧៣ នេះ គឺអតីតមេភូមិ មេ៥០ខ្នង មេ១០០ខ្នង ជំនាន់លន់នល់ ត្រូវខ្មែរក្រហមហៅយកទៅ ហើយក៏មិនដែលឮដំណឹងពីអ្នកទាំងនោះទៀតដែរ ។ ពេលចាប់ផ្តើមជម្លៀសដំបូង ក៏មានភាពជ្រួលច្របល់ពីអ្នកភូមិខ្លះដែរ ចំណែក ធីម និងគ្រួសារពេលនោះ យកបានខោអាវខ្លះ និងគោខ្លះសម្រាប់អូសរទេះធ្វើដំណើរ ។ គាត់ចេញដំណើរដំបូង បានទៅដល់មាត់ទន្លេ ខាងព្រែកប្រសព្វ ។ ដោយសារទៅដល់ទីនោះ នៅតែមានប្រជាជនលួចរត់ទៀត ខ្មែរក្រហម ក៏ជម្លៀសប្រជាជនបន្តទៅដល់ខាងទន្លេតូច ស្រុកពារាំង ។ ការរស់នៅទីនោះ មិនមានការរឹតត្បិតខ្លាំងក្លានោះទេ ប្រជាជនម្នាក់ៗមានសិទ្ធិដាំដំណាំ រកម្ហូបបរិភោគជាឯកជនបាន ។ ដោយសារតែ ធីម ជាអ្នកកោះដាច់ ហើយភាគច្រើនអ្នកភូមិជាអ្នកតម្បាញក្រមា ធីម មានក្រមាច្រើនគួរសម សម្រាប់ដូរម្ហូបអាហារ និងរបស់របរមួយចំនួនសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ។ ធីម ត្រូវខ្មែរក្រហមចាត់ចូលឲ្យធ្វើក្នុងក្រុមកងស្ម័យត្រាណការពារភូមិ ដោយមាននាទីល្បាតការពារភូមិនៅពេលយប់ និងសែងអ្នករបួស ពេលដែលអង្គការដឹកមកដល់ ។

ក្រោយជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ អង្គការបានឲ្យប្រជាជនជម្លៀសពីភូមិកោះដាច់ទាំងអស់ត្រឡប់មករស់នៅភូមិវិញ ។ ធីម និងគ្រួសារបានត្រឡប់មករស់នៅភូមិកំណើតវិញដោយក្តីរីករាយ ។ ពេលត្រឡប់មកវិញ អង្គការបានធ្វើការបែងចែកការងារទៅតាមសហករណ៍ ទៅតាមមុខព្រួញនីមួយៗ ។ ដោយ ធីម ជាយុវជនកម្លាំងស្រួច អង្គការបានចាត់ឲ្យចូលក្នុងកងយុវជនលើកដីនៅខាងបុស្សីជ្រោយ ។ នៅភូមិ គ្រួសាររបស់គាត់មានគោមួយនឹម ហេតុនេះ ក្រៅពីការងារនៅការដ្ឋាន អង្គការបានចាត់តាំង ធីម និងអ្នកឯទៀត ដែលមានគោ គឺត្រូវមើលថែគោ ហើយដើរជួយភ្ជួររាស់ដីស្រែ ដីចម្ការណាដែលសហករណ៍ ឬប្រជាជនត្រូវការ ។

ចំណែក ឪពុកម្តាយគាត់ ដែលមានវ័យចំណាស់ហើយ អង្គការចាត់តាំងឲ្យលួសដ្តៅ ធ្វើបង្គី ដងវែក វេញខ្សែគោ ជាមួយចាស់ៗឯទៀត សម្រាប់កងចល័ត ។ អំឡុងឆ្នាំ១៩៧៦ ធីម ត្រូវអង្គការចាត់ចូលទៅក្នុងកងពាន់ (មានសមាជិក១០០០នាក់) ដែលធ្វើការនៅការដ្ឋានក្រោយព្រែកអញ្ចាញ ។ ទៅដល់ទីនោះដំបូង អង្គការបានចែកចបថ្មីឲ្យម្នាក់មួយសម្រាប់កាប់ដីដាំពោត ។ ធីម ទៅធ្វើនៅកងពាន់ដាំពោតនេះ គឺធ្វើតាំងពីរដូវទឹកសម្រក រហូតដល់រដូវទឹកលិច ទើបអង្គការផ្លាស់ឲ្យទៅលើកទំនប់ ។ ធីម បញ្ជាក់ថា «យើងដាំដុះបានផលហើយ តែយើងមិនមែនជាអ្នកប្រមូលទេ គឺមានក្រុមផ្សេងចុះមកប្រមូល» ។ ការហូបចុកទៀតសោត ក៏មិនចោទជាបញ្ហាខ្លាំងដែរសម្រាប់គាត់ ព្រោះអង្គការចែករបប បបរឲ្យម្នាក់មួយកាម៉ែលដែរ ហើយម៉ោងពេលធ្វើការក៏មិនរិតត្បិតណាស់

ណាដែរ គឺចាប់ផ្តើមពីម៉ោង៧ព្រឹក ដល់ម៉ោង១១ និងរសៀលពីម៉ោង១ ដល់៥ល្ងាច និងបន្ទាប់ពីហូបល្ងាចរួច បន្តដីកប្រឡាយបន្ថែមទៀត ។

បន្ទាប់ពីទៅធ្វើការនៅកងពាន់មួយរយៈ ធីម ត្រូវអង្គការចាត់ឲ្យមកភូមិវិញ មកធ្វើការនៅរោងបាយភូមិ ធ្វើជាអ្នកដាំបបរ និងរែកទឹក ។ នៅក្នុងរោងបាយម្នាក់ៗមានការងារធ្វើរៀងខ្លួន មានអ្នកដាំបាយ រកត្រី ពុសខស ជាដើម ។ ធីម បានឲ្យដឹងថា ភូមិស្រុកដែលខ្លួនរស់នៅ គឺមិនមានប្រជាជនជម្លៀសមកពីភ្នំពេញ ឬកន្លែងផ្សេងៗនោះទេ គឺមានតែប្រជាជនចាស់ ប្រជាជនមូលដ្ឋានដែលអង្គការធ្លាប់ជម្លៀសទៅឆ្នាំ១៩៧៣ប៉ុណ្ណោះ ហេតុនេះហើយទើបការរស់នៅមិនសូវជាលំបាកពេកទេ ។ ចំពោះផ្នែកសេដ្ឋកិច្ចដូចជា បើករបបអង្ករ ស្ករ ថ្នាំពេទ្យ ឬសម្ភារផ្សេងៗ គ្រប់ភូមិ ឃុំនៅកោះដាច់នេះ គឺត្រូវមកបើកនៅវត្តក្រពុំពេជ្រ ដែលអង្គការយកធ្វើជាឃ្លាំងសេដ្ឋកិច្ច ។ ធីម បន្ទាប់ពីការងាររោងបាយ អង្គការបានឲ្យទៅមើលគោដែលជាការងារចាស់រហូតដល់ថ្ងៃរំដោះតែម្តង ។

ក្រោយបរាជ័យរបស់ខ្មែរក្រហម កម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិរបស់ ធីម បាននាំគ្នារត់ចេញអស់ ហើយវៀតណាមក៏ចូលមកគ្រប់គ្រងតែម្តង ។ មុន និងក្រោយរបបខ្មែរក្រហម ធីម និងគ្រួសារមិនបានចាកចេញទៅរស់នៅកន្លែងផ្សេងទេ ។

**ផាង សារៈមុនិន្ទ**

# ខ្សែភាពយន្តឯកសាររឿង «ក្បាលទឹកទន្លេ»

"ក្បាលទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បាលទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បាលទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ : ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*





# ជីវិតរបស់ឪពុកខ្ញុំ ក្នុងរបបអង្គការខោអាវខ្មៅ

ឪពុកខ្ញុំឈ្មោះ វ័ល ធឿន កើតនៅឆ្នាំ១៩៤៨ នៅភូមិក្បាលពោធិ៍ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកខ្ញុំកើតនៅក្នុងគ្រួសារកសិករ ។ គាត់គឺជាកូនទី៥ នៅក្នុងចំណោមបងប្អូនបង្កើត៧នាក់ (ប្រុស៣នាក់ និងស្រី៤នាក់) ។ គាត់ធ្លាប់បានបួសជាព្រះសង្ឃបានចំនួន២វស្សា នៅសម័យសង្គមរាស្ត្រនិយម ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ។ ស្របពេលជាមួយគ្នានោះដែរ គាត់ក៏បានសឹកពីព្រះសង្ឃ មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបនយោបាយពីរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ មកកាន់របបសាធារណរដ្ឋ ។ ស្ថានភាពនយោបាយនៅកម្ពុជាបានទាញប្រទេសមួយនេះឲ្យធ្លាក់ទៅក្នុងសង្គ្រាមយ៉ាងធ្ងន់ធ្ងរ រវាងនិន្នាការនយោបាយពីរ គឺប្រជាជនខ្មែរមួយចំនួននៅគាំទ្រសម្តេច សីហនុ និងប្រជាជនខ្មែរមួយចំនួនទៀត គាំទ្ររបបសាធារណរដ្ឋខ្មែរ ។ ពេលនោះ ក៏មានការប្រកាសតាមវិទ្យុពីប៉េកាំងរបស់សម្តេចព្រះនរោត្តម សីហនុ ជាមូលហេតុធ្វើឲ្យប្រជាជនខ្មែរមួយចំនួន បានរត់ចូលព្រៃម៉ាគី ដើម្បីធ្វើទ័ពប្រឆាំងជាមួយកងទ័ពលោកសេនាប្រមុខ លន់ នល់ ។ កងទ័ពរំដោះទាំងអស់នោះត្រូវបានស្គាល់ថា ខ្មែរក្រហម ។ វត្តមានកងទ័ពខ្មែរក្រហមបានរាលដាលពីតំបន់មួយទៅតំបន់មួយទៀតទូទាំងប្រទេសកម្ពុជាយ៉ាងឆាប់រហ័ស ។

សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ជាមូលហេតុនៃសោកនាដកម្មដ៏ធំធេងសម្រាប់ប្រទេសខ្មែរ និងប្រជាពលរដ្ឋខ្មែរ ។ សង្គ្រាមនេះដែរបានបំផ្លាញដីស្រែ ផលដំណាំកសិកម្មរបស់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាបានបំផ្លាញនូវមុខរបរការរកស៊ីជួញដូរគ្រប់ប្រភេទរបស់ប្រជារាស្ត្រទូទាំងប្រទេស ។ មិនត្រឹមតែប៉ុណ្ណោះ សង្គ្រាមនេះថែមទាំងបានបំផ្លាញទ្រព្យសម្បត្តិប្រទេសជាតិ និងបំផ្លាញទាំងជីវិតមនុស្ស និងសត្វពាហនៈសត្វបែបយ៉ាងផងដែរ ។ ក្រោយពេលដែលរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ បានតែមួយរយៈពេលខ្លីសោះ អ្នកភូមិក្បាលពោធិ៍ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ បាននាំគ្នាស្រឡាំងកាំងចំពោះវត្តមានរបស់ទាហានធីវគី លីកាំភ្លើងជាក្រុមៗដើរកាត់ភូមិរបស់គាត់ ។ នៅពេលនោះ ឪពុករបស់ខ្ញុំមានអាយុប្រហែល២៨ឆ្នាំ ។ គាត់ត្រូវបានទាហានធីវគី ចាប់ដោយបានចោទប្រកាន់គាត់ថា ជាទាហានយៀកកុង ។ គាត់ត្រូវបានទាហាន ធីវគី ធ្វើទារុណកម្មសួរចម្លើយ ដោយបានយកកាំភ្លើងវែងមកវាយក្បាលរបស់គាត់ត្រូវចំគុម្ពត្រចៀកជាច្រើនដង ដែលជាមូលហេតុធ្វើឲ្យត្រចៀករបស់គាត់មួយចំហៀងលែងឮ ។ ទាហានធីវគី បានចងគាត់ជាមួយនឹងយុវជនដទៃទៀត ហើយគាត់បានឮទាហានធីវគី និយាយគ្នាជាភាសាវៀតណាមថា ភ្លឺឡើងស្អែកពេលព្រឹកនឹងយកពួកគាត់ទៅសម្លាប់ចោល ។ ឆ្លៀតឱកាសនោះ គាត់ក៏បានលួចស្រាយចំណងរួច ហើយលួចរត់ទៅលាក់ខ្លួននៅក្នុងភូមិផ្សេងអស់មួយរយៈ ។ ដោយសារសង្គ្រាមនៅក្នុងភូមិ ទើបបណ្តាលឲ្យជីវភាពគ្រួសាររបស់ឪពុកគាត់ពេលនោះជួបការខ្វះខាត ទើបឪពុកគាត់ និងបងប្រុសទី១ និងប្អូនស្រីពៅរបស់គាត់បានបង្ខំចិត្តទៅរកការងារធ្វើនៅភ្នំពេញ ។

ចូលមកដល់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំ ព្រមទាំងបងប្រុសទី១ និងប្អូនស្រីពៅរបស់គាត់ត្រូវបានអង្គការជម្លៀសមកស្រុកទ្រាំង ខេត្តតាកែវវិញ ។ មកដល់ស្រុកកំណើតឪពុករបស់ខ្ញុំ និងបងប្អូនរបស់គាត់ត្រូវរស់នៅបែបវណ្ណៈកសិករអធន ដោយត្រូវមានការហាត់ពត់លត់ដំធ្វើពលកម្មធ្ងន់ធ្ងរ និង ហូបរួម ។ នៅពេលនោះគ្រួសាររបស់ឪពុកខ្ញុំត្រូវបានអង្គការចាត់ទុកថាជាក្រុមប្រជាជនថ្មីដែរ ។ ដូច្នេះមនុស្សក្នុងគ្រួសារនេះទាំងអស់គ្នាត្រូវទទួលទម្ងន់នៃការបំបាត់សិទ្ធិសេរីភាព ក៏ដូចជា ការទទួលការបង្ខិតបង្ខំឲ្យចេញធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរជាមួយនឹងការផ្តល់របបអាហារជាបបររាវតិចតួចបំផុត ។

ឪពុកខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅកងចល័តដែលត្រូវជីកប្រលាយ និងលើកទំនប់ ។ នៅពេលនោះ កងចល័តចំនួន

ប្រហែល៩០នាក់ ត្រូវហូបបបររាវដែលមានអង្ករ៤ ទៅ៦កំប៉ុង ប៉ុណ្ណោះ ។ ដោយសារតែបបររាវពេកឪពុកខ្ញុំក៏ដូចជាកងចល័តទាំងនោះ ត្រូវប្រឹងប្រែងស្វះស្វែងរកត្រកួន ព្រលិត ប្រាច់ ទំពាំងឫស្សីព្រៃ ឬត្នោតទុំ មកធ្វើជាអាហារបន្ថែម ដើម្បីសម្រន់ការអត់ឃ្លាន ។ ក្រោយមកអង្គការបានបញ្ជូនឪពុកខ្ញុំឲ្យទៅធ្វើការនៅកងចល័តនៅកំពង់យោល កំពង់អំពិល ខេត្តតាកែវ ។ តំបន់កំពង់យោល ជាតំបន់ដែលអាចធ្វើឲ្យប្រជាជនចំណូលថ្មីងាយនឹងចាញ់ទឹក ចាញ់ដី និងងាយរងនូវជំងឺគ្រុនចាញ់ ។ ការងារនៅទីនោះ មានសភាពសម្រុកយ៉ាងខ្លាំង ។ អង្គការបានបង្ខំឲ្យកងចល័តទាំងឡាយ ព្រមទាំងឪពុកខ្ញុំផងដែរឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ស្ទើរតែគ្មានពេលសម្រាក ។ ទោះបីធ្វើការងារពលកម្មធ្ងន់ធ្ងរលំបាកយ៉ាងណា អង្គការបានផ្ដល់នូវបបររាវក្នុងម្នាក់ៗតែពីរ ឬបីវែកតែប៉ុណ្ណោះ ។ កាលបើទទួលបានរបបបបររាវតែប៉ុណ្ណោះ ទើបកងចល័ត និងឪពុកខ្ញុំត្រូវតែខ្នះខ្នែងរកម្ហូបអាហារដែលអាចរកបានយកមកហូបបន្ថែម ដូចជា បន្លែ ឬត្រី ដោយត្រូវធ្វើការលាក់លៀមពីភ្នែកច្រមុះអង្គការទៀត ព្រោះថាអង្គការបានហាមឃាត់ដាច់ខាត ។

ប្រសិនបើអង្គការបានដឹងថា ឪពុកខ្ញុំ ឬក៏ប្រជាជនណាម្នាក់លួចចេញទៅរកម្ហូបអាហារ អ្នកនោះនឹងត្រូវអង្គការហៅយកទៅកសាង ឬធ្វើទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ រហូតពេលខ្លះឈានទៅដល់សម្លាប់ចោលទៀតផង ។ ការអត់ឃ្លាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បានបង្ខំឲ្យស្ត្រីម្នាក់ជាប្រជាជន១៧ មេសា ដាច់ចិត្តលួចហូបសាច់សពកូនខ្លួនឯងដែលបានស្លាប់ ដោយកាប់យកដៃយកជើងសពកូន យកទៅសោរដើម្បីចម្អែតក្រពះ ។ ក្រោយមក ស្ត្រីនោះត្រូវអង្គការចាប់យកទៅសម្លាប់ចោលទៀត ។

ម្ហូបអាហារដែលឪពុកខ្ញុំ ព្រមទាំងប្រជាជនថ្មីឯទៀត អាចស្វះស្វែងរកបាននោះ មានតែកូនក្អាត់ទំហំប៉ុនម្រាមដៃ ក្ដាម ខ្យង ឬកណ្ដុរប៉ុណ្ណោះ ។ ចំពោះសត្វកណ្ដុរ ឬកូនក្អាត់ កាលពីមុនមកប្រជាជនខ្មែរ មិនដែលបរិភោគទេ ។ ប៉ុន្តែដោយសារការអត់ឃ្លានប្រជាជនខ្មែរបានបរិភោគទាំងអស់ ។ អ្នកខ្លះទៀត នៅពេលដែលចាប់បានកូនក្អាត់ ក្ដាម ឬ កំពិសភ្លាម បានហូបសត្វទាំងអស់នោះទាំងឆៅតែម្ដងក៏មាន ព្រោះខ្លាចអង្គការឃើញ ។ នៅតំបន់ខ្លះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាជនមួយចំនួនបានយកព្រ័តគោទៅស្ងោរ ក្នុងរយៈពីរទៅបីថ្ងៃ ដើម្បីបរិភោគសម្រន់ការអត់ឃ្លានក៏មាន ។ សម្រាប់បន្លែវិញ ដើម្បីចម្អែតក្រពះ ប្រជាជនចំបាច់ត្រូវតែហូបគល់កូនម្កាក់ ទំពាំងឫស្សីព្រៃ ព្រលិត ប្រាច់ ត្រកួន ។ល ។

ការបង្ខិតបង្ខំឲ្យប្រជាជនធ្វើពលកម្មធ្ងន់ធ្ងរ ជាមួយនឹងការផ្ដល់បបររាវ មានតែអង្ករមួយគ្រាប់ៗ ការហូបសត្វផ្ដេសផ្ដាស និងបន្លែគ្រប់មុខ បានបណ្ដាលឲ្យប្រជាជនមានជំងឺសព្វបែបយ៉ាង ដូចជា ជំងឺរាករូស ខ្វះជីវជាតិ បណ្ដាលឲ្យស្គមស្គាំង ឬហើមពេញទាំងខ្លួនជាមួយស្បែកឡើងលឿងស្លេកស្លាំង ។ល ។

ចំណែកថ្នាំសម្រាប់ព្យាបាលជំងឺប្រជាជនវិញ គឺមានតែថ្នាំសួនខ្មៅៗដូចអាចម៍ទន្សាយ និងសេរ៉ូម ទឹកដូង ដែលមិនអាចមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺប្រជាជននាពេលនោះបានឡើយ ។ ប្រជាជនត្រូវស្លាប់ដោយជំងឺ ឬត្រូវស្លាប់ដោយការខ្វះអាហារហូបចុក ។

ក្រៅពីសេចក្ដីស្លាប់ដូចមូលហេតុខាងលើ អង្គការតែងតែយកប្រជាជនយកទៅសម្លាប់ចោលពីបទហ៊ាននិយាយតវ៉ាជាមួយអង្គការ ធ្វើឲ្យបាក់នង្គ័ល បាត់គោ បាក់ចប លួចដាំបាយបរិភោគ លួច ស្ងោរដំឡូងបរិភោគ លួចទៅសួរសុខទុក្ខបងប្អូនមានជំងឺ យំសោកស្ដាយអ្នកស្លាប់ ច្រូតស្រូវជ្រុះគួរស្រូវ ជម្រះស្មៅពោតដំឡូងមិនស្អាត ឬធ្វើឲ្យបែកខូចឧបករណ៍នេសាទ មានមង និងអួនជាដើម ។ រីឯទោសកំហុស នៅពេលអង្គការយកមនុស្សទៅសម្លាប់ គ្រាន់តែនិយាយថា អ្នកនោះក្បត់បដិវត្តន៍ប៉ុណ្ណោះ ។

ចំណែកអាពាហ៍ពិពាហ៍ អង្គការមានការកំណត់សម្រាប់ប្រជាជនទៅតាមវណ្ណៈដែលខ្លួនបែងចែង គឺប្រជាជនចាស់ត្រូវតែរៀបការជាមួយប្រជាជនចាស់ ឯប្រជាជនថ្មីត្រូវតែរៀបការជាមួយនឹងប្រជាជនថ្មី ។ អង្គការកម្រនឹងអនុញ្ញាតឲ្យប្រជាជនចាស់មករៀបការជាមួយប្រជាជនថ្មីណាស់ ។ អាពាហ៍ពិពាហ៍រវាងប្រជាជនចាស់ និងប្រជាជនថ្មី អាចកើតមានឡើងលុះត្រាតែសមាជិកក្នុងគ្រួសារនៃភាគីប្រជាជនចាស់ មានទោសកំហុសដោយប្រការណាមួយដែលកំណត់ដោយអង្គការ ហើយជាប់ឈ្មោះថាគ្រួសារជាប់បំណុលឈាម ។ កាលបើមានទោស ប្រជាជនចាស់ក្ដី ប្រជាជនថ្មីក្ដី មុខជានឹងត្រូវអង្គការហៅប្រជាជនរូបនោះទៅកសាង ឬយកទៅរៀនសូត្រជាមិនខាន ។ នៅក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ អង្គការ

បានសម្លាប់បងប្អូនឪពុកខ្ញុំអស់ចំនួន២នាក់ គឺបងប្រុសទី១ និងប្អូនស្រីទី៧ ដោយត្រូវអង្គការចោទថា ក្បត់ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ។ ប្រជាជនខ្មែរទូទាំងប្រទេស រួមទាំងឪពុកខ្ញុំដែលសល់ពីការកាប់សម្លាប់ បានធ្វើការផ្លាស់ប្តូរទីលំនៅពីតំបន់ដែលអង្គការជម្លៀសទៅ មកកាន់ស្រុកកំណើតវិញ ។ មនុស្សរាប់ម៉ឺននាក់ បានរំកិលនៅលើដងផ្លូវតូច-ធំទាំងឡាយ នៅទូទាំងប្រទេសកម្ពុជា ចេញទៅរកស្រុកភូមិវិញ ។

សព្វថ្ងៃ ឪពុករបស់ខ្ញុំនៅតែចងចាំជានិច្ចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់នេះ ។ គាត់បានសំណូមពរឲ្យកូនខ្មែរជំនាន់ក្រោយសិក្សារៀនសូត្រ និងស្វែងយល់អំពីប្រវត្តិសាស្ត្រដ៏សែនជូរចត់មួយនេះ ដើម្បីទុកជាមេរៀនដ៏សំខាន់ដែលត្រូវចងចាំ និងទុកជាមេរៀនសម្រាប់កូនចៅកុំឲ្យកើតមាននៅថ្ងៃមុខទៀត ។

**ជួត រិទ្ធី**



កងចល័តជីកប្រឡាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩)

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំឭកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិ សាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុម គ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្នេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រិតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតទ្បើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអធម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈ ។

សរុបសេចក្តីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយទ្បើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ធ្វើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# ជាភ័ព្វសំណាងរបស់ខ្ញុំ ឬ?



រូបខាងឆ្វេង ៖ ផាវ សារមុនិន្ទ អ្នកសរសេរទស្សនាវដ្ដីស្វែងរកការពិត និង ជិន សុខា

ក្រោយរបបខ្មែរក្រហមដួលរលំ នាថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ ប្រជាជនខ្មែរជាងពីរលាននាក់ បានស្លាប់ដោយសារអត់អាហារ ការធ្វើពលកម្មហួសកម្លាំង ជំងឺ និងការសម្លាប់ ។ គ្រួសារនីមួយៗ ត្រូវបាត់បង់សមាជិកគ្រួសារ ឬសាច់ញាតិរបស់ខ្លួនយ៉ាងហោចណាស់មួយនាក់ ហើយគ្រួសារខ្លះ ត្រូវស្លាប់ទាំងអស់តែម្ដង ។ ជាក់ស្ដែង គ្រួសាររបស់ ជិន សុខា មានសមាជិកទាំងអស់១៨នាក់រួមទាំងឪពុកម្ដាយ ជីដូន និងក្មួយស្រីម្នាក់ តែក្រោយរបបខ្មែរក្រហមបានបញ្ចប់ សមាជិក៣នាក់ប៉ុណ្ណោះដែលមានវាសនារួច ជីវិតពីរបបដ៏ព្រៃផ្សៃមួយនេះ គឺប្អូនស្រីរបស់គាត់ដែលបានទៅសហរដ្ឋអាមេរិក មុនខ្មែរក្រហមកាន់កាប់ប្រទេស និងប្អូនស្រីម្នាក់ទៀត ដែលបានរៀបការជាមួយប្រជាជនមូលដ្ឋានចាស់ និង សុខា ផ្ទាល់ ។

**សម័យ លន់ នល់**

មុនរបបខ្មែរក្រហម សុខា រៀនសាលាពញាយ៉ាត (បច្ចុប្បន្នសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង) ។ នៅភ្នំពេញ សុខា និងគ្រួសាររស់នៅខាងកើតវត្តទួលទំពូង ម្ដុំលូទឹកស្អុយ ជាមួយនឹងបងប្អូនប្រុសស្រី ១០នាក់ ។

ក្រោយរដ្ឋប្រហារទម្លាក់សម្ដេច ព្រះនរោត្តម សីហនុ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ សុខា ក៏ដូចជា សិស្ស និស្សិតផ្សេងទៀត បានចូលរួមធ្វើបាតុកម្មដើម្បីប្រឆាំងនឹង លន់ នល់ ។ នៅឆ្នាំ ១៩៧៤ សុខា បានរៀបការ តែពិធីមង្គលការនៅពេលនោះ មិនបានរៀបចំឲ្យអធិកអធមនោះទេ ព្រោះស្ថានភាពស្រុកទេសមិនល្អ ដោយគ្រាន់តែរៀបចំពិធីសែនព្រេនជាការបំពេញកិច្ចប៉ុណ្ណោះ ។

**ជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥**

ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ សុខា បានរត់ពីផ្ទះជួលរបស់គាត់មកកាន់ផ្ទះឪពុកម្ដាយគាត់នៅខាងកើតវត្តទួលទំពូង ដើម្បីប្រាប់ដំណឹងពីជ័យជម្នះរបស់ខ្មែរក្រហម និងពីការបណ្ដេញឲ្យចេញពីផ្ទះ ។ ពេលនោះ ដោយសារអង្ករមិនគ្រប់គ្រាន់ សុខា និងប្អូនប្រុសម្នាក់ទៀត បាននាំគ្នាទៅយកអង្ករនៅឃ្លាំងអង្ករម្ដុំស្ពានព្រះមុនីវង្ស ។ មនុស្សម្នាជាច្រើនបានប្រជ្រៀតគ្នាយកអង្ករ ហើយអ្នកមួយចំនួនទៀតបានស្លាប់ដោយសារតែបាវអង្ករធ្លាក់សង្កត់ពីលើ ។ នៅប្រហែលម៉ោង៦ល្ងាច ខ្មែរក្រហមបានមកដល់ផ្ទះរបស់ សុខា ។ គាត់ និងសមាជិកគ្រួសារទាំងអស់ត្រូវខ្មែរក្រហមបង្ខំឲ្យចេញពីផ្ទះភ្លាមៗ ។ សុខា បានដើរបែកពីគ្រួសារដើម្បីទៅរកប្រពន្ធនៅឯផ្ទះជួល នៅតាមផ្លូវ គាត់ត្រូវខ្មែរក្រហមឃាត់សួរ ដោយសារតែគាត់ធ្វើដំណើរបញ្ច្រាស់ទិសដែលខ្មែរក្រហមឲ្យធ្វើដំណើរ ។ ពេលនោះ ខ្មែរក្រហមសួរគាត់ថា “មិត្តឯងទៅណា?” សុខា ឆ្លើយថា “ខ្ញុំទៅរកគ្រួសារ បងប្អូន” ។ ខ្មែរក្រហម មិនព្រមឲ្យគាត់ទៅមុខទៀតទេ ដោយឲ្យត្រឡប់ក្រោយជាមួយប្រជាជនជម្លៀសដទៃទៀត ។ សុខា ក៏ធ្វើតាមការណែនាំនេះ ពេលគាត់ត្រឡប់ក្រោយវិញគាត់ងាកមកក្រោយឃើញយោធាខ្មែរក្រហមបាញ់សម្លាប់ប្រជាជនជម្លៀសដែលធ្វើដំណើរខុសនឹងបញ្ជារបស់ខ្លួន ។ សុខា គិតក្នុងចិត្តថា គាត់ពិតជាសំណាងណាស់ដែលយោធាខ្មែរក្រហមទាំងនោះ មិនសម្លាប់គាត់ដូចអ្នកឯទៀត ។ សុខា បានព្យាយាមដើរវាងចុះឡើងដើម្បីគេចពីភ្នែកយោធាខ្មែរក្រហម ទីបំផុត គាត់បានទៅដល់ផ្ទះជួលដែលប្រពន្ធមានទម្ងន់របស់គាត់កំពុងរង់ចាំគាត់យ៉ាងអន្ទះសារ ។

បន្ទាប់ពីទៅដល់ផ្ទះ សុខា និងប្រពន្ធ បានរៀបចំអីវ៉ាន់ធ្វើដំណើរមកទិសខាងស្ពានព្រះមុនីវង្ស ព្រោះស្រុកកំណើតរបស់ឪពុកគាត់នៅខេត្តព្រៃវែង ។ នៅតាមផ្លូវធ្វើដំណើរ គាត់ឃើញសាកសពជាច្រើនស្លាប់នៅតាមដងផ្លូវ និងក្នុងទឹក ។ ទឹកស្ទើរតែយកមកប្រើប្រាស់ពុំបាន ព្រោះមានសាកសពជាច្រើនអណ្តែតត្រៀបត្រា ។ សុខា បានធ្វើដំណើរ និងសម្រាកនៅដីឥដ្ឋ ស្រុកកៀនស្វាយពីរយប់ ហើយអំឡុងពេលធ្វើដំណើរ ក៏ដូចជាពេលសម្រាកមិនមានអង្គការណាមកផ្គត់ផ្គង់អាហារនោះទេ គឺម្នាក់ៗត្រូវរកដោយខ្លួនឯង ហើយអង្គការគ្រាន់តែប្រកាសថា អ្នកណាមានស្រុកកំណើតនៅទីណា សូមធ្វើដំណើរទៅទីនោះចុះ ។ នៅតាមផ្លូវធ្វើដំណើរ យោធាខ្មែរក្រហមបានឆែកឆេរអីវ៉ាន់អ្នកជម្លៀសទាំងអស់ដើម្បីរកអាវុធ ក្រែងមានអ្នកលួចលាក់ និងប្រកាសរកអតីតអ្នករដ្ឋការ ប៉ូលីស ទាហានជាដើម ។ ខ្មែរក្រហម ក៏បានឃាត់ និងធ្វើការសាកសួរពីប្រវត្តិរបស់ សុខា ដែរ ។ ខ្មែរក្រហមបានសួរគាត់ថា "មិត្តធ្វើអីពីមុនមក?" គាត់ថា "ខ្ញុំជាសិស្ស បន្ទាប់ពីចេញពីរៀនខ្ញុំទៅធ្វើកម្មករលីសែងនៅកំពង់ផែ គ្រាន់បានលុយបន្តិចបន្តួចយកមកចិញ្ចឹមខ្លួនឪពុកម្តាយ បងប្អូន" ។ ពេលនោះ ខ្មែរក្រហមតបវិញថា "ទេ! វានេះ មិនទំនងជាកម្មករលីសែងអីទេ សមតែជាកូនមូលធនអភិជនហើយ តាមមើល" ហើយ សុខា តបវិញដោយភាពទន់ភ្លន់ថា "ទេៗ ឪពុកម្តាយខ្ញុំជាកម្មករទេ" ។ ការឆ្លើយបែបនេះ គឺគាត់បាននឹកឃើញដល់សម្តីពូម្នាក់ដែលធ្លាប់រាប់អានគ្រួសាររបស់គាត់ដែលជាកម្មាភិបាលខ្មែរក្រហមមួយរូប នៅពេលដែលគាត់សម្រាកនៅដីឥដ្ឋ ។ ពូម្នាក់នោះបានផ្តាំគាត់ថា មានរឿងអ្វីក៏ដោយចូរកុំប្រាប់គេត្រង់ បើអ្នកណាសួរថាធ្វើអ្វីពីមុន ត្រូវប្រាប់ថា ធ្វើជាកម្មករបានហើយ ទើបរួចខ្លួន បើហ៊ានឆ្លើយថាជាអ្នកធ្វើការ ប្រាកដជាបាត់ខ្លួនមិនខាន ។ នៅទីនោះ សុខា និងប្រពន្ធ បានជួបឪពុកម្តាយ និងបងប្អូនទាំងអស់ ដោយគ្រួសារឪពុកម្តាយគាត់បានទៅដល់មុនគាត់បន្តិច ប៉ុណ្ណោះ ។

គ្រួសាររបស់ សុខា បានចេញដំណើរពីដីឥដ្ឋទៅស្នាក់នៅទឹកឃ្លាំងស្រុកល្វាឯមមួយយប់ ហើយបន្តទៅនៅភូមិព្រែកក្រូច និងភូមិបឹងផ្កោលប្រហែល១១ថ្ងៃ ។ អ្នកភូមិមូលដ្ឋានទាំងអស់ មានសមានចិត្តល្អណាស់ ហើយបានណែនាំ សុខា ឲ្យរកស្បៀងត្រៀមទុកធ្វើដំណើរផង ។ នៅទីនោះ សុខា បានទៅរកត្រីជាមួយអ្នកឯទៀតដើម្បីធ្វើត្រីងៀត ប្រហុក ផ្អក ជាដើម ទុកគ្រាន់ធ្វើដំណើរបន្តទៀត ព្រោះគាត់ឮអ្នកជិតខាងខ្សឹបខ្សៀវថា យើងគ្មានថ្ងៃនឹងត្រឡប់ទៅផ្ទះវិញទេ មានតែបន្តដំណើរទៅមុខទៀតប៉ុណ្ណោះ ។ នៅទីនោះបានមួយរយៈ គ្រួសារ សុខា បានបន្តដំណើរទៅដល់ភូមិពោធិ៍រៀងដែលមានសាច់ញាតិខាងឪពុកគាត់រស់នៅមួយចំនួន ។ អ្នកទាំងអស់គ្នាបានឃាត់ដំណើរគ្រួសារ សុខា ដោយប្រាប់ថា កុំចាំបាច់ទៅណាទៀតអី ទៅដល់ណាក៏ដូចគ្នាដែរ ។ ទោះជាយ៉ាងណា នៅពេលជួប បងប្អូនទាំងអស់គ្នាមិនអាចបញ្ចេញភាពរីករាយ ក៏ដូចជាការស្វាគមន៍បានទេ គឺបានត្រឹមតែដើរមកជិត ហើយលួចខ្សឹបប្រាប់ថា បើអង្គការឲ្យធ្វើអីធ្វើហ្នឹងចុះ ឲ្យយើងធ្វើថ្នង់ធ្វើគ ។ ទៅដល់ភូមិ អង្គការឲ្យប្រជាជនជម្លៀសទៅរស់នៅខ្ទមដែលអង្គការសង់រួចតាមគ្រួសាររៀងខ្លួន ។ សុខា រស់នៅបែកពីសមាជិកគ្រួសាររបស់គាត់ ដោយសារតែគាត់មានប្រពន្ធហើយ ។ អង្គការទុកពេលឲ្យអ្នកទាំងអស់គ្នារៀបចំកន្លែងស្នាក់នៅឲ្យបានសមរម្យរយៈពេលពីរថ្ងៃប៉ុណ្ណោះ ។ (បញ្ជាក់ សុខា នៅពេលនោះបានប្តូរឈ្មោះថា ប៊ុនធឿន)

បន្ទាប់មក អង្គការក៏ធ្វើការបែងចែកប្រជាជនទៅធ្វើការងារតាមការដ្ឋានរៀងៗខ្លួន ។ សុខា ត្រូវអង្គការចាត់ចូលជាក្រុមកម្លាំងស្រួច ដែលធ្វើការងារចល័តទៅតាមទិសដែលអង្គការត្រូវការ ឬសហករណ៍ដទៃ ដែលត្រូវការកម្លាំង ។ ប្រធានក្រុមរបស់គាត់ គឺមាន តាលន់ ជាប្រធាន និង តារុណ ជាអនុប្រធាន ។ ការងាររបស់ សុខា នៅកងចល័ត គឺធ្វើគ្រប់បែបយ៉ាងតាមទិសអង្គការ ដូចជា កាប់ដី រែកដី កាប់ព្រៃ លើកភ្លឺស្រែ ជាដើម ។ ចំណែក ប្រពន្ធគាត់មិនត្រូវបានចាត់តាំងឲ្យធ្វើការឆ្ងាយៗនោះទេ ដោយសារតែមានទម្ងន់ពោះ ហេតុនេះហើយអង្គការចាត់តាំងឲ្យនៅដេរស្បូវក្រងស្បូវ ដេរស្លឹក ជាមួយយាយៗនៅភូមិ ។ ចំពោះការហូបចុកនៅអំឡុងពេលនោះ គឺអង្គការបានចែករបបឲ្យពីរនាក់អង្ករមួយកំប៉ុងសម្រាប់ហូបមួយថ្ងៃ ហើយមិនមានម្ហូបអ្វីបន្ថែមទេ ។ ដោយសារតែការអាណិតស្រលាញ់ពីសំណាក់ប្រធានក្រុម អនុក្រុម អ្នកទាំងពីរតែងតែលបលួចផ្តល់ឲ្យដូចជា ម្ហូប ជាអំបិល ស្ករ ដល់ សុខាជានិច្ច ហើយ សុខា តបស្នងទៅវិញដោយឲ្យជាខោអាវ សារុង ដែលខ្លួននៅសេសសល់បន្តិចបន្តួច ។ ពេលនោះ ការរស់នៅ និងធ្វើការ

មិនទាន់មានការរឹតត្បិតទេ យើងអាចហូប និងរកអាហារជាឯកជនបាន មិនទាន់ហូបបាយរួមជាសហករណ៍ទេ ។ សុខា រស់នៅទីនោះបាន៨ខែ គឺចាប់ពីខែឧសភា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៦ ។

## ការជម្លៀសទៅកំពង់ចាម

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ វេលាម៉ោង ៥ព្រឹក អង្គការបានយករទេះមកដឹកប្រជាជនមួយចំនួន ក្នុងនោះ ក៏មានគ្រួសារ សុខា ដែរ គឺធ្វើដំណើរបន្តដោយគ្មានទិសដៅ ។ គ្រួសារសុខា សម្រេចចិត្តធ្វើដំណើរទៅកំពង់ចាម ដោយសារតែពេលទៅដល់ភូមិពោធិ៍រៀងដំបូង កងសន្តិសុខបានចាប់ខ្លួនឪពុករបស់គាត់ដោយដឹងពីប្រវត្តិ ។ តែថៃជន្យ ពេលដែលចាប់ទៅដល់មន្ទីរសន្តិសុខ ប្រធានសន្តិសុខនៅទីនោះ ស្គាល់ឪពុកគាត់ ហើយទុកឪពុកគាត់នៅទីនោះជាងដប់ថ្ងៃ តែមិនបានធ្វើទុកបុកម្នេញអ្វីទេ និងបានផ្ដែផ្ដាំទៀតថា នៅពេលខាងមុខអង្គការនឹងធ្វើការជម្លៀសប្រជាជនមួយចំនួនចេញពីភូមិនេះ ។ ប្រធានសន្តិសុខនោះ ប្រាប់ឲ្យឪពុករបស់គាត់ឲ្យចាកចេញពីភូមិនេះទៅនៅកន្លែងផ្សេងដើម្បីរក្សាជីវិតខ្លួន និងគ្រួសារ ។ ហេតុនេះហើយ ទើបគ្រួសារ សុខា ចាកចេញពីភូមិពោធិ៍រៀងនេះ ។ សុខា និងអ្នកឯទៀត ធ្វើដំណើរតាមរទេះរហូតដល់ស្វាយអន្ទរ ទើបមានឡានចាំទទួលបន្តនៅទីនោះ ដើម្បីទៅខាងស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ម៉ោងប្រហែល៨យប់ ទើបទៅដល់វត្តស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលជាទីសុំចតរបស់អ្នកជម្លៀស ។ សម្រាកនៅទីនោះបានមួយយប់ ទើបមានរទេះគោដឹកទៅបន្តទៀត ហើយសុខា និងគ្រួសារ បានទៅដល់ភូមិចំបក់មាស ឃុំអន្លង់ពេជ្រ ស្រុកចម្ការលើ ដែលជាព្រំប្រទល់រវាងខេត្តកំពង់ចាម និងកំពង់ធំ ។ ទៅដល់អង្គការចែកដីដើម្បីសាងសង់ខ្ទម និងដាំដំណាំ គឺមួយគ្រួសារបានដីក្បាល១៥ម៉ែត្រ និងបណ្ដោយ១០០ម៉ែត្រ ។

សុខា រំឭកថា ដីនៅទីនោះទំនេរច្រើនណាស់ យើងអាចឆ្ការយកថែមទៀតក៏បាន ឲ្យតែពូកែដាំដុះ អង្គការមិនហាមឃាត់នោះទេ ។ ចំពោះផលដំណាំដែលយើងដាំបាន គឺយើងមានសិទ្ធិទុកហូបខ្លួនឯងខ្លះ នៅសល់ប៉ុន្មាន គឺត្រូវប្រមូលយកទៅដាក់សហករណ៍ ។ ការហូបចុកពេលទៅដល់ដំបូង ក៏មិនទាន់ហូបរួមដែរ គឺអង្គការបានផ្ដល់ឲ្យម្នាក់ពាខាំអង្ករក្នុងមួយពេល ។ នៅចុងឆ្នាំ១៩៧៦ អង្គការចាប់ផ្ដើមឲ្យហូបបាយរួមនៅរោងបាយ តែទោះបីជាយ៉ាងណា ភូមិដែល សុខា រស់នៅមិនមានការរឹតត្បិតខ្លាំងនោះទេដោយសារតែប្រធានភូមិ ប្រធានសហករណ៍សុទ្ធសឹងតែជាអ្នកមានចិត្តករុណា ហើយក៏មិនសូវធ្វើបាបប្រជាជនដែរ ។

## ត្រូវយកទៅសម្លាប់ដោយសារចាក់ចម្រៀងខុស

សុខា ត្រូវអង្គការចាត់តាំងឲ្យទៅជីកទំនប់ ប្រឡាយ ទៅកាប់ព្រៃ និងលើកភ្លឺស្រែ ។ ក្រោយមក សុខា ត្រូវអង្គការចាត់តាំងឲ្យទៅលើកទំនប់ ហៅថា ទំនប់ទួលលោ ដោយមួយថ្ងៃ ត្រូវលើក៥ម៉ែត្រគូប ហើយអ្នកដែលធ្វើមិនបាននឹងមានបញ្ហាជាមិនខាន ។ មានពេលមួយ សុខា នៅចាំថា ពេលកំពុងតែលើកទំនប់ ស្រាប់តែអ្នកចាក់ចម្រៀងរបស់អង្គការ ចាក់ចម្រៀងខុស ដោយច្រំឡំចាក់ចម្រៀងរបស់លោក ស៊ិន ស៊ីសាមុត ។ គ្រាន់តែឮសំឡេងលោក ស៊ិន ស៊ីសាមុត ភ្លាម អ្នកធ្វើការទាំងឡាយនាំគ្នាស្រែកហ៊ោ ហើយបន្ទាប់មក ម្នាក់ៗនាំគ្នាយំ ដោយនឹកដល់អតីតកាលរបស់ខ្លួន ។ រំពេចនោះ អ្នកចាក់ចម្រៀងក៏ស្ទុះទៅបិទយ៉ាងលឿន តែជាអកុសលម្នាក់នោះត្រូវអង្គការយកទៅសម្លាប់ចោលតែម្ដង បន្ទាប់ពីមានរឿងនេះកើតឡើង ។

## បាត់បង់ឪពុកម្ដាយ និងបងប្អូន

នៅខែកក្កដា ឆ្នាំ ១៩៧៧ ឪពុកម្ដាយ និងបងប្អូនរបស់ សុខា ត្រូវអង្គការយកទៅសម្លាប់ជាមួយនឹងប្រជាជនថ្មីដទៃទៀត ។ បន្តដោយក្តីក្រៀមក្រំ សុខា រំឭកទៀតថា ប្រជាជនជម្លៀសស្ទើរតែមួយភូមិតែម្ដង ត្រូវអង្គការប្រមូលយកទៅសម្លាប់គ្មានសល់ ។ ពេលនោះ គឺមានការប្រកាសតាមមេក្រូ និង នីសារមកប្រកាសឲ្យប្រជាជនទាំងអស់សម្រាកការងារសិន ហើយឡើងទៅប្រជុំជាបន្ទាន់ ។ តែមុនហេតុការណ៍នេះប៉ុន្មានថ្ងៃ អង្គការបានកោះហៅប្រជាជនទាំងអស់ម្ដងហើយ ដោយកុហកថា ឥឡូវអង្គការសម្រេចជ្រើសរើសបងប្អូនមួយចំនួនចេញពីភូមិដើម្បីទៅនៅប្របតាមមាត់ផ្លូវពីភ្នំពេញទៅខេត្តសៀមរាប អង្គរវត្ត ព្រោះតាមផ្លូវទៅគឺស្ងាត់ណាស់ ។ ហេតុដូច្នេះអង្គការនឹងធ្វើដូះឲ្យបងប្អូនទាំងអស់គ្នានៅ ហើយអ្នកដែលមានឈ្មោះគឺត្រូវចាកចេញតែម្ដង ។ ប្រជាជនម្នាក់ៗនៅពេលនោះមានការសប្បាយរីករាយណាស់នឹងដំណឹងនេះ ដោយមិនបានដឹងថាជាឧបាយកលរបស់ខ្មែរក្រហមទេ ។

ក្រោយ ពេលប្រកាសឲ្យបងប្អូនទាំងអស់ ឡើងមកប្រជុំ

អង្គការបានប្រកាសឈ្មោះអ្នកដែលត្រូវចាកចេញ ក្នុងនោះក៏មានឈ្មោះឪពុកម្តាយ និងបងប្អូនប្រុសស្រីទាំងអស់របស់ សុខា ដែរ ។ លើកលែងតែគាត់ និងប្រពន្ធប៉ុណ្ណោះ ដែលគ្មានឈ្មោះទៅជាមួយគ្រួសារ ។ សុខា ឆ្ងល់ក្នុងចិត្ត ហើយក៏ឡើងទៅសុំ តាអ៊ួ ប្រធានភូមិ ដោយប្រាប់ថា “អ៊ំៗ ខ្ញុំសូមទៅតាមឪពុកម្តាយ បងប្អូនខ្ញុំផង តែអ្នកទាំងអស់គ្នាទៅ គឺបែកគ្នាហើយ?” ដោយទទូចច្រើនដងពេក ធ្វើឲ្យ តាអ៊ួ គាត់ខឹង ហើយតបថា “ម៉េច? មិត្តឯងអត់ស្តាប់អង្គការចាត់តាំងទេ ឬយ៉ាងម៉េច? មិត្តឯងគង់តែបានទៅទេ! គ្រាន់តែគេទៅមុនម្នាក់!” ។ សុខា នៅតែឆ្ងល់ក្នុងចិត្តជានិច្ច តែដោយក្តីភ័យខ្លាច គាត់ក៏ឈប់សុំតទៅទៀត ។ ក្រោយប្រជុំចប់ អ្នកដែលមានឈ្មោះទៅទាំងអស់ ត្រូវរៀបចំអីវ៉ាន់ចាកចេញជាបន្ទាន់ ដោយទៅជួបជុំគ្នានៅមន្ទីរពេទ្យស្រុកចម្ការលើ នឹងមានឡានទៅចាំទទួលនៅទីនោះ ។

ក្រោយមកទើប សុខា ដឹងថា អ្នកដែលអង្គការយកទៅទាំងនោះ គឺអង្គការយកទៅសម្លាប់នៅខាងភ្នំស្រីភ្នំប្រុសឯណោះ ។ គាត់ដឹងរឿងនេះ តាមការសាកសួរទៅកងឈ្លបដែលជូនប្រជាជនទាំងនោះទៅកាន់កន្លែងពិឃាតនោះ ។ ដោយការទុកចិត្ត និងអាណិតស្រឡាញ់ សុខា ទើបកងឈ្លបទាំងនោះប្រាប់ការពិតដល់រូបគាត់ ហើយស្នើឲ្យគាត់រក្សាការណ៍នេះឲ្យបាន បើអង្គការដឹងថារឿងនេះត្រូវបែកធ្លាយ គឺត្រូវស្លាប់ទាំងអស់គ្នាមិនខាន ។ ក្នុងភូមិរបស់ សុខា រស់នៅ គឺមានប្រជាជន១៨០គ្រួសារ តែត្រូវអង្គការយកទៅសម្លាប់អស់១០០គ្រួសារ ។ គាត់បានឲ្យដឹងថា ការយកទៅសម្លាប់នេះ មិនមែនតែភូមិរបស់គាត់មួយទេ គឺភូមិនៅជិតៗគាត់ក៏ដូចគ្នាដែរ ។ ភូមិខ្លះត្រូវអង្គការកម្ទេចស្ទើរគ្មានសល់ម្នាក់ ភូមិខ្លះនៅសល់តែពីរបីគ្រួសារប៉ុណ្ណោះ ។ រំពឹកទៅដល់បងប្អូនខ្មែរអ៊ីស្លាម សុខា ចាំថា បងប្អូនខ្មែរអ៊ីស្លាមដែលភាគច្រើនជម្លៀសមកពីខាងទន្លេ ត្រូវអង្គការប្រមូលទៅសម្លាប់ចោលទាំងអស់ ជាមួយនឹងប្រជាជនជម្លៀសផ្សេងទៀត រួមទាំងគ្រួសារគាត់ដែរ ។

## ជាភ័ព្វសំណាងរបស់ខ្ញុំឬ?

សុខា បានឲ្យដឹងថា ការប្រមូលប្រជាជននេះ គឺមានពីរដំណាក់កាល ក្រោមទ្រឹស្តីថា “ដីកស្មៅ ត្រូវដីកទាំងឫស” ។ នៅឆ្នាំ១៩៧៧ គឺប្រមូលម្តង ហើយក្រោយមកនៅឆ្នាំ១៩៧៨ អង្គការមានផែនការប្រមូលម្តងទៀត ចំពោះអ្នកដែលនៅសេសសល់ពីមុនមក ។ ដោយសារតែភាពស្មោះត្រង់ ភាពសកម្មការងាររបស់ សុខា ធ្វើឲ្យអ្នកគ្រប់គ្នាស្រឡាញ់អាណិតគាត់ ជាពិសេស គឺ តាអ៊ួ ដែលជាប្រធានភូមិតែម្តង ។ តាអ៊ួ តែងតែយកបាយដាក់ស្មុគមកហូបហើយសល់ប៉ុន្មានឲ្យទៅ សុខា ហូបទាំងអស់ ។ មួយរយៈក្រោយមក ប្រធានភូមិឈ្មោះ តាអ៊ួ និងកម្មាភិបាលមួយចំនួនទៀត ត្រូវអង្គការយកទៅកម្ទេច ដោយចោទថា ក្បត់ ព្រោះមិនបានធ្វើតាមបញ្ជារបស់អង្គការ មានការធូររលុងជាមួយប្រជាជន ។ ប្រធានភូមិថ្មី ដែលឡើងជំនួស តាអ៊ួ ឈ្មោះ តាស៊ីម ក៏ជាអ្នកករុណាដែរ ហើយក៏មានចិត្តអាណិតស្រឡាញ់ដល់ សុខា ដូចតា អ៊ួ ដែរ ។ សុខា តែងតែភ្ញាក់ក្នុងចិត្តថា នេះ ប្រហែលជាភ័ព្វសំណាង ជាបុណ្យកុសលដែលគាត់បានសាងហើយ ទើបបណ្តាលចិត្តឲ្យអ្នកគ្រប់គ្នា មានចិត្តករុណា និងសន្តោសគាត់ និងប្រពន្ធយ៉ាងនេះ ។

តមក សុខា ត្រូវអង្គការចាត់តាំងឲ្យទៅរែកទឹកស្រោចស្ពៃនៅព្រំប្រទល់ស្រុកចម្ការលើ និងស្រុកស្ទឹងត្រង់ ។ ចំណែកឯប្រពន្ធគាត់ គឺធ្វើការនៅផ្នែកឡក្បឿងនៅឯភូមិដដែល ។ ការដែលបញ្ជូន សុខា ទៅនេះ គឺប្រធានភូមិចង់ជម្លៀស សុខា ចេញពីការចាប់ខ្លួន ហើយផ្តាំ សុខា ទៀតថា បើនៅទីនោះ មានអ្នកប្លែកមុខទៅរកចង់ចាប់នោះ គឺធ្វើម៉េចកុំឲ្យគេចាប់ ហើយរត់ចូលព្រៃភ្លាម ព្រោះមានគេនៅក្នុងព្រៃដែរ ។

## ចុងបញ្ចប់នៃរបបខ្មែរក្រហម

ថ្ងៃមួយពេលដែល សុខា កំពុងតែស្រោចស្ពៃ ស្រាប់តែឃើញយន្តហោះ ហោះបាចគ្រាក់ពីលើ គាត់រើសគ្រាក់នោះ មកអាន ហើយពិភាក្សាគ្នា និងដឹងថា រណសិរ្សសង្គ្រោះជាតិកម្ពុជាបានវាយផ្តួលរំលំខ្មែរក្រហមហើយ ដូច្នេះយើងគួរតែបែកគ្នា ហើយត្រឡប់ទៅរកគ្រួសាររៀងៗខ្លួនវិញ ។ សុខា ក៏បានត្រឡប់មករកប្រពន្ធ និងកូននៅភូមិចំបក់មាសវិញ ។

ក្រោយរបបខ្មែរក្រហមដួលរលំ សុខា បានបាត់បង់សមាជិកគ្រួសារប្រាំបួននាក់ ។ សព្វថ្ងៃ ជិន សុខា ហៅ ទុំ អាយុ៦៨ឆ្នាំ មានប្រពន្ធ និងកូនស្រីប្រាំពីរនាក់ រស់នៅរាជធានីភ្នំពេញ ដោយបម្រើការងារនៅនាយកដ្ឋានសិល្បៈ ផ្នែកចម្រៀង និងបច្ចេកទេស ។

**ធាវ សារៈមុនិន្ទ**

# ម៉ៅ រ៉ាន់ កងអន្តរាគមន៍ចាប់ទូកនេសាទ និង កប៉ាល់ ឆ្លងចូលកម្ពុជាប្រជាធិបតេយ្យ

ជាអតីតកងទ័ពជើងទឹកខ្មែរក្រហមនៅកងពល១៦៤ដែលបានឈរជើងនៅកំពង់សោម ម៉ៅ រ៉ាន់ ធ្វើនៅក្នុងនាវាប្រដេញមួយក្នុងចំណោមកងនាវាប្រដេញ៤ ដែលប្រើសម្រាប់ធ្វើការអន្តរាគមន៍ និងចាប់អ្នកដែលចូលក្នុងដែនសមុទ្រកម្ពុជា រួចបញ្ជូនមកកោះតាងតាមការបញ្ជាផ្ទាល់ពីថ្នាក់លើ ។

ម៉ៅ រ៉ាន់ មានស្រុកកំណើតនៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ រ៉ាន់ បានរៀនត្រឹមថ្នាក់ទី៨ (សង្គមចាស់) នៅសាលាមួយក្នុងស្រុកបរសេដ្ឋ ហើយក៏ឈប់រៀន ពីព្រោះតែក្រោយពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុឆ្នាំ១៩៧០ មិនមានកន្លែងសម្រាប់រៀនត្រឹមត្រូវ ហើយប្រទេសជាតិក៏ធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលទៀត ។

នៅឆ្នាំ១៩៧២ រ៉ាន់ បានចូលធ្វើជាកងទ័ពខ្មែរក្រហមដោយមុនដំបូងគាត់ត្រូវបានជ្រើសរើសជាឈ្លបភូមិឃុំ ។ បន្ទាប់ពីធ្វើជាឈ្លបភូមិឃុំបានមួយរយៈ គាត់ត្រូវបានបញ្ជូនមកនៅស្រុក ។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ រ៉ាន់ ត្រូវបានបញ្ជូនឡើងមកតំបន់៣៣ ស្ថិតនៅខេត្តកំពង់ស្ពឺ ដែលនៅពេលនោះ គណៈតំបន់មានឈ្មោះ អន់ ។ រ៉ាន់ នៅកងពលទី៣ វរសេនាធំ២១ វរសេនាតូច៤១០ ហើយគាត់មានតួនាទីជាប្រធានអនុសេនាតូច ។ កងពលរបស់គាត់ត្រូវឡើងទៅវាយតាមបណ្តោយផ្លូវជាតិលេខ៤ ចាប់តាំងពីពេជ្រនិលរហូតដល់ទីក្រុងភ្នំពេញ ។

ក្រោយពីរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ



អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស របបកម្ពុជាប្រជាធិបតេយ្យ ទស្សនកិច្ចកងទ័ពជើងទឹក

១៩៧៥ កងពលរបស់ វ៉ាន់ មិនបានចូលទីក្រុងទេ គឺមកបោះទីតាំងនៅបែកចានវិញ ។ ពីរថ្ងៃក្រោយមក កងពលរបស់គាត់ត្រូវបានដកទៅនៅកំពង់សោម ។ វ៉ាន់ បញ្ជាក់ថា ដោយសារតែកំពង់សោមមិនទាន់បានរំដោះទាំងស្រុង ដូច្នេះហើយបានជាកងពលរបស់គាត់ទៅដល់កន្លែងណាគឺត្រូវតែវាយនៅកន្លែងនោះតែម្ដង ។ បើមិនមានទាហាន លន់ នល់ សេសសល់នោះទេ គឺគាត់ឈរជើងនៅកន្លែងនោះតែម្ដង ។ បន្ទាប់ពីមកដល់កំពង់សោមបានមួយថ្ងៃ គាត់ក៏ត្រូវបានបញ្ជូនទៅរាម ដែលនៅពេលនោះ គណៈកងពលមិនទាន់ទៅដល់ទេ ។ បន្ទាប់ពី វ៉ាន់ នៅរាមបានរយៈពេលពីរថ្ងៃ ប្រធានវរសេនាតូចឈ្មោះ ហឹម បានប្រមូល និងបែងចែកកម្លាំងទៅប្រចាំការនៅកោះតាង ដែលមានគ្នាមិនដល់២០នាក់ផងនៅពេលនោះ ពីព្រោះកងទ័ពនៅកងពលផ្សេងៗមិនទាន់បានមកប្រមូលផ្ដុំគ្នានៅឡើយទេ ។ ដូច្នេះហើយ បានជាខ្មែរក្រហមប្រើវិធីសាស្ត្រមួយនោះគឺ អ្នកណាមកមុន គឺត្រូវតែចេញទៅមុន ដោយបានដឹកយកទៅប្រចាំការនៅកោះឆ្ងាយៗ ដូចជា កោះតាង កោះព្រីង កោះពូលូវៃ ជាដើម ។

វ៉ាន់ បានរៀបរាប់ថា នៅពេលទៅដល់កោះតាងដំបូង កងទ័ពមានការលំបាកក្នុងការរស់នៅ ដោយសារតែកោះតាងព័ទ្ធជុំវិញសុទ្ធតែព្រៃ ដូច្នេះហើយគ្មានជម្រើសអ្វីក្រៅពីបោះតង់នៅតាមមាត់សមុទ្រដើម្បីសម្រាកនោះទេ ។ បន្ទាប់ពីនៅលើកោះតាងបានរយៈពេល៤-៥ថ្ងៃ ខ្មែរក្រហមក៏បានបញ្ជូនកម្លាំងបន្ថែមទៀតដែលធ្វើឲ្យកម្លាំងឈរជើងនៅលើកោះកើនឡើងរហូតដល់ប្រហែល ៣០នាក់ ។ ក្រោយមកកម្លាំងដែលឈរជើងប្រចាំការនៅលើកោះតាងទាំងនោះ ត្រូវបានថ្នាក់លើដកយកមួយចំនួនមកវិញ ដោយឲ្យទៅការពារកោះក្រចកសេះ ដូច្នោះហើយបានជាកម្លាំងខ្មែរក្រហមដែលប្រចាំការលើកោះតាងនៅសល់តែជាង១០នាក់តែប៉ុណ្ណោះ ។

វ៉ាន់ ក៏បានបញ្ជាក់ទៀតថា មានកប៉ាល់ ម៉ាយ៉ាហ្គេ របស់អាមេរិកាំងធំមួយបានបើកមកជិតកោះតាង ហើយពេលនោះនាវារបស់ខ្មែរក្រហមដែលសល់ពីរបប លន់ នល់ បានទៅធ្វើអន្តរាគមន៍ និងបាននាំកប៉ាល់នោះទៅខាងកើតកោះ ។ បន្ទាប់មក ខ្មែរក្រហមក៏បានបញ្ជូនកម្លាំងជំនួយទៅកោះតាង បន្ថែមទៀតដែលធ្វើឲ្យកម្លាំងខ្មែរក្រហមកើនឡើងប្រមាណ៣០នាក់ ។

ពីរថ្ងៃបន្ទាប់ពីចាប់កប៉ាល់ ម៉ាយ៉ាហ្គេ យន្តហោះអាមេរិកាំងក៏បានមកធ្វើអន្តរាគមន៍ ។ ប៉ុន្តែ មុនរយៈកាលនោះ ខាងទាហានអាមេរិកាំងបានមកទម្លាក់កម្លាំងជុំវិញរួចហើយ ។ ទាហានអាមេរិកាំង ចាប់ផ្ដើមបើកការប្រយុទ្ធជាទ្រង់ទ្រាយធំដោយនាំកម្លាំងមកជាច្រើន មានដូចជា យន្តហោះសម្រាប់ ទម្លាក់គ្រាប់ជាដើម ។ នៅពេលដែលយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់ ខាងកម្លាំងខ្មែរក្រហមមិនអាចធ្វើអ្វីបានឡើយ ដោយសារតែខ្វះខាតអាវុធ គឺមានតែកាំភ្លើងអាកា និងអ៊ឹម១៦ សម្រាប់បាញ់ទម្លាក់យន្តហោះអាមេរិកាំងតែប៉ុណ្ណោះ ។ បន្ទាប់មក ខាងកម្លាំងខ្មែរក្រហមបានជីករណ្ដៅត្រង់សេ សម្រាប់លាក់ខ្លួនដើម្បីឲ្យផុតពីការទម្លាក់គ្រាប់របស់អាមេរិកាំង ខ្មែរក្រហមបានបាញ់ទម្លាក់យន្តហោះអាមេរិកាំងនៅទីងកន្លែងពីរគ្រឿងដងដែរ ។ វ៉ាន់ បានបញ្ជាក់ថា បន្ទាប់ពីបាញ់ទម្លាក់ឧទ្ធម្ភាគចក្ររបស់អាមេរិកាំងធ្លាក់ ទាហានអាមេរិកាំងដែលជិះនៅលើឧទ្ធម្ភាគចក្រនោះបានហែលឡើងគោក ។ នៅពេលនោះទាហានអាមេរិកាំងមានចំនួនច្រើន ហើយខាងខ្មែរក្រហមក៏បានបាញ់សម្លាប់តែម្ដង ។

បន្ទាប់ពីបានបាញ់ទម្លាក់ឧទ្ធម្ភាគចក្រ និងសម្លាប់ទាហានអាមេរិកាំងហើយ ទ័ពជើងអាកាសអាមេរិកាំងចាប់ផ្ដើមវាយប្រហារកាន់តែខ្លាំងឡើង ។ ដោយមិនមានសម្ភារសឹកគ្រប់គ្រាន់ដើម្បីប្រយុទ្ធជាមួយទាហានអាមេរិកាំង ការប្រយុទ្ធគ្នាបានបណ្ដាលឲ្យខាងខ្មែរក្រហមស្លាប់៧នាក់នៅលើកោះ និងជាច្រើននាក់ទៀតនៅលើទូក ហើយអ្នកសេសសល់ផ្សេងទៀតក៏បានរត់ចូលក្នុងព្រៃនៅពេលដែលទាហានអាមេរិកាំងឡើងលើកោះ ។ បន្ទាប់ពីឈ្នះលើកងទ័ពខ្មែរក្រហមនៅលើកោះតាង ទ័ពអាមេរិកាំងមិនបានចូលក្នុងព្រៃទេ ប៉ុន្តែបែរជារាយកម្លាំងរបស់ខ្លួននៅលើកោះទៅវិញ ។ ទាហានអាមេរិកាំងបានលើកសាកសពដែលស្លាប់រប៉ាត់រប៉ាយដាក់លើឧទ្ធម្ភាគចក្រ ដើម្បីយកទៅទុកនៅកន្លែងមួយផ្សេងទៀត ។

វ៉ាន់ក៏បានបន្ថែមទៀតថា ក្រោយពីការប្រយុទ្ធ មានទាហានអាមេរិកម្នាក់នៅរស់ ហើយបានដើរជួបប្រទះកម្លាំងខ្មែរក្រហម ហើយក៏ត្រូវបានខ្មែរក្រហមបាញ់សម្លាប់ ។ យន្តហោះអាមេរិកាំងមិនត្រឹមតែទម្លាក់គ្រាប់នៅកោះតាងនោះទេ ប៉ុន្តែក៏ទម្លាក់នៅកំពង់

សោម នៅរាម ដែលបណ្តាលឲ្យប៉ុស្តិ៍វិទ្យុ និងផែអន្តរជាតិខូចខ្ទីស្ទើរតែទាំងស្រុង ។ ប្រហែលជាកន្លះខែក្រោយពីការប្រយុទ្ធគ្នានៅលើកោះតាង វ៉ាន់ ត្រូវបានដកមកកំពង់សោមដើម្បីបង្កើតជាកងថ្មី នៅពេលនោះអ្នកដែលត្រូវបានដកមកនោះ គឺមានតែប្រធានកង ប្រធានក្រុម ។

វ៉ាន់ បានបន្តទៀតថា ក្រោយពីប្រយុទ្ធជាមួយអាមេរិកាំងនៅកោះតាង កងទ័ពវៀតណាមបានចាប់ផ្តើមវាយយកកោះត្រល់ កោះក្រចកសេះជាដើម ដែលធ្វើឲ្យកងទ័ពខ្មែរក្រហមទាំងអស់បានស្លាប់ និងត្រូវបានចាប់ខ្លួន ។ បន្ទាប់ពីត្រូវបានបញ្ជូនទៅកោះត្រល់មួយរយៈ យោធាខ្មែរក្រហមដែលត្រូវបានចាប់ខ្លួនទាំងនោះត្រូវបានដោះលែង បន្ទាប់ពីមានការចរចាជាមួយខាងភាគីវៀតណាមតាមរយៈផ្លូវការទូត ។

ក្រោយមកទៀត វ៉ាន់ ត្រូវបានបញ្ជូនមកនៅខាងនាវាចម្បាំងនៅកំពង់សោមសម្រាប់ធ្វើការអន្តរាគមន៍ និងចាប់ទូកដែលចូលដែនសមុទ្រកម្ពុជាដោយខុសច្បាប់ ។ នៅពេលនោះប្រធានកងពលឈ្មោះ មាស មុត និង តាសារឿន ជាអ្នកគ្រប់គ្រងនាវាចម្បាំងទាំង ៨គ្រឿង ។ ជាទូទៅ មុនចុះអន្តរាគមន៍ និងចាប់ទូក ដូចជាទូកនេសាទថៃ ឬក៏ទូកដែលចូលដែនសមុទ្រកម្ពុជា កងនាវាចម្បាំងតែងតែចេញទៅអន្តរាគមន៍ដោយមានបទបញ្ជាផ្ទាល់ពីថ្នាក់លើ ។ ជាក់ស្តែង នៅដើមឆ្នាំ១៩៧៨ កងនាវារបស់ វ៉ាន់ បានចាប់ និងបញ្ជូនទូកនេសាទថៃ២គ្រឿង ដែលក្នុងទូកនីមួយៗមានមនុស្ស ប្រហែលជា ៣០នាក់ ។ ទូកនេសាទថៃច្រើនតែពន្លៀនទូកចូលក្នុងដែនសមុទ្រកម្ពុជានៅខែប្រាំង ពីព្រោះតែមិនសូវមានរលកធំៗ ។ បន្ទាប់ពីធ្វើការអន្តរគមន៍ទូកនេសាទថៃហើយ ថ្នាក់លើក៏បានបញ្ជាឲ្យបញ្ជូនអ្នកនេសាទថៃទាំងនោះទៅដែរាម ។ វ៉ាន់ បញ្ជាក់ថា កងទ័ពដែលឈរជើងនៅលើកោះក៏រងគ្រោះមិនតិចដែរ ដោយសារយន្តហោះរបស់ថៃហោះបាចថ្នាំពីលើអាកាសដែលធ្វើឲ្យពុលរាគស្ទើតែហ្នឹងស្លាប់ ។ ក្រៅពីចាប់ទូកនេសាទថៃ ខ្មែរក្រហមក៏បានអន្តរគមន៍និងចាប់ទូកក្តោងរបស់ជនជាតិអាមេរិកាំងមួយទៀតដែរ ប៉ុន្តែមិនមែនកងនាវារបស់ វ៉ាន់ ជាអ្នកចាប់នោះទេ ពីព្រោះគាត់បានត្រឹមតែឃើញទូកក្តោងនោះត្រូវបានគេនាំទៅដៃមួយផ្សេងទៀតនៅអូឈើទាល ។ បន្ថែមពីលើការធ្វើអន្តរគមន៍ទៅលើទូកដែលចូលមកដែនសមុទ្រកម្ពុជា កងនាវារបស់ វ៉ាន់ ក៏មានតួនាទីដោយឡែកមួយទៀតដែរ គឺសម្រាប់ជូនថ្នាក់លើ ដូចជា មាស មុត ទៅប្រជុំតាមកោះ ។

ក្រោយពីកងទ័ពវៀតណាមយកឈ្នះលើកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧៩ វ៉ាន់ បានជួប មាស មុត ម្តងទៀត ហើយបានរៀបចំអង្គភាពមួយផ្សេងទៀតនៅចន្លោះពីចុងឆ្នាំ១៩៧៩ ទៅដើមឆ្នាំ ១៩៨០ ដែលកងពលនោះគឺជាកងពល៣៧០ ដែលមានឈ្មោះ សឹង ជាប្រធាន (តែក្រោយមកស្លាប់ក្នុងពេលប្រយុទ្ធគ្នា) ។ បន្ទាប់មក កងពល៣៧០ របស់ វ៉ាន់ បានវៃតាមផ្លូវជាតិលេខ៤មកកើត រហូតមកទល់ខេត្តកំពង់ស្ពឺ ប៉ុន្តែជាអកុសល នៅពេលដែលកំពុងវាយជាមួយកងទ័ពវៀតណាម នៅពេជ្រនិលក្នុងឆ្នាំ១៩៨៥ វ៉ាន់ បានត្រូវអំបែងគ្រាប់បេ៤០ ខ្ទាតចំហើយក៏ផ្លាក់ខ្លួនពីការចាប់តាំងពីពេលនោះមក ។

**ស៊ាង ចិន្តា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

**(តពីលេខមុន)**

## ៧) សេចក្តីសន្និដ្ឋាន

ជំពូកនេះបានកំណត់អំពីលក្ខណៈសំខាន់មួយចំនួននៃអត្តសញ្ញាណខាងក្រៅ និងសំខាន់របស់ជនជាតិចាម ។ ជនជាតិចាមគឺជាបច្ចាជនរបស់មនុស្សរស់នៅដែនសមុទ្រដែលមានទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយប្រជាជនម៉ាឡាយូកាត់ប៉ូលីណាស៊ីដែលរស់នៅក្នុងអាស៊ីអាគ្នេយ៍ជាមួយគ្នា ជាពិសេស អ្នកដែលរស់នៅប្រជុំកោះអាស៊ីអាគ្នេយ៍ ។ ការរលាយបាត់ចម្ប៉ានៅក្នុងដៃរបស់អ្នកវៀតទីវៀតណាម បណ្តាលឲ្យជនជាតិចាមមានទំនាក់ទំនងច្រើនជាងមុនជាមួយអ្នកកាន់សាសនាអ៊ីស្លាម និងប្រទេសជិតខាង ។ ជនជាតិចាមតែងតែរក្សានូវទស្សនវិស័យអន្តរជាតិនៅក្នុងប្រវត្តិសាស្ត្រ ។ ពួកគេចូលរួមនៅក្នុងពាណិជ្ជកម្ម សង្គ្រាម និងការទូតតាមសមុទ្រជាមួយដៃគូនៅជុំវិញសមុទ្រចិនខាងត្បូង ។

លក្ខណៈសំខាន់មួយទៀតនៃអត្តសញ្ញាណជាតិពន្ធុស្នូលរបស់ពួកគេ គឺការបាត់បង់ទឹកដីទៅវៀតណាម និងការលំបាករបស់ពួកគេក្នុងការស្វែងរកការជ្រកកោននៅកម្ពុជា ដែលនៅទីនោះពួកគេបានក្លាយជាជនជាតិភាគតិច និងបានប្រកាន់យកអត្តសញ្ញាណសាសនាស្នូលថ្មីមួយជាអ្នកកាន់សាសនាអ៊ីស្លាម ។ បន្ទាប់ពីសង្គ្រាមជាច្រើន




វិហារអ៊ីស្លាមធ្វើពីដើមឫស្សី និងស្លឹក ស្ថិតនៅជំរំសាយធូ ជាប់ព្រំដែនខ្មែរថៃ ឆ្នាំ១៩៨៥

ឆ្នាំជាមួយវៀតណាម ជនជាតិចាមបានបាត់បង់រាជធានីវីចាយ៉ារបស់ពួកគេនៅក្នុងឆ្នាំ១៤៧១ ។ នេះបានបណ្ដាលឲ្យមានការបំលាស់ទីលើកដំបូងរបស់ជនជាតិចាមមកកាន់កម្ពុជា ។ ចម្ប៉ាលែងក្លាយជារាជាណាចក្រទៀតហើយនៅក្នុងឆ្នាំ១៨៣៥ នៅពេលដែលទឹកដីចុងក្រោយត្រូវបាត់បង់ទៅវៀតណាម ។ នៅចន្លោះឆ្នាំ១៤៧១ និង១៨៣៥ ជនជាតិចាមបានភៀសខ្លួនមកកាន់កម្ពុជាក្នុងដំណាក់កាលជាច្រើន ។ បើទោះបីជាមានប្រវត្តិជម្លោះជាច្រើនរវាងរាជាណាចក្រទាំងពីរនេះក្ដី ជនជាតិខ្មែរបានទទួលស្វាគមន៍អ្នកផ្លាស់ទីលំនៅចាមដែលបានតាំងទីលំនៅនៅលើដីទំនាបភាគឦសាន្ត (ត្រង់ម្ដុំខេត្តកំពង់ចាម) និងស្របតាមដងទន្លេមេគង្គ ដែលនៅកន្លែងទាំងនេះ ពួកគេបានបង្កើតឡើងវិញនូវអត្តសញ្ញាណនយោបាយរបស់ពួកគេជាអ្នកកាន់សាសនាអ៊ីស្លាមគាំទ្រព្រះរាជាណាចក្រកម្ពុជា ។

នៅកម្ពុជា ជនជាតិចាមបានជួបអ្នកកាន់សាសនាអ៊ីស្លាមជនជាតិម៉ាឡេ ឬក៏ជ្វា ដែលបានបោះទីលំនៅនៅកម្ពុជាមុនការមកដល់របស់ជនជាតិចាមយ៉ាងយូរ ។ ពីជ្វា អ្នកផ្លាស់ទីលំនៅជនជាតិចាមជាច្រើនបានផ្លាស់ប្ដូរសាសនាទៅជាអ៊ីស្លាម ។ ដូច្នេះ អត្តសញ្ញាណសាសនាអ៊ីស្លាមរបស់ជនជាតិចាម តែងតែមានជាប់ពាក់ព័ន្ធជាមួយជនជាតិជ្វា ដែលតែងតែហាក់ដូចជាដើរតួជាមនុស្សកណ្ដាលរវាងជនជាតិចាម និងខ្មែរ សូម្បីតែនៅក្នុងសង្គមបច្ចុប្បន្ននេះ ។ កាលពីអតីតកាល ជនជាតិជ្វា ជួយជនជាតិចាមឲ្យបានតាំងទីលំនៅនៅកម្ពុជា និងបានផ្លាស់ប្ដូរសាសនារបស់ពួកគេទៅអ៊ីស្លាម ។ សព្វថ្ងៃ ជនជាតិជ្វាដែលនិយាយភាសាខ្មែរបានល្អជាងជនជាតិចាម ប៉ុន្តែ មិននិយាយភាសាចាម ឈរនៅចន្លោះជនជាតិចាម និងខ្មែរ ពាក់ព័ន្ធនឹងភាពស្រដៀងគ្នា និងការធ្វើសមាហរណកម្មទៅសហគមន៍សង្គមខ្មែរ ។ តាមពិតពាក្យថា ខ្មែរអ៊ីស្លាម ដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលកម្ពុជាដើម្បីហៅអ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ប្រើត្រឹមត្រូវជាងជាមួយជនជាតិជ្វា ជាជាងជាមួយជនជាតិចាម ព្រោះជនជាតិជ្វាមិនមានភាសាដើមទេ ។ ដូច្នេះ ជនជាតិជ្វាបានជួយ និងនៅតែជួយសមាហរណកម្មជនជាតិចាមចូលជាមួយជនជាតិខ្មែរ ។ បើទោះបីជា ជនជាតិភាគតិចតូចមួយនៅកម្ពុជាសព្វថ្ងៃនេះក៏ដោយ ជនជាតិចាមមានប្រវត្តិយូរអង្វែងក្នុងការធ្វើទំនាក់ទំនង និងប្រឈមមុខជាមួយខ្មែរ ដែលបានបន្តទៅជាមូលដ្ឋាននៃអត្តសញ្ញាណជាតិពន្ធុស្នូលរបស់ជនជាតិចាម ។ នៅត្រង់ចំណុចខ្ពស់បំផុតនៃអាណាចក្រអង្គរ ចម្ប៉ាមានកម្លាំងខ្លាំងគ្រប់គ្រាន់ដែលអាចលុកលុយ និងលួចប្លន់ក្រុងអង្គរបានសម្រេចនៅក្នុងឆ្នាំ១១៧៧ ។ ប៉ុន្តែ ខ្មែរបានឆ្លើយតបយ៉ាងឆាប់រហ័សតាមរយៈការឈ្លានពានវីចាយ៉ាក្នុងឆ្នាំ១២០៣ និងបានគ្រប់គ្រងរាជធានីនេះ អស់រយៈពេល១៧ឆ្នាំរហូតដល់ឆ្នាំ១២២០ ។ ប្រវត្តិចាម និងខ្មែរ មានលក្ខណៈស្រដៀងគ្នាក្នុងករណីមួយចំនួន ។ ជនជាតិទាំងពីរនេះ សុទ្ធតែធ្លាប់មានបទពិសោធន៍បាត់បង់ដីទៅវៀតណាម ។ ខណៈដែលចាមបានបាត់បង់អាណាចក្រទាំងមូល កម្ពុជាបាត់បង់តែដីសណ្ដមេគង្គខាងក្រោមប៉ុណ្ណោះ ។ ការរលាយបាត់បង់ចម្ប៉ាមានន័យថា កម្ពុជាលែងមានតំបន់នៅចន្លោះកណ្ដាលមួយសម្រាប់ការពារប្រទេសប្រឆាំងនឹងការវាតទីជាបន្តរបស់វៀតណាម ។

បើទោះបីជា ជនជាតិចាមបាត់បង់ប្រទេសរបស់ពួកគេក៏ដោយ រាជធានីរបស់ចាមមានអាយុកាលវែងជាងក្រុងអង្គរ ។ អង្គរត្រូវបានបោះបង់ចោលនៅក្នុងឆ្នាំ១៤៣២ ក្រោមការវាយប្រហាររបស់ថៃ ខណៈដែលរាជធានីវីចាយ៉ារបស់ចម្ប៉ាបានបាត់បង់នៅក្នុងឆ្នាំ១៤៧១ ក្រោមការវាយប្រហាររបស់វៀតណាម ។ ខណៈដែលខ្មែរមានព្រះបាទជ័យវរ្ម័នទី៧ជាស្ដេច និងមេទ័ពដ៏អស្ចារ្យ ជនជាតិចាមមាន ឆេ បុង ង៉ា ជាស្ដេចវីរបុរសរបស់ពួកគេ ដែលបានបំភិតបំភ័យវៀតណាមអស់រយៈពេល២០ឆ្នាំ ។ ប្រវត្តិទំនាក់ទំនងការប្រឈមមុខ និងភាពស្រដៀងគ្នារបស់ចាមជាមួយខ្មែរបានបង្កើតនូវព្រំដែនជាតិពន្ធុមួយយ៉ាងច្បាស់លាស់រវាងចាម និងខ្មែរ ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនេះ នៅតែខ្លាំង ទាំងនៅក្នុងសតិសម្បជញ្ញៈរបស់ចាម និងខ្មែរ ដោយសារជនជាតិទាំងពីរនេះស្រលាញ់អតីតកាលរុងរឿងបំផុតរបស់ខ្លួនដូចគ្នា ។

នៅក្នុងអំឡុងពេលនៃរបបអាណានិគម អត្តសញ្ញាណជាតិពន្ធុត្រូវបានពង្រឹង និងធ្វើឲ្យស្របច្បាប់បន្ថែមតាមរយៈច្បាប់អាណានិគមដែលបានចាត់ទុកជនជាតិចាមជាជនជាតិភាគតិចនៅកម្ពុជា ប៉ុន្តែមិនមែនជា "ជនបរទេស" ។ នៅក្រោមរបបព្រះបាទនរោត្តមសីហនុ ពួកគេត្រូវបានគិតថាជា "ខ្មែរ" កាន់សាសនាអ៊ីស្លាម ។

រយៈកាលនៃការពង្រីកធំបំផុតនៃអត្តសញ្ញាណសាសនា

របស់ចាម គឺប្រហែលជាក្នុងសតវត្សរ៍ទី១៧ នៅពេលដែលព្រះរាជាខ្មែរបានផ្លាស់ប្តូរសាសនាទៅជាអ៊ីស្លាម ។ ព្រះបាទរាមាធិបតីទី១ បានគ្រប់គ្រងកម្ពុជាពីឆ្នាំ១៦៤២ ដល់១៦៥៨ ។ ព្រះអង្គបានឡើងកាន់អំណាចដោយមានជំនួយពីមេទ័ពចាម និងបានផ្លាស់ប្តូរទៅកាន់សាសនាអ៊ីស្លាម ដើម្បីស្វែងរកការលើកលែងទោសសម្រាប់អំពើបាបដែលព្រះអង្គបានប្រព្រឹត្តនៅពេលដណ្តើមរាជបល្ល័ង្ក ទោះបីជាប្រភពខ្លះបាននិយាយថា ព្រះអង្គរៀបអភិសេកជាមួយស្ត្រីកាន់សាសនាអ៊ីស្លាម និងត្រូវតម្រូវឲ្យប្តូរសាសនា ។ នៅក្នុងពេលគ្រងរាជ្យ ប្រទេសកម្ពុជាស្ទើរតែត្រូវផ្លាស់ប្តូរទៅកាន់សាសនាអ៊ីស្លាមទៅហើយ ។ អ្នកបម្រើរាជសំណាក់ និងមន្ត្រីព្រះបរមរាជវាំង ត្រូវបានផ្លាស់ប្តូរសាសនា ។ ព្រះវិហារសាសនាអ៊ីស្លាមត្រូវបានសាងសង់នៅទូទាំងប្រទេស ដែលមានទាំងព្រះវិហារមួយនៅភូមិឃ្លាំងស្បែក ដែលសព្វថ្ងៃនេះគេឲ្យឈ្មោះថា អាល់ អាក់បា ឌូបៃ ឃ្លាំងស្បែក (Al Akbah Dubai Khleang Sbek) ។ ជនជាតិចាមត្រូវបានតែងតាំងឲ្យកាន់តំណែងធំៗនៅក្នុងរដ្ឋាភិបាល ។ ព្រះរាជាបានបោះបង់នូវពិធីសាសនាបែបព្រះពុទ្ធសាសនា ។ ការចិញ្ចឹម សម្លាប់ និងលក់ដូរសត្វជ្រូកមិនត្រូវបានលើកទឹកចិត្តទេ ប្រសិនបើមិនត្រូវហាមប្រាមនោះ ។ ជាសរុបមក នៅក្នុងរជ្ជកាលរបស់ព្រះបាទរាមាធិបតីទី១ ជនជាតិចាមបានបង្កើតនូវគ្រឹះសម្រាប់អត្តសញ្ញាណសាសនាអ៊ីស្លាមរបស់ពួកគេជាជនជាតិភាគតិចសំខាន់មួយនៅកម្ពុជា ។

នៅក្រោមរបប លន់ នល់ អត្តសញ្ញាណនយោបាយជនជាតិចាម បានផ្លាស់ប្តូរពីគាំទ្ររបបរបស់ព្រះបាទនរោត្តម សីហនុ និងញាតិវង្សរបស់ព្រះអង្គ ទៅជាការបែកបាក់មួយតាមបន្ទាត់នយោបាយ ។ អ្នកដែលរស់នៅក្រោមការគ្រប់គ្រងរបស់ក្រុមកុម្មុយនីស្តបានចូលរួមដោយស្ម័គ្រចិត្ត និងជួនកាលត្រូវបង្ខំឲ្យចូលរួមនៅក្នុងការតស៊ូបដិវត្តន៍ដើម្បីផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ ខណៈដែលជនជាតិចាមខ្លះនៅទីក្រុង ត្រូវបានហៅឲ្យចូលរួមកងទ័ពសាធារណរដ្ឋខ្មែរ ។ របបនេះក៏បានបង្កើតកងចាម ពិសេសមួយ ដឹកនាំដោយមេទ័ព ឡេះ កូសេម ។ នៅក្នុងអំឡុងពេលសង្គ្រាម គំនិតអំពីអត្តសញ្ញាណជាតិពន្ធុចាមជាមួយនឹងប្រភពពីចម្ប៉ាត្រូវបានដុតបញ្ឆេះដើម្បីឲ្យពួកគេអាចចូលរួមសម្ព័ន្ធភាពនយោបាយជនជាតិភាគតិចមួយឈ្មោះថា ហ្វុលរ៉ូ (FULRO) ដើម្បីប្រឆាំងនឹងកុម្មុយនីស្តខ្មែរក្រហម និងវៀតណាម និងដណ្តើមយកចម្ប៉ា និងដីសណ្តទន្លេមេគង្គភាគខាងក្រោមមកពីវៀតណាមវិញ ។

## ជំពូក៤

## បញ្ហាប្រឈមនៃអត្តសញ្ញាណស្មុល : បទពិសោធន៍របស់ជនជាតិចាមនៅក្នុងរបបខ្មែរក្រហម

ខ្មែរក្រហមបានឡើងកាន់អំណាចនៅកម្ពុជាអស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ពេលយើងលើកយកសម័យកាលនេះមកប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រចាមទាំងមូល សម័យកាលនេះ មានរយៈខ្លីណាស់ ប៉ុន្តែ មានរឿងហេតុជាច្រើនដែលបានកើតឡើងទាក់ទងទៅនឹងអត្តសញ្ញាណរបស់ជនជាតិចាមដែលយើងត្រូវលើកយកមកពិភាក្សារៀបរាប់នៅក្នុងជំពូកនេះ ។ ជំពូកនេះនឹងពិភាក្សាពីបទពិសោធន៍របស់ជនជាតិចាមនៅក្នុងរបបខ្មែរក្រហម ដោយបង្ហាញថាទង្វើដែលខ្មែរក្រហមបានធ្វើមកលើជនជាតិចាមគឺជាអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិចាម ។ ទង្វើនេះធ្វើឲ្យមានការផ្លាស់ប្តូរអត្តសញ្ញាណបន្ទាប់បន្សំរបស់ជនជាតិចាម ។ ឧទាហរណ៍ដូចជា និកាយសាសនា នយោបាយ និងសេដ្ឋកិច្ច នៅទសវត្ស ឆ្នាំ១៩៨០ និងបន្តប៉ះពាល់សហគមន៍ ចាមរហូតដល់សព្វថ្ងៃ ។

ជាបឋម ជំពូកនេះនឹងមើលទៅលើការឡើងកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ និងបង្ហាញទិដ្ឋភាពទូទៅនៃរបបខ្មែរក្រហមមុនពេលឈានទៅដល់ការវិភាគពីច្បាប់មូលដ្ឋានរបស់ខ្មែរក្រហមស្តីអំពីអ៊ីស្លាម និងបំណងរបស់ខ្មែរក្រហមក្នុងការបំផ្លាញជនជាតិចាម ។ បន្តមកទៀតយើងនឹងពិភាក្សាអំពីការវិវត្តនៃទង្វើរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តមកលើជនជាតិចាម ដោយចាប់ផ្តើមតាំងពីកាលដែលខ្មែរក្រហមចូលមកដល់ភូមិចាមនានា នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ការបង្ខំឲ្យបង្កើតក្រុមសាមគ្គី ការបង្ខំឲ្យបរិភោគរួមគ្នាការបង្ខំឲ្យរៀបចំជាប្រព័ន្ធសហករណ៍នៅក្នុងភូមិចាមនានា និងការប្រព្រឹត្តអំពើកាន់តែឃោរឃៅខ្លាំងឡើងៗមកលើជនជាតិចាម ដែលនៅពេលនោះខ្មែរក្រហមយល់ឃើញថា ខ្លួនអាចវាយឲ្យរបបលន់ នល់ ចុះចាញ់បានដោយមិនចាំបាច់មានជំនួយពីចាម ។

ចំណុចចុងក្រោយនៃជំពូកនេះ នឹងវិភាគពីប្រតិកម្មតបរបស់ជនជាតិចាមទៅនឹងការហាមឃាត់របស់ខ្មែរក្រហម ចំពោះការដែលខ្មែរក្រហមមិនឲ្យប្រណិប័តន៍សាសនាអ៊ីស្លាម និងលទ្ធផលនៃការគាបសង្កត់របស់ខ្មែរក្រហមដែលចំណុចនេះត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ ។

## ១) សេចក្តីផ្តើម

## ការឡើងកាន់អំណាចរបស់ខ្មែរក្រហម

“ខ្មែរក្រហម” ជាឈ្មោះមួយដែលសម្តេចព្រះនរោត្តម សីហនុ បានហៅក្រុមកុម្មុយនីស្តមួយក្រុមនៅប្រទេសកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ។ នៅឆ្នាំក្នុង១៩៦៧ ពាក្យនេះ ព្រះអង្គបានសំដៅយ៉ាងច្បាស់ចំពោះវត្តមាន និងការកើនឡើងនៃឥទ្ធិពលរបស់កុម្មុយនីស្តនៅតាមទីជនបទនានានៃប្រទេសកម្ពុជា ។ នៅក្នុងយុទ្ធការខេមរយានកម្មរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងគោលបំណងច្របាច់បញ្ចូលអត្តសញ្ញាណនៃក្រុមជាច្រើននៅក្នុងកម្ពុជាឲ្យទៅជាក្រុមខ្មែរធំមួយ ទាំងពួកកុម្មុយនីស្ត និងអ្នកកាន់សាសនាអ៊ីស្លាមត្រូវបានដាក់ឈ្មោះជាខ្មែរតែមួយ ដូចជាក្រុមសង្គម និងក្រុមនយោបាយដទៃផ្សេងទៀតដែរនៅប្រទេសកម្ពុជា ។

សម្តេច សីហនុ ទ្រង់ចាត់ទុកប្រជាជនទាំងអស់ស្មើគ្នានៅប្រទេសកម្ពុជា ប៉ុន្តែ ខ្មែរក្រហមយល់ឃើញខុសប្លែកពីនេះ ។ ខ្មែរក្រហមមើលឃើញពីអំពើអយុត្តិធម៌ខាងសេដ្ឋកិច្ច និងការកេងប្រវ័ញ្ចពីសំណាក់អ្នកមានទៅលើអ្នកក្រ អ្នកចេះដឹងទៅលើអ្នកមិនចេះដឹង និងអ្នករស់នៅទីក្រុងទៅលើកសិករក្រីក្រដែលរស់នៅតាមជនបទ ។ រាជានិយម សក្តិភូមិនិយម មូលធននិយម និងទំនើបកម្មត្រូវបានខ្មែរក្រហមលុបបំបាត់ ។ អត្តសញ្ញាណខ្មែរថ្មីមួយ ត្រូវការជាចាំបាច់ដើម្បីរំដោះកម្ពុជាចេញពីជំងឺសង្គមនានា ។ ខ្មែរក្រហមបានប្រតិបត្តិគម្រោងផែនការអនាគត ដែលមានភាពទំនើប និងរីកចម្រើនរបស់ខ្លួន ពោលគឺមនុស្សទាំងអស់ស្មើភាពគ្នា គ្មានបទឧក្រិដ្ឋ គ្មានវណ្ណៈសង្គម គ្មានអ្នកមានគ្មានអ្នកក្រ និងគ្មានជាតិសាសន៍ផ្សេងៗគ្នា ។

សម្តេច សីហនុ បានព្យាយាមច្របាច់បញ្ចូលក្រុមដែលមានអត្តសញ្ញាណផ្សេងគ្នា ឲ្យទៅជាក្រុមខ្មែរធំតែមួយ ប៉ុន្តែព្រះអង្គគោរពអត្តសញ្ញាណបន្ទាប់បន្សំរបស់ក្រុមទាំងនោះ ឧទាហរណ៍ ដូចជាការបន្ថែម ពាក្យខ្មែរដែលអាចបែងចែកថា ក្រុមមួយណាគឺជាអ្នកកាន់សាសនាអ៊ីស្លាម ក្រុមណារស់នៅតំបន់ភ្នំ ក្រុមណាជាក្រុមកុម្មុយនីស្តឬសេរីជាដើម ។ ចំណែកឯ ខ្មែរក្រហមវិញមិនបានបែងចែកអត្តសញ្ញាណតូចៗនោះទេ ។ មុនឆ្នាំ១៩៧០ ខ្មែរក្រហមត្រូវបានចាត់ទុកជាក្រុមកុម្មុយនីស្តដែលមាននយោបាយ និងយោធាទន់ខ្សោយ ។ ខ្មែរក្រហមពឹងផ្អែកជំនួយភស្តុភារ និងនយោបាយជាចម្បងពីប្រទេសវៀតណាមខាងជើង ។ ក្រុមខ្មែរកុម្មុយនីស្ត និងក្រុមកុម្មុយនីស្តដទៃទៀតនៅឥណ្ឌូចិន រមែងតែងមានទំនាក់ទំនងគ្នា ។ នៅពេលសង្គ្រាមនៅឥណ្ឌូចិនទី១ បានផ្ទុះឡើង ក្រុមមួយត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥០ និងបានឲ្យឈ្មោះថា ខ្មែរឥស្សរ ដែលដឹកនាំដោយក្រុមខ្មែរកុម្មុយនីស្ត ។ ក្រុមនេះមានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធជាមួយក្រុមកុម្មុយនីស្តទ័ពព្រៃហូជីមិញ ។ បក្សបដិវត្តន៍ប្រជាជនខ្មែរបានទទួលការណែនាំពីវៀតណាមនៅមួយឆ្នាំក្រោយពេលដែលក្រុមនេះត្រូវបានបង្កើតឡើង ។

ប៉ុល ពត ដែលជាអនាគតមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ពេលនោះកំពុងសិក្សានៅប្រទេសបារាំងនៅឡើយ និងមិនបានចូលរួមក្នុងចលនានយោបាយនានានៅពេលដំបូងនោះទេ ។ ប៉ុល ពត ត្រឡប់ពីសិក្សានៅប្រទេសបារាំងមកកម្ពុជាវិញនៅឆ្នាំ១៩៥៣ ។ អ្នកដឹកនាំក្រុមកុម្មុយនីស្តដំបូងនៅប្រទេសកម្ពុជាគឺ សឺង ង៉ុកមិញ, ស៊ីវ ហេង, ទូ សាមុត និង ចាន់ សម័យ ។ បន្ទាប់ពីទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ និងបន្ទាប់ពីសង្គ្រាមឥណ្ឌូចិនទី១ បានបញ្ចប់នៅឆ្នាំ១៩៥៤ សម្តេចព្រះនរោត្តម សីហនុ ចាប់ផ្តើមអស់ភាពអត់ធ្មត់នឹងក្រុមកុម្មុយនីស្តដែលជាហេតុធ្វើឲ្យមេដឹកនាំកុម្មុយនីស្តមួយចំនួនរត់គេចខ្លួនទៅកាន់ប្រទេសវៀតណាម ។

ក្រុមកុម្មុយនីស្តក៏បានបង្កើតគណបក្សនយោបាយមួយឈ្មោះថា បក្សប្រជាជន ដើម្បីប្រជែងនៅក្នុងការបោះឆ្នោតជាតិនៅឆ្នាំ១៩៥៥ជាមួយនឹងគណបក្សសង្គមរាស្ត្រនិយមរបស់សម្តេចព្រះនរោត្តម សីហនុ ។ បន្ទាប់មក ប៉ុល ពត បានព្យាយាមយ៉ាងខ្លាំងនៅក្នុងសកម្មភាពនេះ និងភ្លក់រសជាតិនៃការបរាជ័យផ្នែកនយោបាយជាលើកដំបូង ។ គណបក្សរបស់ ប៉ុល ពត និងគណបក្សប្រជាធិបតេយ្យដែលគាំទ្រដោយ ប៉ុល ពត ទទួលរងភាពបរាជ័យយ៉ាងខ្លាំង ។ សម្តេច សីហនុ បានទទួលជ័យជម្នះលើសលុបនៅក្នុងការបោះឆ្នោត

ដែលបានផ្តល់មេរៀនយ៉ាងមានតម្លៃដល់ ប៉ុល ពត អំពីអំណាច និងប្រជាប្រិយភាពរបស់ព្រះអង្គ ។ ប៉ុល ពត ក៏បានរៀនសូត្រពីភាពស្មោះត្រង់ចំពោះបក្ស និងវិធីធ្វើយ៉ាងណាដើម្បីពង្រឹងភាពស្មោះត្រង់ចំពោះបក្ស ខណៈពេលដែលសមាជិកជាច្រើននៃចលនាកុម្មុយនីស្តរបស់ខ្លួនចាប់ផ្តើមចុះចូលជាមួយរបបថ្មីរបស់សម្តេចព្រះនរោត្តម សីហនុ ។ ស៊ីវ ហេង ដែលជាមេដឹកនាំបក្សបដិវត្តន៍ប្រជាជនខ្មែរបានចុះចូលជាមួយសម្តេច សីហនុ នៅឆ្នាំ១៩៥៩ ។ ការចុះចូលរបស់ ស៊ីវ ហេង បាននាំមកនូវការចាប់ខ្លួនភ្នាក់ងារកុម្មុយនីស្តសម្ងាត់ជាច្រើននាក់ ។ ប៉ុន្តែ បន្ទាប់ពីពេលនោះមកក្រុមកុម្មុយនីស្តក៏បានបង្កើតមូលដ្ឋានមួយយ៉ាងរឹងមាំនៅខេត្តកំពង់ចាម និងតាកែវ ។ ក្រោយមក ខេត្តទាំងពីរនេះត្រូវបានពង្រីកក្លាយជាភូមិភាគបូព៌ា និងភូមិភាគនិរតី ដែលជាភូមិភាគខ្មែរក្រហមពីរ ដែលធ្វើឲ្យជនជាតិចាមជួបប្រទះនឹងគ្រោះមហន្តរាយ ។

នៅឆ្នាំ១៩៦២ ប៉ុល ពត បានក្លាយជាមេដឹកនាំក្រុមកុម្មុយនីស្តនៅប្រទេសកម្ពុជាពេញមុខចំណែកឯ នួន ជា ជាអនុប្រធាន ។ ភ្លាមៗនោះ ប៉ុល ពត បានរត់គេចខ្លួនទៅកាន់តំបន់ដែលមានប្រជាជនរស់នៅតិចគឺភាគឦសាន្តនៃប្រទេសកម្ពុជា ដែលក្រោយមក ប៉ុល ពត បានហៅថាភូមិភាគឦសាន ។ នៅទីនោះ ប៉ុល ពត បានជ្រើសរើសប្រជាជនខ្មែរលើជាច្រើនឲ្យចូលរួមប្រយុទ្ធដើម្បីចលនាកុម្មុយនីស្ត ។ មិនតែប៉ុណ្ណោះ ប៉ុល ពត ក៏បានធ្វើទស្សនកិច្ចទៅកាន់ប្រទេសវៀតណាម ចិន និងកូរ៉េខាងជើងនៅឆ្នាំ១៩៦៥ ។ ដំណើរទស្សនកិច្ចនោះបានបង្ហាញ ប៉ុល ពត ឲ្យដឹងពីភាពខុសគ្នានៃលទ្ធិកុម្មុយនីស្ត ដែលមានបែបផែនផ្សេងៗគ្នា ។ នៅពេលនោះប្រទេសចិន និងសហភាពសូវៀត បានបង្ហាញពីសញ្ញានៃការខ្វែងគំនិតគ្នាយ៉ាងខ្លាំង ។ ប៉ុល ពត បានត្រឡប់មកភូមិភាគឦសានវិញក្រោយពីមានការមិនទុកចិត្ត និងមិនពេញចិត្តយ៉ាងខ្លាំងចំពោះលទ្ធភាពនឹងបង្កើតបក្សកុម្មុយនីស្តរួមគ្នាតែមួយនៅឥណ្ឌូចិន ។ នៅឆ្នាំ១៩៦៦ ប៉ុល ពត បានបង្កើតបក្សកុម្មុយនីស្តកម្ពុជា ។ យោងតាមភ័ស្តុតាងដែលបានបង្ហាញពីការមិនទុកចិត្តរបស់ ប៉ុល ពត ចំពោះវៀតណាម នាំឲ្យ ប៉ុល ពត លែងជឿទុកចិត្តលើជនកុម្មុយនីស្តកម្ពុជានានាដែលទទួលការហ្វឹកហាត់ពីវៀតណាម និងក្រោយមកត្រូវបានចាប់ឃុំឃាំង និងសម្លាប់ចោលដោយសម្ងាត់ ។

ការលុបបំបាត់នូវសមាជិកកុម្មុយនីស្តជាន់ចាស់ដៀសមិនផុតពីធ្វើឲ្យចលនាកុម្មុយនីស្តចុះខ្សោយនោះទេ ។ មិនតែប៉ុណ្ណោះទង្វើនេះក៏បាននាំមកនូវការមិនយល់ស្របគ្នាក្នុងការបកស្រាយនិងអនុវត្តលិទ្ធិកុម្មុយនីស្តនៅកម្ពុជា ។ លើសពីនេះទៅទៀត ទង្វើនេះបានធ្វើឲ្យមានភាពខុសប្លែកគ្នាក្នុងការអនុវត្តនៅតំបន់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជាផងដែរ ។ ភាពខុសប្លែកគ្នានេះ រឹតតែធ្វើឲ្យចលនាកុម្មុយនីស្ត កាន់តែចុះខ្សោយទៅៗ ។ ប៉ុន្តែ ភ័ព្វសំណាងរបស់ ប៉ុល ពត បានផ្លាស់ប្តូរនៅខែមីនា ឆ្នាំ១៩៧០ គឺពេលដែល លន់ នល់ និងសិរិមតៈ (ជាឪពុកមារបស់សម្តេច សីហនុ) បានទម្លាក់សម្តេច សីហនុ ចេញពីអំណាចដោយរដ្ឋប្រហារដែលគ្មានការបង្ហូរឈាម ខណៈពេលដែលសម្តេច សីហនុ យាងទៅប្រទេសបារាំង ។ សម្តេច សីហនុ មិនត្រឹមតែត្រូវបានបំបាក់មុខដោយអ្នកនៅក្រោមបង្គាប់របស់ព្រះអង្គប៉ុណ្ណោះទេ ប្រសិនបើព្រះអង្គយាងត្រឡប់មកប្រទេសកម្ពុជាវិញ ព្រះអង្គអាចនឹងប្រឈមនឹងការកាត់ទោស និងដាក់ពន្ធនាគារថែមទៀតផង ។ ព្រះអង្គគ្មានជម្រើសអ្វីក្រៅពីចូលរួមជាមួយចលនាកុម្មុយនីស្តរបស់ ប៉ុល ពត ដែលនៅពេលនោះ ប៉ុល ពត បានបង្កើតកម្លាំងទ័ពព្រៃយ៉ាងរឹងមាំនៅជុំវិញប្រទេស ។ ការចូលរួមជាមួយក្រុមកុម្មុយនីស្តរបស់សម្តេច សីហនុ បានអនុញ្ញាតឲ្យចលនាកុម្មុយនីស្តរបស់ ប៉ុល ពត ទាញយកប្រយោជន៍ពីប្រជាប្រិយភាពរបស់ព្រះអង្គដែលមានអ្នកនិយមចូលចិត្តដ៏ច្រើនលើសលុបនៅតាមទីជនបទនានា ។ កត្តាទាំងអស់នោះ បានជំរុញឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់មួយទៅលើអំណាចរបស់ជនកុម្មុយនីស្តក៏ដូចជាសមត្ថភាពខាងយោធា ។ ប៉ុន្តែ ប៉ុល ពត បានធ្វើការបញ្ជាក់ថា គាត់ជាអ្នកកាន់អំណាច មិនមែនសម្តេច សីហនុ នោះទេ ។ រដ្ឋប្រហារឆ្នាំ១៩៧០ បានជំរុញឲ្យកម្ពុជាធ្លាក់ទៅក្នុងសង្គ្រាមឥណ្ឌូចិនទី២ និងបានបែងចែកប្រទេសកម្ពុជាជាពីរ ដែលខ្មែរក្រហមហៅថាតំបន់រំដោះ និងតំបន់ លន់ នល់ ។

មិនខុសពីប្រជាជនខ្មែរទេ ជនជាតិចាមត្រូវជាប់នៅចន្លោះតំបន់ទាំងពីរ និងត្រូវបង្ខំចិត្តចុះចូលទាំងសងខាង ។ ដូចដែលបានរៀបរាប់ខាងដើម ឡេស កូសឹម (Les Kosem) ជាមួយនឹងអ្នកកាន់សាសនាអ៊ីស្លាមផ្សេងទៀតនៅទីក្រុងនានា បានដើរតួយ៉ាងសកម្មក្នុងជួយរដ្ឋាភិបាល លន់ នល់ ខណៈពេលដែល សុះ ម៉ាន (Sos Man)

និងអ្នកដឹកនាំជនជាតិចាមជាច្រើនផ្សេងទៀត ដែលរស់នៅតាមសហគមន៍ជនបទបានចូលរួមយ៉ាងសកម្មជាមួយរណសិរ្សរួបរួមជាតិ ដែលជាឈ្មោះផ្លូវការរបស់ក្រុមខ្មែរក្រហម ។

នៅត្រឹមឆ្នាំ១៩៧២ ស្ទើរតែ៧០ភាគរយនៃដែនដីប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយខ្មែរក្រហម ។ ចំណែកឯលន់ នល់ វិញ បានកាន់កាប់ត្រឹមតែកំពង់ផែសមុទ្រ តំបន់ឆ្នេរ ផ្លូវជាតិនានាដែលតភ្ជាប់ពីភ្នំពេញទៅវៀតណាមខាងត្បូង និងផ្នែកផ្សេងទៀតនៃខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលតភ្ជាប់ភ្នំពេញទៅកាន់ប្រទេសថៃ ។ នៅត្រឹមឆ្នាំ១៩៧៣ ស្ទើរតែ៩០ភាគរយនៃប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយខ្មែរក្រហម ។ កម្លាំងទ័ពរបស់ លន់ នល់ បានកាន់កាប់ត្រឹមតែផ្លូវជាតិនានា ដែលតភ្ជាប់ភ្នំពេញទៅកាន់កំពង់ផែព្រះសីហនុ ខេត្តកំពង់ចាម និងខេត្តបាត់ដំបងប៉ុណ្ណោះ ។ ទឹកដីដែលកាន់កាប់ដោយ លន់ នល់ នៅពេលនោះមានតែនៅតាមបណ្តោយព្រំដែនថៃនិងខេត្តបាត់ដំបងតែប៉ុណ្ណោះ ។ ទីរួមខេត្តមួយចំនួនដែលនៅតែស្ថិតនៅក្រោមការគ្រប់គ្រងទ័ពរបស់ លន់ នល់ រួមមានខេត្តកំពង់ចាម កំពត និងកំពង់ធំ ពោធិ៍សាត់ សៀមរាប ក្រុងព្រះសីហនុ ព្រៃវែង កណ្តាល និងខេត្តបាត់ដំបង ។ ទោះបីជាទីរួមខេត្តទាំងនោះ ត្រូវបានកាត់ផ្តាច់ពីតំបន់ផ្សេងៗទៀតដោយខ្មែរក្រហមក៏ដោយ ។ ទោះបីជាយ៉ាងនេះក្តី ក្រុមកុម្មុយនីស្តបានបញ្ជៀបខ្លួនចូលទៅក្នុងតំបន់ទាំងនេះ សូម្បីមន្ត្រី លន់ នល់ ក៏បានធ្វើជំនួញជាមួយក្រុមកុម្មុយនីស្តដែរ ។ បើយោងតាមជនជាតិចាមដែលរស់នៅខេត្តកំពង់ចាម បានឲ្យដឹងថា ខ្លួនបានធ្វើជំនួញជាមួយប្រជាជនដែលនៅក្នុងតំបន់កាន់ដោយ លន់ នល់ ។

ខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជាទាំងមូលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលទីក្រុងភ្នំពេញ ក្លាយជាសមរភូមិចុងក្រោយនៃសង្គ្រាមដែលគ្មានការបង្ហូរឈាម ។ ផែនការយ៉ាងក្តៅមួយចំនួនបានត្រូវបានអនុវត្តដោយខ្មែរក្រហមក្នុងបំណងទប់ស្កាត់ការប្រឆាំងតប និងដើម្បីសម្រេចបាននូវទស្សនវិស័យវែងឆ្ងាយដ៏ធំសម្បើមរបស់របស់ខ្លួនក្នុងការកែប្រែប្រទេសកម្ពុជាឲ្យទៅជាប្រទេសមួយដែលល្អឥតខ្ចោះ ។ ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ និងទីក្រុងផ្សេងទៀតត្រូវបានជម្លៀសចេញ ។ នួន ជា ក្រោយមកបាននិយាយក្នុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលច្រើនស្គាល់ថា (ជាតុលាការខ្មែរក្រហម) ថា ការជម្លៀសត្រូវបានអនុវត្តដើម្បីគ្រប់គ្រងប្រជាជន ។ មនុស្សប្រុសស្រី ក្មេងចាស់សូម្បីអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ និងចាស់ជរា ក៏ត្រូវបានបញ្ជាឲ្យចាកចេញដោយថ្មើរជើងទៅកាន់ទីជនបទ ។ ទោះជាយ៉ាងណាក្តី ខ្មែរក្រហមមិនមានគម្រោងច្បាស់លាស់ណាមួយថាតើត្រូវបែងចែកប្រជាជនយ៉ាងដូចម្តេចនោះទេ ។ ខ្មែរក្រហមគ្រាន់តែដឹងថា ប្រជាជននៅទីក្រុងត្រូវតែបញ្ជូនចេញទៅទីជនបទ ។

នៅឯទីក្រុងភ្នំពេញវិញ ប្រជាជនតម្រូវឲ្យដើរតាមបណ្តោយផ្លូវធំៗនានាទៅកាន់ភូមិស្រុក ដែលធ្លាប់រស់នៅពីមុនឬក៏មានបងប្អូនសាច់ញាតិជិតស្និទ្ធរស់នៅ ។ ទោះជាយ៉ាងណាក្តី ដោយសារការដាក់បម្រាមគោចរណ៍ប្រជាជនខ្លះមិនអាចធ្វើដំណើរទៅកាន់ភូមិករតាមតែខ្លួនចង់នោះទេ ។ បន្ថែមពីលើនេះទៀត ប្រជាជនដែលត្រូវបានជម្លៀសសង្ឃឹមថានឹងអាចត្រឡប់មកទីក្រុងភ្នំពេញវិញ ក្នុងអំឡុងពេលបីបួនថ្ងៃ ។ ជនជាតិចាមនៅខាងភាគឦសាននៃទីក្រុងភ្នំពេញដូចជាតំបន់ច្រាំងចំរេះ និងជ្រោយចង្វារ ជាទូទៅផ្លាស់ទៅនៅខេត្តកំពង់ចាម និងកំពង់ឆ្នាំង ។ ឯប្រជាជនចាមនៅតំបន់ព្រែកប្រា ភាគអគ្នេយ៍នៃទីក្រុងភ្នំពេញវិញ បានផ្លាស់ទៅកាន់ខេត្តកណ្តាល ។ អត្តសញ្ញាណជាតិសាសន៍របស់ប្រជាជនចាមទាំងនោះលែងជាជនជាតិចាម ឬអ្នកកាន់សាសនាអ៊ីស្លាមទៀតហើយ តែជា «ប្រជាជនថ្មី» ។ ដំបូងឡើយខ្មែរក្រហម ហាក់ដូចជា មិនមានចេតនាចង់បំបែកប្រជាជនចាមនោះទេ ប៉ុន្តែក្រោយមកទៀតខ្មែរក្រហមមានចេតនាកាន់តែខ្លាំងឡើងក្នុងការបំបែកសហគមន៍ចាម នៅទូទាំងប្រទេសឲ្យបែកខ្ញែកពីគ្នា ។ ការបំបែកនេះធ្វើឲ្យអត្តសញ្ញាណស្នូលរបស់ជនជាតិចាមចុះខ្សោយ និងច្របាច់បញ្ចូលជាមួយក្រុមខ្មែរភាគច្រើន ។

នៅខែធ្នូ ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហម និងមន្ត្រីជាច្រើនរូបបានជួបពិភាក្សាគ្នាដើម្បីបង្កើតរដ្ឋធម្មនុញ្ញជាតិថ្មីមួយដែលបានអនុម័តិនៅខែមករា ឆ្នាំ១៩៧៦ ។ នៅក្នុងឆ្នាំដដែល កម្ពុជាប្រជាធិបតេយ្យបានលុបបំបាត់ចោលនូវការបែងចែករដ្ឋបាលចាស់ និងបានបែងចែករដ្ឋបាលថ្មី តាមភូមិភាគ តំបន់ ស្រុក ឃុំ និងភូមិ ។ ខ្មែរក្រហមបានបង្កើតភូមិភាគចំនួន៦ និងតំបន់ចំនួន៣២ ។ នៅឆ្នាំ១៩៧៦ មន្ត្រីខ្មែរក្រហមបានជួបជុំបង្កើតផែនការបួនឆ្នាំ

សម្រាប់អនុវត្តពីឆ្នាំ១៩៧៧ ទៅឆ្នាំ១៩៨០ ដែលកសិកម្មគឺជាផលិតកម្មអាទិភាពតាមរយៈសមូហនីយកម្ម ការរៀបចំជាសហករណ៍ និងការលុបបំបាត់ឯកជននីយកម្ម ។ ទោះបីយ៉ាងណា ការអនុវត្តទម្រង់សហករណ៍ ប្រហាក់ប្រហែលគ្នានៅភូមិចាមនានា បានចាប់ផ្តើមយូរណាស់មកហើយ ។ សមាជិកគ្រួសារចាមត្រូវបានបែងចែកដោយផ្អែកទៅតាមអាយុ ដោយចែកចេញជាកងកុមារ កងចល័ត កងយុវនារី កងយុវជន និងកងមនុស្សចាស់ក្នុងចំណោមប្រជាជនដទៃទៀត ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការរៀបការឆ្លងសាសន៍ត្រូវបានបង្ខំឲ្យអនុវត្ត ។ ការគោរពប្រតិបត្តិសាសនាអ៊ីស្លាម និងការថ្វាយបង្គំ (សំយ៉ាំង) ត្រូវបានខ្មែរក្រហមហាមឃាត់ ។ សុះ ម៉ែត បានឲ្យដឹងថា គ្មានការគោរពបន់ស្រន់នៅក្នុងរបបខ្មែរក្រហមនោះទេ ។ ម៉ែត ធ្លាប់បានឃើញស្ត្រីចាមម្នាក់ត្រូវបានខ្មែរក្រហមសម្លាប់ចោល ដោយសារការសំយ៉ាំង ។ សុះ ភក្រ្ត័ បានបន្ថែមថា “ខ្មែរក្រហមមកលបស្តាប់នៅក្រោមខ្ទមក្រែងលយើងនិយាយចាម និងសំយ៉ាំងនៅពេលយប់ ។ អាវផាយសម្រាប់សំយ៉ាំង ត្រូវបានជ្រលក់ពណ៌ពីសទៅជាខ្មៅ ទើបមិនសូវមានការសង្ស័យ” ។

នៅក្នុងរោងបាយសហករណ៍ ម្ហូបអាហារដែលសាសនាហាមឃាត់មិនឲ្យទទួលទានមិនត្រូវបានខ្មែរក្រហមយកចិត្តទុកដាក់នោះទេ ។ អ្នកកាន់សាសនាអ៊ីស្លាមត្រូវបានខ្មែរក្រហមបង្ខំឲ្យហូបសាច់ជ្រូក នៅពេលណាដែលខ្មែរក្រហមធ្វើម្ហូបមានដាក់សាច់ជ្រូក ។ ជួនកាលការបរិភោគសាច់ជ្រូកត្រូវបានខ្មែរក្រហមប្រើសម្រាប់សាកល្បងពីភាពស្មោះត្រង់នៃអ្នកកាន់សាសនាអ៊ីស្លាមចំពោះកម្ពុជាប្រជាធិបតេយ្យ និងការកែប្រែចរិតរបស់ជនជាតិចាមឲ្យស្របតាម “អង្គការ” ។ ណោ អែលីម៉ាស់បានឲ្យដឹងថា ៈ

ជីវិតនៅក្រោមរបបខ្មែរក្រហមគឺពិតជាពិបាកខ្លាំងណាស់ ។ ថ្ងៃមួយប្រធានកងនារីម្នាក់បានដាក់ម្ហូបដែលមានសាច់ជ្រូកមួយចាននៅចំពីមុខខ្ញុំ ហើយឲ្យខ្ញុំហូបម្ហូបនោះដើម្បីបញ្ជាក់ថា ខ្ញុំក៏ដូចពួកគេដែរ ។ ខ្ញុំប្រាប់គាត់ថា “មិត្តបង ខ្ញុំប្រាថ្នាឲ្យខ្លួនខ្ញុំអាចហូបសាច់ជ្រូកដែលឃើញរាល់ថ្ងៃបានដូចជា សាច់គោ និងសាច់មាន់ដែរ ។ ខ្ញុំមិនបានរើសអើងប្រឆាំងនឹងមិត្តបងទេ ។ បើមើលទៅវិហារចាមជាច្រើន ត្រូវបានបំផ្លាញអស់ហើយ ។ ខ្ញុំសង្ឃឹមថា ខ្ញុំអាចហូបវាបានឥឡូវនេះ ប៉ុន្តែខ្ញុំមិនទាន់សាំនៅឡើយទេ ។ សូមកុំខឹងអី ការធ្វើបដិវត្តន៍ត្រូវការពេលវេលាយូរមិនអាចធ្វើមួយថ្ងៃឬពីរថ្ងៃបានទេ” ។ គាត់បានឆ្លើយតបថា “មិត្ត ណុប និងអ្នកដទៃទៀតបានហូបសាច់ជ្រូកហើយ នៅសល់តែមិត្តឯងម្នាក់ទេ ” ។ ខ្ញុំបានតបវិញថា “មិត្តបង គេអាចធ្វើបានខ្ញុំសូមសរសើរគេ ។ ប៉ុន្តែ ការធ្វើបដិវត្តន៍ត្រូវការពេលវេលា ។ ថ្ងៃនេះមិត្ត ណុប ធ្វើបានល្អជាងខ្ញុំ នៅពេលខាងមុខ ខ្ញុំអាចនឹងធ្វើល្អជាងគាត់ទៅទៀត” ។ បន្ទាប់មក គាត់បានដកចានដែលមានសាច់ជ្រូកចេញ ជំនួសដោយចានដែលមានជ្រក់ត្រកួនវិញ ។ ជាការពិតណាស់ នៅពេលណាដែលខ្ញុំអាចជៀសមិនហូបសាច់ជ្រូកបាន ខ្ញុំយកអំបិលពីផ្ទះទៅហូបជាមួយបបរ ឬបាយ និងព្យាយាមជៀសវាងម្ហូបដែលមានសាច់ជ្រូក ។

ស្ត្រីត្រូវបានខ្មែរក្រហមបញ្ជាឲ្យកាត់សក់ខ្លី ឈ្មោះ សុះ ភក្រ្ត័ បានឲ្យដឹងថា “ខ្មែរក្រហមបានព្យាយាមលុបបំបាត់សាសនាអ៊ីស្លាម ។ ខ្មែរក្រហមចង់ឲ្យយើងក្លាយទៅជា “ខ្មែរ” ។ ខ្មែរក្រហមបានបញ្ជាយើងឲ្យកាត់សក់ឲ្យខ្លី និងហូបសាច់ជ្រូក ។ សូម្បីតែអាវដៃវែងក៏មិនអនុញ្ញាតឲ្យពាក់ដែរ ។ កន្សែងរុំសក់ (ហៃចាប់) របស់យើងត្រូវបានហែកទៅជាបីជម្រៀក និងត្រូវបានក្រវែងចោល ។ ខ្មែរក្រហមបាននិយាយថា មិនមានចាមទៀតទេ មានតែខ្មែរ ។ បន្ទាប់មកខ្មែរក្រហមកាត់សក់ខ្ញុំ ។ ខ្ញុំអង្គុយយំពេលដែលខ្មែរក្រហមធ្វើដូចនេះ” ។

គម្ពីរគួរអាន **(Quran)** ត្រូវបានប្រមូល និងបានបំផ្លាញចោល ។ សុះ ភក្រ្ត័ បានបន្ថែមថា “មេភូមិបញ្ជាឲ្យយើងបោះចោលគម្ពីរគួរអាន និងអត្ថបទសាសនាចោលក្នុងបង្គន់សាធារណៈ ។ ប៉ុន្តែឪពុករបស់ខ្ញុំបដិសេធ ។ ខ្ញុំប្រាប់ឪពុកខ្ញុំថាត្រូវតែកប់គម្ពីរសាសនាទាំងនោះ បើមិនដូច្នោះ ខ្មែរក្រហមនឹងមកអាករពួកយើង ។ ចុងក្រោយ ឪពុករបស់ខ្ញុំប្រាប់មេភូមិថា គាត់បានបោះគម្ពីរទាំងនោះចោលក្នុងបង្គន់អស់ហើយ តែតាមការពិតគាត់គ្រាន់តែកប់ចោលប៉ុណ្ណោះ” ។ ទូល័ស អាសម៉ាត់ បាននិយាយថា “ឪពុកក្មេករបស់ខ្ញុំបានរិចខ្ចប់គម្ពីរសាសនាដាក់នៅក្នុងបាវមួយ ហើយដាក់គម្ពីរទាំងនោះទៅក្នុងទឹកដើម្បីលាក់កុំឲ្យខ្មែរក្រហមឃើញ” ។

ព្រះវិហារនានាត្រូវបានខ្មែរក្រហមមើលស្រាល ដោយយកទៅប្រើជាឃ្លាំង ឬប្រើជាកន្លែងចិញ្ចឹមជ្រូកដោយខុសឆ្គង

បំផុត ។ ព្រះវិហារទាំងនោះជួនកាលត្រូវបានខ្មែរក្រហមបំផ្លាញចោល ។ នៅមុនឆ្នាំ១៩៧៥ វិហារអ៊ីស្លាមនៅទូទាំងប្រទេសកម្ពុជាមានចំនួន១១៣ ។ ប៉ុន្តែនៅក្រោយឆ្នាំ១៩៧៩ មានតែវិហារចំនួនប្រាំប៉ុណ្ណោះដែលនៅសល់ ។ អ្នកចេះដឹង និងអ្នកដឹកនាំជនជាតិចាមត្រូវបានចាប់ខ្លួន និងសម្លាប់ ។ ទង្វើទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ពីការវាយប្រហារទៅលើអត្តសញ្ញាណស្នូលរបស់ជនជាតិចាម ។ ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាមកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ ។

ការធ្វើវិស្សុទ្ធកម្មរបស់ខ្មែរក្រហម បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជនជាតិចាម ដែលរស់នៅខេត្តកំពង់ចាម និងតំបន់ផ្សេងទៀតនៅក្នុងប្រទេស ។ ជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ដែលបានចាប់ផ្តើមនៅឆ្នាំ១៩៧៦ កាន់តែបង្កឲ្យមានការសម្លាប់កម្មាភិបាលរបស់ខ្មែរក្រហមជាបន្តបន្ទាប់ ។ នៅឆ្នាំ១៩៧៧ នៅពេលដែលវៀតណាមបានឈ្លានពាន និងបន្ទាប់មកដកទ័ពចេញពីភូមិភាគបូព៌ា ខ្មែរក្រហមបានធ្វើវិស្សុទ្ធកម្មកម្មាភិបាលរបស់ខ្លួនរាប់រយនាក់នៅភូមិភាគបូព៌ា រួមទាំង មេដឹកនាំភូមិភាគរបស់ខ្លួនគឺ សោ ភឹម ដោយចោទថា «មានក្បាលយួនខ្លួនខ្មែរ» ។ សមាជិកកងទ័ពជាច្រើននៃភូមិភាគបូព៌ា បានវាយប្រឆាំងតបវិញ ដែលជាហេតុធ្វើឲ្យ ប៉ុល ពត កាន់តែជឿថា កម្មាភិបាលទាំងនោះពិតជាបានក្បត់ពិតមែន ។ មនុស្សរាប់សែននាក់ត្រូវបានសម្លាប់ក្នុងពេលធ្វើវិស្សុទ្ធកម្ម និងពេលប្រយុទ្ធគ្នា ចំណែកឯមនុស្សរាប់ពាន់នាក់ទៀតដែលរួមទាំងកម្មាភិបាលខ្មែរក្រហមមួយចំនួនបានរត់គេចខ្លួនទៅប្រទេសវៀតណាម ។

ខ្មែរក្រហមបានធ្វើវិស្សុទ្ធកម្មនៅភូមិភាគឧត្តរ ដែលក្រោយមកក្លាយជាភូមិភាគមជ្ឈិមនៅឆ្នាំ១៩៧៧ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ។ កុយ ធួន លេខាភូមិភាគត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែង ក្នុងឆ្នាំ១៩៧៦ ។ នៅក្នុងដំណើរការវិស្សុទ្ធកម្ម ប៉ុល ពត បានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ ហ៊ូ នឹម, ទីវ អុល និង មេដឹកនាំជាច្រើនទៀត ។ វន វើត ជាសមាជិកចាស់យូរយាររបស់បក្សកុម្មុយនីស្តកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចត្រូវបានចាប់ខ្លួន និងសម្លាប់នៅឆ្នាំ១៩៧៨ ។ ញឹម រស់ លេខាធិការភូមិភាគពាយ័ព្យត្រូវបានសម្លាប់នៅឆ្នាំ១៩៧៨ ។

កម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់ត្រូវបានសម្លាប់ក្នុងការធ្វើវិស្សុទ្ធកម្មនេះ ។ នៅក្នុងដំណើរការនោះ មានជានជាតិចាមជាច្រើន ត្រូវបានសម្លាប់ជាច្រើនដំណាក់កាល ។ ជនជាតិចាមទាំងនោះត្រូវបានខ្មែរក្រហមបំបែក និង ចាត់ទុកជាខ្មាំងជាតិសាសន៍ ។

## ២) រដ្ឋធម្មនុញ្ញខ្មែរក្រហម និងសាសនាអ៊ីស្លាម

រដ្ឋធម្មនុញ្ញខ្មែរក្រហមត្រូវបានអនុម័តនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ និងបានផ្តល់ភ័ស្តុតាងយ៉ាងរឹងមាំស្តីអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះអ៊ីស្លាម ។ មាត្រា២០ ផ្នែកទី១៥ នៃរដ្ឋធម្មនុញ្ញបានបង្ហាញថា «ប្រជាជនកម្ពុជាមានសិទ្ធិជឿនូវជំនឿ ឬសាសនា និងមានសិទ្ធិមិនជឿលើជំនឿ ឬសាសនានានា ។ ប្រជាជនមិនត្រូវបានអនុញ្ញាតជាដាច់ខាតឲ្យជឿលើសាសនាប្រតិកិរិយាដែលបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជានោះទេ» ។ តាមរយៈរដ្ឋធម្មនុញ្ញនេះ បានបង្ហាញយ៉ាងច្បាស់ថា ខណៈដែលខ្មែរក្រហមផ្តល់ឲ្យប្រជាជនកម្ពុជានូវសេរីភាពខាងជំនឿ ខ្មែរក្រហមក៏ជាអ្នកកំណត់ថា សាសនាមួយណាដែលល្អ ឬអាក្រក់ ។ ជាទូទៅ នៅក្នុងរដ្ឋាភិបាលប្រជាធិបតេយ្យមួយ សាសនាមិនត្រូវបានវាយតម្លៃនោះទេ ប៉ុន្តែមានតែបទឧក្រិដ្ឋទេ ដែលត្រូវបានវាយតម្លៃនោះ ។ ផ្ទុយទៅវិញ សាសនាត្រូវបានវាយតម្លៃថា មានប្រយោជន៍ មិនមែនប្រយោជន៍ មានគ្រោះថ្នាក់ ឬមានសុវត្ថិភាពសម្រាប់ការធ្វើបដិវត្តន៍នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរក្រហម ។ នៅពេលសាសនាត្រូវបានខ្មែរក្រហមយល់ឃើញបែបនេះ សាសនាទាំងអស់លែងត្រូវបានចាត់ទុកថា ជាជំនឿ ប៉ុន្តែជានយោបាយទៅវិញ ។ សាសនាអ៊ីស្លាម ក៏ដូចគ្នាដែរ ត្រូវបានចាត់ទុកជាគោលដៅក្នុងការបំផ្លាញច្រើនជាងសាសនាដទៃទៀត ។ សាសនាអ៊ីស្លាមត្រូវបានខ្មែរក្រហមចាត់ទុកជាសាសនាចម្លែកក្រោមការដឹកនាំរបស់ខ្មែរក្រហម ដោយសារតែខ្មែរក្រហមភាគច្រើន ជាខ្មែរពុទ្ធសាសនិក ។

ចំណុចមួយផ្សេងទៀតក្នុងការពិភាក្សាពីរដ្ឋធម្មនុញ្ញខ្មែរក្រហម គឺការវិភាគពាក្យ «ប្រតិកិរិយា» ដែលត្រូវបានប្រើជារនាំង ដើម្បីហាមឃាត់សាសនា និងកំណត់ថាតើខ្មែរក្រហមនឹងបញ្ចេញប្រតិកម្មយ៉ាងដូចម្តេច? នៅពេលប្រជាជន ឬស្ថាប័នផ្សេងៗចាត់ទុកថាប្រក្រតី ។ ប្រតិកិរិយា ជាភាសាខ្មែរត្រូវបានពន្យល់នៅក្នុងវចនានុក្រម ជួន ណាត ឆ្នាំ១៩៦៣ សំដៅទៅលើមនុស្សណាដែលប្រឆាំង

និងការផ្លាស់ប្តូរនយោបាយ ឬការវិវត្តន៍នៃសង្គម ។

នៅក្នុងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ ដែលបានចេញផ្សាយប្រចាំខែរបស់ខ្មែរក្រហម ពាក្យ "ប្រតិកិរិយា" ត្រូវបានខ្មែរក្រហម លើកឡើងជាញឹកញាប់ ។ ពាក្យនេះត្រូវបានយកមកប្រើដើម្បីហៅបុគ្គលណាដែលខ្មែរក្រហមគិតថាជាសត្រូវដែលខ្មែរក្រហមស្អប់ជាងគេ ។ ខ្មែរក្រហមបានបញ្ចូលចក្រពត្តិអាមេរិក និងភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា អ្នកមានទ្រព្យធន ម្ចាស់ដី និងអ្នកជំនួញដែលមានទ្រព្យធន មន្ត្រីរដ្ឋការ លន់ នល់ និងជនណាដែលកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់កម្មករដែលគ្មានជំនាញ និងកសិករ ។

ដូចដែលបានគត់សម្គាល់ខាងដើម នៅពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ទៅកាន់ទីជនបទ ។ ប្រជាជនទាំងនេះ ក្រោយមកបានក្លាយជាប្រជាជនថ្មី (អ្នកថ្មី) ។ ក្រោយមកមន្ត្រីខ្មែរក្រហមជាច្រើនបានតាមដានរកអ្នករស់នៅទីក្រុង នៅពេលដែលប្រជាជនទាំងនោះត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅតាមវាលស្រែ ដើម្បីបញ្ជាក់ពីភាពអធន នៅមុនពេលបដិវត្តន៍អធន គឺជាលទ្ធភាពដែលប្រើកម្លាំងផ្ទាល់ខ្លួនដើម្បីរកទ្រព្យធន ។ វណ្ណៈអធន គឺជាវណ្ណៈកណ្តាលដែលគ្រាន់តែមានទ្រព្យធនគ្រប់គ្រាន់ ត្រឹមតែអាចផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួនបានតែប៉ុណ្ណោះ ពួកគេមិនបានកេងប្រវ័ញ្ចអ្នកដទៃ និងមិនត្រូវបានគេកេងប្រវ័ញ្ច ។ ទស្សនៈរបស់ខ្មែរក្រហមទាក់ទងនឹងផ្នែកនយោបាយ និងសេដ្ឋកិច្ចមិនសូវជាខុសគ្នាប៉ុន្មានទេ ។ ជនទាំងឡាយដែលមិនមានសមាសភាពដូចនេះ ត្រូវបានចាត់ទុកថាជាពួកប្រតិកិរិយា ។ ជនទាំងនោះជាទូទៅត្រូវបានដាក់ក្នុងលក្ខខណ្ឌការងារលំបាក បង្អត់អាហារ ឃុំឃាំង និងធ្វើទារុណកម្ម ឬត្រូវសម្លាប់ចោលនៅតាមវាលស្រែ ។

នៅក្នុងទស្សនាវដ្តីចុះខែសីហា ឆ្នាំ១៩៧៨ បានសរសេរថា "ពួកចក្រពត្តិសក្តិភូមិនាយទុននិយមនៅក្នុងប្រទេស បានធ្វើឲ្យខូចសតិអារម្មណ៍របស់យុវជន ។ ដូច្នេះ យុវជនគឺជាសមាសធាតុស្នូលសម្រាប់ការការពារ និងទប់ស្កាត់ការរីករាលដាលនៃការគ្រប់គ្រងបែបហ្វាស៊ីសក្បត់ជាតិ និងក្បត់ប្រជាជន" ។ នៅក្នុងទស្សនាវដ្តីលេខដដែលនេះបានបង្ហាញថា មុនពេលរំដោះ យុវជនកម្ពុជាបានទទួលរងការមើលងាយមើលស្រាយពីជនអាណានិគម ពួកចក្រពត្តិ និងពួកវណ្ណៈជិះជាន់ ដែលជនទាំងអស់នោះ គឺជាក្រុមប្រតិកិរិយា សក្តិភូមិ នាយទុន ។ ទស្សនាវដ្តីចេញខែកក្កដា ឆ្នាំ១៩៧៥ បានឲ្យដឹងថា "កាលពីសង្គមចាស់ដែលជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិ និងជាសង្គមដែលជិះជាន់មនុស្ស នាយទុន សក្តិភូមិ និងចក្រពត្តិប្រតិកិរិយា ដែលរស់នៅហ៊ឺហាសប្បាយ ដោយសារតែជនទាំងនោះបានជិះជាន់កម្លាំងពលកម្មរបស់ប្រជាជន" ។ ទស្សនាវដ្តីលេខដដែលនេះ បានសរសេរបន្តថា "ក្រុមប្រតិកិរិយាទាំងនោះបានសាបព្រោះគំនិតប្រតិកិរិយា និងជីវិតរបស់ខ្លួនទៅឲ្យយុវជន ដូច្នេះយុវជនមានគំនិតស្អប់ និងមើលស្រាលពលករ និងអ្នកស្រែចម្ការ ។ សរុបមកក្រុមប្រតិកិរិយា បានបង្រៀនយុវជនឲ្យស្អប់វណ្ណៈកម្មករ កសិករដែលជាអ្នកផលិតម្ហូបអាហារ និងឧបករណ៍នានា" ។ នៅក្នុងទស្សនាវដ្តីនោះក៏បានបញ្ជាក់ដែរថា "ក្រោយពីបានទទួលបានការអប់រំខាងនយោបាយ និងសតិអារម្មណ៍ និងទទួលយកកិច្ចការខ្ពស់បំផុតពីបដិវត្តន៍ សមមិត្ត ខុន បានយល់ពីហេតុផលនានា ដែលនាំឲ្យគាត់និងក្រុមគ្រួសារគាត់រងទុក្ខ ។ គាត់បានមើលឃើញពីអំពើសាហាវព្រៃផ្សៃ និងផ្តាច់ការរបស់អ្នកកាន់អំណាចប្រតិកិរិយានានា" ។ សរុបមក "កាលពីសង្គមចាស់ ចក្រពត្តិអាមេរិក និងអាយ៉ង របស់ជនទាំងនោះ បានបំពុលសតិអារម្មណ៍របស់យុវជនយើង ដោយប្រើវប្បធម៌ប្រតិកិរិយា គាបសង្កត់ និងដោយការងារសង្គមកិច្ច" ។ ទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ ចេញផ្សាយខែកុម្ភៈ ឆ្នាំ១៩៧៨ បានសរសេរថា "បក្សកុម្មុយនីស្តកម្ពុជាបានដឹកនាំប្រទេសជាតិប្រជាជន និងយុវជនរបស់ខ្លួនឲ្យធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដើម្បីវាយបណ្តេញចក្រពត្តិអាមេរិក និងបនក្បត់ លន់ នល់ សិរិមតៈ, សឺង ង៉ុកថាញ់ និង អ៊ិន តាំ ដែលតំណាងឲ្យក្រុមសក្តិភូមិនាយទុនប្រតិកិរិយា" ។ ដូចដែលយើងបានដឹងហើយថា ប្រតិកិរិយាត្រូវបានប្រើសំដៅលើក្រុមសក្តិភូមិ និងពួកនាយទុន និងសត្រូវរបស់ខ្មែរក្រហម ។ សត្រូវទាំងអស់រួមមាន លន់ នល់ សិរិមតៈ, សឺង ង៉ុកថាញ់ និង អ៊ិន តាំ ។ សិរិមតៈ សឺង ង៉ុកថាញ់ និង អ៊ិន តាំ ត្រូវបានខ្មែរក្រហមសម្លាប់ ។ លន់ ណុន គឺជាប្អូនប្រុសរបស់ លន់ នល់ ក៏ត្រូវបានសម្លាប់ដែរ ។

**(តទៅលេខក្រោយ)**

**អេង កុកថាយ**

# សវនាការភស្តុតាងស្ដីពីការផ្ដល់សក្ខីកម្មរបស់សាក្សីជំនាញ អេលីហ្សាបែត បេ៊កខ័រ

កាលពីថ្ងៃទី៩-១២ ខែកុម្ភៈ ឆ្នាំ២០១៥ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការអង្គសេចក្ដីលើសំណុំរឿង០០២ ដំណាក់កាលទី២ សួរដេញដោលលើសាក្សីជំនាញមួយរូបឈ្មោះ អេលីហ្សាបែត បេ៊កខ័រ ។ លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានធ្វើការកំណត់ថា លោកស្រី អេលីហ្សាបែត បេ៊កខ័រ គឺជាសាក្សីជំនាញដោយផ្អែកលើសេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ (E២១៥)របស់ខ្លួនថា លោកស្រី អេលីហ្សាបែត បេ៊កខ័រ ត្រូវបានភាគីស្នើសុំមកផ្ដល់សក្ខីកម្ម ដោយសារ ចំណេះដឹងផ្ទាល់ខ្លួនអំពីអង្គហេតុនានា ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងតាមរយៈវត្តមានរបស់គាត់ផ្ទាល់នៅក្នុងអំឡុងពេលនោះ ឬតាមរយៈការធ្វើបទសម្ភាសន៍ជាមួយមេដឹកនាំ ឬកម្មាភិបាលទាំងឡាយ ។ ហេតុដូច្នេះ លោកស្រីត្រូវកោះអញ្ជើញធ្វើជាអ្នកជំនាញ បើទោះបីជាគាត់អាចនឹងត្រូវសួរអំពីអង្គហេតុទាំងឡាយដែលបានដឹងដោយផ្ទាល់ទាក់ទងនឹងសំណុំរឿងនេះក៏ដោយ ។



អ្នកស្រី អេលីហ្សាប៉ែត ប៊េកឃ័រ អតីតអ្នកយកព័ត៌មានឲ្យការសែតវ៉ាស៊ីនតោនប៉ុស្ដិ៍

អ្នកជំនាញ អេលីហ្សាបែត បេ៊កខ័រ កើតនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤៧ សញ្ជាតិអាមេរិក សព្វថ្ងៃរស់នៅទីក្រុងវ៉ាស៊ីនតោន មានមុខរបរជាអ្នកកាសែត និងជាអ្នកនិពន្ធ ។ ប្រវត្តិសិក្សា និងការងាររបស់ខ្លួនលោកស្រី អេលីហ្សាបែត បេ៊កខ័រ បញ្ចប់ការសិក្សាផ្នែកការសិក្សាអំពីអាស៊ីអាគ្នេយ៍ នៅសាកលវិទ្យាល័យវ៉ាស៊ីនតោន ក្នុងរដ្ឋស៊ីអាថល ។ លោកស្រីធ្លាប់បានទទួលការហ្វឹកហាត់ភាសានៅប្រទេសឥណ្ឌា ហើយក្រោយមកនៅឆ្នាំ១៩៧២ លោកស្រីបានក្លាយជាអ្នកកាសែត ។ ដំបូងលោកស្រីបានបម្រើការងារនៅកាសែត ហ្វាអ៊ីសស៊ើន អេកូណូមិក រីវីយូ ហើយបន្ទាប់មក កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ។ លោកស្រីបម្រើការងារជាអ្នកកាសែតអស់រយៈពេលប្រហែល៤០ឆ្នាំ ក្នុងនោះមានដូចជា អ្នកឆ្លើយឆ្លងព័ត៌មានរបស់ការសែតវ៉ាស៊ីនតោនប៉ុស្ដិ៍ ដែលលោកស្រីទើបតែលាឈប់កាលពី៦ឆ្នាំមុន ។ បន្ទាប់មកវិទ្យុសាធារណរដ្ឋជាតិ នៅក្នុងសហរដ្ឋអាមេរិកក្នុងឋានៈជាមន្ត្រីផ្សព្វផ្សាយជាន់ខ្ពស់អន្តរជាតិ ទទួលបន្ទុកអ្នកឆ្លើយឆ្លងព័ត៌មានបរទេសនៅទូទាំងពិភពលោក ។ ដំណែងចុងក្រោយរបស់លោកស្រីគឺជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់កាសែតញូវយ៉កថែមស៍ ។

លោកស្រីបានតាមដានព័ត៌មានសង្គ្រាម រហូតដល់ឆ្នាំ១៩៧៤ ហើយបានត្រឡប់មកកម្ពុជាប្រជាធិបតេយ្យម្តងទៀតក្នុងនាមជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ។ លោកស្រីបាននិពន្ធសៀវភៅនិយាយពីប្រទេសកម្ពុជាឈ្មោះថា "នៅពេលសង្គ្រាមរលត់ទៅ" ហើយសៀវភៅនេះបានបកប្រែជាភាសាបារាំង និងភាសាខ្មែរទៀតផង ។ សៀវភៅមួយក្បាលទៀតឈ្មោះថា "បូប្ផាណា" ដែលមានលក់នៅតែក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ។

សៀវភៅ "នៅពេលដែលសង្គ្រាមរលត់ទៅ" បោះពុម្ពលើកដំបូងនៅឆ្នាំ១៩៨៦ ដោយ ស៊ីម៉ុន និង ស្កាស់ស្ទើ ហើយប្រភពឯកសារយោងមានច្រើនប្រភេទ ដូចជារបាយការណ៍ការងាររបស់លោកស្រី ក្នុងនាមជាអ្នកឆ្លើយឆ្លងព័ត៌មាន នៅពេលសង្គ្រាមចាប់ផ្តើមខ្លាំងនៅឆ្នាំ១៩៧៣ បទសម្ភាសន៍ជាមួយបុគ្គលមួយចំនួន និងនៅអង្គការសហប្រជាជាតិជាមួយអ្នកនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យដូចជា អៀង សារី និង ជួន ប្រសិទ្ធ បទសម្ភាសន៍ជាមួយជនភៀសខ្លួន ពីអ្នកបកប្រែកម្ពុជាពីវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ និងពីអ្នកការទូតកម្ពុជា និងអន្តរជាតិ ព្រមទាំងពីអ្នកស្រាវជ្រាវ ប៊ែន យៀរនិន នៅសាកលវិទ្យាល័យ យែល លោក ស៊្ទីវិន ហេឌ័រ និងអ្នកការសែតពីររូបទៀត ។ លោកស្រី ក៏មានការជួយជ្រោមជ្រែងពីលោក ដេវីដ ហក និង លោក ដេវីដ ឆេនដ៍ល័រ ។ ខណៈដែលលោកស្រីធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីបានជួបសម្ភាសន៍ជាមួយ អៀង សារី អៀង ធីរិទ្ធ និង ប៉ុល ពត ។ វាជាបទសម្ភាសន៍ដែលសំខាន់ជាងគេ ។ បន្ទាប់ពីការចោទសំណួរមូលដ្ឋានមួយចំនួន លោកប្រធានអង្គជំនុំជម្រះបានធ្វើការកំណត់ពីវិសាលភាពក្នុងការសួរដេញដោលរបស់ភាគីទៅកាន់សាក្សីតែត្រឹមប្រធានបទដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ដំណាក់កាលទី២ ប៉ុណ្ណោះ មានដូចជា ៖ ដំណើរទស្សនកិច្ចនៅខែធ្នូ ឆ្នាំ១៩៧៨ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់សាក្សីជំនាញជាមួយ រីឆាដ ដាដមែន និង ម៉ាលខំ ខាដវែល បទសម្ភាសន៍ដែលសាក្សីជំនាញធ្វើជាមួយ អៀង សារី, អៀង ធីរិទ្ធ, ប៉ុល ពត, ជួន ប្រសិទ្ធ កម្មាភិបាលខ្មែរក្រហមផ្សេងទៀត និងជនភៀសខ្លួនកម្ពុជា គោលនយោបាយបក្សទាក់ទងនឹងការប្រព្រឹត្តលើក្រុមជាក់លាក់ ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម និងបទចោទលើការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងបទចោទទាំងឡាយប្រឆាំងនឹងបរិបទអន្តរជាតិ ។

## ការតាំងសំណួរដោយមេធាវីក្រុម ហ្សង់ម៉ាក ឡាវែរញ

ចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវែរញ បានតាំងសំណួរទាក់ទងនឹងជំនួបរវាងសាក្សីជំនាញ លោកស្រី អេលីហ្សាបែត បេកឃ័រ និងមេដឹកនាំខ្មែរក្រហម ។ សាក្សីជំនាញបានជម្រាបជូនអង្គជំនុំជម្រះថា រៀងរាល់ឆ្នាំនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិក្នុងខែតុលា លោកស្រីបានទៅញូវយ៉ក និងចូលរួមសន្និសីទកាសែតឬក៏ធ្វើបដិសណ្ឋារកិច្ចដែលពិភាក្សាជាមួយ អៀង សារី ភាគច្រើន ហើយបន្ទាប់មកគឺ ជួន ប្រសិទ្ធ, គាត ឈុន, ចាន់ យូរ៉ាន់ និង ហ៊ីង សុខុម ពុំមែនជាគណៈប្រតិភូទេ ប៉ុន្តែជាជនជាតិខ្មែរដែលរស់នៅសហរដ្ឋអាមេរិកហើយឈ្មោះរបស់គាត់ត្រូវគេរកឃើញនៅក្នុងបញ្ជីឈ្មោះនៅឯមន្ទីរសន្តិសុខស-២១ ។ ចៅក្រម ហ្សង់ម៉ាក បានសួរដេញដោលអំពីការលើកឡើងរបស់ ខៀវ សំផន ទាក់ទងនឹងស្ថានភាពរបស់ប្រជាជន ក៏ដូចជាការគ្រប់គ្រងប្រទេសនៅចំពោះមុខអង្គការសហប្រជាជាតិ ។ លោកស្រី អេលីហ្សាបែត បេកឃ័រ បានរៀបរាប់ពីដំណើរទស្សនកិច្ចរបស់ខ្លួនថា គឺជាដំណើរដែលមានការត្រួតពិនិត្យគ្រប់ពេលវេលា ។ ទោះជាទៅណាមកណាតែងតែមានអ្នកជូន ហើយមិនអាចជ្រើសរើស និងធ្វើអ្វីដែលខ្លួនចង់ធ្វើបានទេ ។ លោកស្រីអាចនិយាយបានតែក្នុងពេលមានវត្តមានរបស់ ជួន ប្រសិទ្ធ ដែលជាអ្នកបកប្រែប៉ុណ្ណោះ ។ នៅពេលមួយដែលលោកស្រីចេញខាងក្រៅដោយខ្លួនឯង លោកស្រីត្រូវគេបញ្ជូនត្រឡប់មកផ្ទះសំណាក់ដែលចាក់សោវិញ ហើយត្រូវទទួលការស្តីបន្ទោស និងមិនអនុញ្ញាតឲ្យលោកស្រីចេញក្រៅទៀតផង ។ លោកស្រីបានបញ្ជាក់ថា ខ្លួនពិតជាមិនធ្លាប់មានដំណើរទស្សនកិច្ចបែបនេះសោះនៅក្នុងជីវិតរបស់ខ្លួន ។ អ្វីដែលធ្វើឲ្យលោកស្រីមិនសប្បាយចិត្តនៅក្នុងដំណើរទស្សនាទីក្រុងនោះ គឺលោកស្រីពុំបានឃើញអ្វីទាល់តែសោះ មានតែភាពទទេប៉ុណ្ណោះ ។ ចៅក្រម ឡាវែរញ បានព្យាយាមសួរដេញដោលសាក្សីទាក់ទងនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនា ។ សាក្សីជំនាញបានជម្រាបថា វត្តអារាមក៏មានសភាពទទេដែរ ពុំមានទីសក្ការៈ ពុំមានព្រះសង្ឃសូម្បីមួយអង្គ ហើយវត្តមួយ

ចំនួនត្រូវប្រើប្រាស់ជាជង្រុកសម្រាប់ដាក់ស្រូវ ។

**ការសួរដេញដោលដោយសហព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា សេង លាង បានសួរដេញដោលសាក្សីអំពីមូលហេតុដែលខ្មែរក្រហមជ្រើសរើសសាក្សីដើម្បីមកទស្សនាប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីជំនាញ អេលីហ្សាបែត បេ៊ីកខ័រ បានឆ្លើយតបថា ដោយសារខ្មែរក្រហមស្គាល់ខ្លួន តាមរយៈការសរសេរអត្ថបទនៅអំឡុងពេលសង្គ្រាម ហើយខ្លួនបានសួរមេដឹកនាំទាំងនោះ រួមទាំងការសម្ភាសន៍នៅអង្គការសហប្រជាជាតិជារៀងរាល់ឆ្នាំទៀតផង ។ សាក្សីបានស្គាល់សាស្ត្រាចារ្យ ខាតវើល ដែលជាអ្នករួមដំណើរជាមួយថា ខ្លួនពុំធ្លាប់ស្គាល់គ្នាពីមុនមកទេ ប៉ុន្តែសាស្ត្រាចារ្យ ខាតវើល ធ្លាប់សរសេរសៀវភៅមួយក្បាលស្តីពីប្រទេសកម្ពុជា ដូច្នេះសាក្សីបានស្គាល់តាមរយៈស្នាដៃនេះ ។ នៅក្នុងដំណើរទស្សនកិច្ចនោះ លោកស្រីមិនត្រូវទទួលការអនុញ្ញាតឲ្យនាំអ្នកថតរូប ឬអ្នកបកប្រែមកជាមួយនោះទេ ហើយមានតែ ដួន ប្រសិទ្ធ ម្នាក់ប៉ុណ្ណោះដែលជាអ្នកបកប្រែ ។ ព្រះរាជអាជ្ញា បានសួរបញ្ជាក់ពីគោលបំណងរបស់សាក្សីក្នុងការធ្វើទស្សនកិច្ចប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីជំនាញបានឆ្លើយតបថា ពុំមានអ្នកការសែតណាម្នាក់មកធ្វើការសោះនៅក្នុងរបបនេះ ។ លោកស្រីមានចម្ងល់ណាស់ថា តើអ្វីនឹងកើតឡើង? កម្ពុជាប្រជាធិបតេយ្យគឺជាសង្គមមួយបិទជិត ពុំមានការប្រាស្រ័យទាក់ទងពីខាងក្រៅ ពុំមានការភ្ជាប់ខ្សែកាប ពុំមានទូរស័ព្ទ ពុំមានអ្វីទាំងអស់ ។ ជាសង្គមដែលផ្តាច់ខ្លួនពីអ្នកដទៃ ហើយអ្នករាល់គ្នាមានការភ័យខ្លាច ។ សំណួរបន្តពីសហព្រះរាជអាជ្ញាថាតើលោកស្រីបានឃើញអ្វីដែលខ្លួនប្រាថ្នាចង់ឃើញឬទេ? សាក្សីបានឆ្លើយថា លោកស្រីពុំបានឃើញអ្វីដែលខ្លួនប្រាថ្នាចង់ឃើញនោះទេ ហើយស្ថានភាពនៅពេលនោះ គឺស្មើនឹងការឃុំខ្លួននៅក្នុងផ្ទះដែរ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា កម្ពុជាប្រជាធិបតេយ្យបានបដិសេធថា ពុំមានមន្ទីរឃុំឃាំង ឬគុកនោះទេ ។ សាក្សីធ្លាប់បានធ្វើបទសម្ភាសជាមួយ អៀង ធីរិទ្ធ នៅក្នុងទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នៅជិតអង្គការសហប្រជាជាតិ ។ នៅពេលនោះ អៀង ធីរិទ្ធ បានផ្តល់សម្ភាសថា ខ្លួនបានធ្វើដំណើរទៅទស្សនាពីស្ថានភាពប្រជាជន ហើយនៅពេលខ្លួនត្រឡប់មកទីក្រុងភ្នំពេញវិញ បានរាយការណ៍ជូនមេដឹកនាំថា មានរឿងចម្លែកនៅតាមបណ្តាខេត្តខ្លះ ។ ឧទាហរណ៍ ដូចជា ខេត្តបាត់ដំបង អៀង ធីរិទ្ធ បានឃើញច្បាស់ពីប្រជាជនដែលត្រូវទៅធ្វើស្រែ ដែលមានទីតាំងឆ្ងាយដាច់ស្រយាលពីភូមិ ។ ប្រជាជនទាំងនោះគ្មានផ្ទះស្នាក់នៅទេ និងឈឺគ្រប់ៗគ្នា ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកស្រី អេលីហ្សាបែត បានជម្រាបថា មានការបែងចែកប្រជាជនពិតប្រាកដមែន ។ វាគឺជាប្រព័ន្ធនៃការផ្តល់អភ័យឯកសិទ្ធិមួយដែលថាប្រជាជនថ្មីត្រូវបានគេប្រព្រឹត្តមិនសមរម្យ ដូចជាចំណីអាហារ ពេលវេលាធ្វើការ កម្លាំងពលកម្ម និងឋានានុក្រមជាដើម ។ (**នៅមានត**)

**ឌី សុជាតា**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រង៉ែ ស្រុកត្រាំកក់ ខេត្តតាកែវ បាត់ខ្លួននៅឆ្នាំ១៩៧៩ ពេលវៀតណាមចូល ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ យុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៤ ៩៦៧ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

# ៤០ឆ្នាំ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ តើកម្ពុជាបានដោះស្រាយជាមួយអតីតកាលរបស់ខ្លួនឬនៅ?

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ហើយបានចាប់ផ្តើមយុទ្ធនាការទូទាំងប្រទេសរបស់ខ្លួន ដើម្បីអនុវត្តការដឹកនាំបែបផ្តាច់ការបំផុតនៃលទ្ធិកុម្មុយនីស្តជ្រុលនិយម ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ។ ប៉ុន្តែផែនការដើម្បីសម្រេចឲ្យបាននូវសង្គមកុម្មុយនីស្តដ៏ល្អផូរផង់នោះបានបរាជ័យជាខ្លាំង ។ ជាងនេះទៅទៀត បដិវត្តន៍នេះបានក្លាយទៅជាយុទ្ធនាការនៃការបំផ្លិចបំផ្លាញ និងឃាតកម្មទៅវិញ ។ ជាលទ្ធផល ប្រជាជនជិតពីរលាននាក់បានស្លាប់ និងជាច្រើននាក់ទៀតបានរងរបួសផ្លូវកាយ និងផ្លូវចិត្តដ៏គួរឲ្យរន្ធត់ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមដែលត្រូវបានស្គាល់ជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំចេញពីអំណាច ។ ក្រោយពីរបបនេះ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងស្ថានភាពខ្ទេចខ្ទាំបំផុតស្ទើរតែគ្មានធនធាន និងមធ្យោបាយចិញ្ចឹមជីវិតខ្លួនឯង ។ សេដ្ឋកិច្ចពុំសូវមានដំណើរការ រីឯជំនួយផ្នែកហិរញ្ញវត្ថុដែលត្រូវការជាចាំបាច់សម្រាប់កសាងប្រទេសឡើងវិញក៏ពុំមានគ្រប់គ្រាន់ ។ ចំណែកឯធនធានមនុស្សដែលជាធនធានដ៏សំខាន់បំផុតសម្រាប់កសាងប្រទេសជាតិក៏ខ្វះខាត ។ មន្ត្រីរាជការ និងបញ្ញវន្តជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់ ហើយមួយចំនួនទៀតភៀសខ្លួនចេញទៅក្រៅប្រទេស ។ ការចាកចេញរបស់អ្នកមានចំណេះដឹង និងកង្វះខាតអ្នកជំនាញយ៉ាងគំហុកនេះធ្វើឲ្យការកសាងប្រទេសស្ទើរតែគ្រប់វិស័យជួបបញ្ហាប្រឈមជាខ្លាំង ។ ការពិតគឺថា កេរដំណែលនៃរបបខ្មែរក្រហមនៅតែបន្តរាលដាលពេញស្ថាប័ន និងសង្គមខ្មែរបច្ចុប្បន្ននេះ ។

ចាប់តាំងពីខ្មែរក្រហមឡើងកាន់កាប់អំណាចមកដល់ឥឡូវនេះ វាមានរយៈពេលជាងបួនទសវត្សរ៍ ហើយបើគិតចាប់តាំងពីរបបនេះបានដួលរលំ វាមានរយៈពេលជាង៣៦ឆ្នាំទៅហើយ ។ នេះគឺតម្រូវឲ្យយើងក្រឡេកមើលទៅក្រោយ និងវាយតម្លៃពីវិសាលភាពដែលកម្ពុជាបានដោះស្រាយជាមួយនឹងអតីតកាលដ៏ឈឺចាប់របស់ខ្លួន ។

**ភាពជោគជ័យ**



កងយោធាខ្មែរក្រហមដើរចូលទីក្រុងភ្នំពេញ នៅថ្ងៃជ័យជម្នះ ១៧ ខែមេសា ឆ្នាំ១៩៧៥

ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីដោះស្រាយជាមួយអតីតកាលរបស់ខ្លួន ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបពីវិធីសាស្ត្រសំខាន់ៗមួយចំនួន ។ ស្ទើរតែភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ របបថ្មីទីក្រុងភ្នំពេញបានបង្កើតនូវតុលាការកាត់ទោសរបបប្រល័យពូជសាសន៍ជាលើកដំបូងនៅលើពិភពលោកដោយធ្វើការកាត់ទោសកំបាំងមុខនូវមេដឹកនាំខ្មែរក្រហមពីររូបគឺ ប៉ុល ពត និង អៀង សារី ។ តុលាការឆ្នាំ១៩៧៩នេះ

ដែលមានការទទួលស្គាល់តិចតួច និងទទួលរងការរិះគន់ច្រើននោះ បានផ្តន្ទាទោសប្រហារជីវិតដល់ជនជាប់ចោទទាំងពីររូបនេះ ។ សាលក្រមនេះ ដែលពុំត្រូវបានមជ្ឈដ្ឋានទូទៅទទួលស្គាល់ មិនត្រូវបានយកមកអនុវត្តនោះទេ ដោយសារតែជនជាប់ទាំងពីរនាក់នេះរស់នៅតាមបណ្តោយព្រំដែនថៃហើយបន្តធ្វើសង្គ្រាមឈ្លបរហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែល ប៉ុល ពត បានស្លាប់ និងខ្មែរក្រហមដទៃទៀតបានចុះចាញ់ ។

ដោយសារហេតុផលមួយចំនួន របបថ្មីនេះក៏បានចាត់វិធានការជាបន្ទាន់ដើម្បីបង្ហាញទៅកាន់ពិភពលោកនូវបទឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម ។ គុកសម្ងាត់ខ្មែរក្រហម ស-២១ ដែលបច្ចុប្បន្ននេះក្លាយទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង រួមទាំងវាលពិឃាតជើងឯក បានក្លាយជាបូជនីយដ្ឋានប្រវត្តិសាស្ត្រ ។ ភ្លាមៗក្រោយពីការដួលរលំនៃរបបខ្មែរក្រហម រដ្ឋាភិបាលថ្មីបានធ្វើការចាប់ខ្លួនអតីតខ្មែរក្រហមមួយចំនួន និងជួយទប់ស្កាត់ការកាប់សម្លាប់សងសឹងគ្នាដែលកំពុងកើតឡើងនៅពេលនោះ ។ របបថ្មីនេះក៏បានណែនាំឲ្យមានការបង្កើត និងថែរក្សាបូជនីយដ្ឋាន និងឯកសារជាច្រើនទូទាំងប្រទេស ។ នៅក្នុងចំណោមកិច្ចខំប្រឹងប្រែងទាំងឡាយ យើងឃើញមានយុទ្ធនាការទូទាំងប្រទេសមួយត្រូវបានបង្កើតក្នុងគោលបំណងប្រមូលការគាំទ្រពីជនរងគ្រោះដើម្បីផ្តោលទោសឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម និងប្តឹងទៅអង្គការសហប្រជាជាតិដើម្បី «បដិសេធការទទួលស្គាល់» ខ្មែរក្រហមជាតំណាងស្របច្បាប់របស់កម្ពុជា ។ យុទ្ធនាការនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ នេះអាចប្រមូលបានញត្តិគាំទ្រពីអ្នករស់រានមានជីវិតដ៏ច្រើនសន្ធឹកសន្ធាប់ដែលក្នុងនោះមានស្នាមផ្តិតមេដៃច្រើនជាងមួយលាននាក់ ។ ញត្តិនេះក្រោយមកត្រូវបានស្គាល់ថាជា ញត្តិរណសិរ្ស ។

ក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានដកចេញទាំងស្រុងពីកម្មវិធីសិក្សាថ្នាក់ជាតិ ដើម្បីជាប្រយោជន៍ដល់ការផ្សះផ្សាជាតិ ។ រហូតមកដល់ឆ្នាំ២០០៧ ការបង្រៀនប្រវត្តិសាស្ត្រនេះនៅតែមិនទាន់ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សានោះទេ ។ នៅឆ្នាំ២០០៤ គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមធ្វើការដោយឯករាជ្យក្នុងការចងក្រងជាសំណេរឡើង ដែលក្រោយមកត្រូវបានគេស្គាល់ថាជាសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)» ។ សៀវភៅនេះត្រូវបានបោះពុម្ព និងទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមកិច្ចការងារដ៏សំខាន់មួយក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់វិទ្យាល័យទូទាំងប្រទេស ស្តីពីបរិបទ និងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ចាប់តាំងពីពេលនោះមក រាជរដ្ឋាភិបាលកម្ពុជាបានដាក់ជាកំហិតឲ្យមានការសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅកម្រិតសាកលវិទ្យាល័យទូទាំងប្រទេស ។

ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ និងក្រោយពីសង្គ្រាមស៊ីវិលអស់ជាងពីរទសវត្សរ៍មកនេះ ប្រទេសកម្ពុជាបានបោះជំហានទៅមុខយ៉ាងខ្លាំងក្នុងការធានាឲ្យបាននូវសន្តិភាព ស្ថិរភាព និងការផ្សះផ្សាជាតិមួយផ្នែកធំ ។ ការបោះឆ្នោតដែលជ្រោមជ្រែងដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៩៣ បានពាំនាំមកនូវលទ្ធិប្រជាធិបតេយ្យមួយផ្នែកមកឲ្យប្រទេសកម្ពុជា ដែលបានជួយបើកចំហរព្រំដែន និងសេដ្ឋកិច្ចរបស់កម្ពុជាឡើងវិញផងដែរ ។

ចាប់តាំងពីឆ្នាំ១៩៩៩ សង្គ្រាមស៊ីវិល និងការតស៊ូប្រដាប់អាវុធត្រូវបានបញ្ចប់ រីឯកងទ័ពខ្មែរក្រហមត្រូវបានរំសាយ និងធ្វើសមាហរណកម្មមកក្នុងសង្គមខ្មែរវិញ ។ ទន្ទឹមនេះដែរ សាលាក្តីខ្មែរក្រហមដែលមានតួនាទីដោះស្រាយនូវការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងសមូហភាព ក៏កំពុងតែបំពេញបេសកកម្មដ៏សំខាន់របស់ខ្លួននៅក្នុងការផ្តល់នូវយុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ជាការពិតណាស់ ចំពោះលទ្ធផលរបស់សាលាក្តីនេះនឹងមានប្រជាជនមួយចំនួនពេញចិត្ត ប៉ុន្តែក៏នឹងមានប្រជាជនមួយចំនួនទៀតដែលនឹងមិនពេញចិត្តនោះទេ ហើយក៏មានប្រជាជនមួយចំនួនទៀតនឹងមានការស្ទាក់ស្ទើរ ។ សាលាក្តីខ្មែរក្រហមនេះមានសារសំខាន់មិនត្រឹមតែដើម្បីបញ្ចប់និទណ្ឌភាពនៃរបបខ្មែរក្រហមប៉ុណ្ណោះទេ វាក៏ជាការបើកឲ្យមានកិច្ចសន្ទនាស្តីពីយុត្តិធម៌ និងអតីតកាលផងដែរ ។

**ផ្លូវខាងមុខ**

យ៉ាងហោចណាស់ ប្រទេសកម្ពុជាបានដោះស្រាយនឹងអតីតកាលរបស់ខ្លួនមួយកម្រិតរួចមកហើយ ទោះបីជាកិច្ចខំប្រឹងប្រែងនោះនៅតែបន្តយ៉ាងណាក្តី ។ ទាក់ទិននឹងកិច្ចខំប្រឹងប្រែងក្នុងការអប់រំអ្នកជំនាន់ថ្មីស្តីពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងរយៈពេលនេះ គឺទើបតែចាប់ផ្តើមនោះទេ ។ កិច្ចខំប្រឹងប្រែងនេះចាំបាច់ត្រូវតែបន្តវាយតម្លៃ និងធ្វើឲ្យប្រសើរឡើងដើម្បីចូលរួមចំណែកក្នុងការផ្សះផ្សាជាតិ និងការពារមិនឲ្យរបបប្រល័យពូជសាសន៍កើតឡើងវិញ ។

ទោះបីជាមានកិច្ចខំប្រឹងប្រែងជាច្រើនត្រូវបានអនុវត្តឡើងដើម្បីឲ្យអតីតយុទ្ធជនធ្វើសមាហរណកម្មចូលក្នុងចំណោមប្រជាជនទូទៅ ក៏វានៅមានគម្លាតឆ្ងាយពីគ្នាក្នុងកម្រិតមួយរវាងអតីតខ្មែរក្រហម និងជនរងគ្រោះ ក៏ដូចជាក្មេងជំនាន់ក្រោយផងដែរ ។ កិច្ចខំប្រឹងប្រែងច្រើនជាងនេះចាំបាច់ត្រូវធ្វើឡើងដើម្បីតភ្ជាប់ទំនាក់ទំនងនៅក្នុង និងរវាងសហគមន៍ទាំងឡាយដែលនេះមានន័យថា អតីតខ្មែរក្រហមអាចបើកចំហពីប្រវត្តិរបស់ខ្លួនដោយមិនមានការភ័យខ្លាចចំពោះការសងសឹក ចំណែកឯជនរងគ្រោះវិញ អាចពិភាក្សាពីបទពិសោធន៍របស់ខ្លួននៅក្នុងវេទិកាសាធារណៈដែលគោរព និងឲ្យតម្លៃរឿងរ៉ាវដែលពួកគាត់ចែករំលែក ។

អត្តសញ្ញាណជាខ្មែរក្រហមនៅតែកប់យ៉ាងជ្រាលជ្រៅនៅក្នុងចិត្តគំនិតរបស់ពួកគាត់ បូកផ្សំនឹងជំងឺផ្លូវចិត្ត ក៏ដូចជាការភ័យខ្លាចចំពោះការរើសអើងឬការជាប់ពាក់ព័ន្ធផ្សេងៗដែលអាចឲ្យគាត់ត្រូវបានគេនាំខ្លួនមកចំពោះមុខសាលាក្តីខ្មែរក្រហម ។ ការអាម៉ាស់មុខ ការបដិសេធ និងការភ័យខ្លាច គឺជាជញ្ជាំងរារាំងពិតប្រាកដដែលលើកទឹកចិត្តឲ្យអតីតខ្មែរក្រហមមួយចំនួនជៀសវាងការពិភាក្សាពីប្រវត្តិសាស្ត្រ ជាពិសេស នៅពេលដែលការពិភាក្សានេះទាក់ទិនទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។

ដោយសារហេតុផលដូចគ្នានេះ មានអតីតខ្មែរក្រហមមួយចំនួនមិនលើកទឹកចិត្តឲ្យកូនរបស់ខ្លួនរៀនពីប្រវត្តិសាស្ត្រដែលជាប់ពាក់ព័ន្ធនោះទេ ។ ទាំងនេះបានធ្វើឲ្យការអប់រំអំពើប្រល័យពូជសាសន៍ជួបការលំបាក ជាពិសេសនៅក្នុងអតីតតំបន់កាន់កាប់ខ្មែរក្រហម ដូចជា ប៉ៃលិន ម៉ាឡៃ អន្លង់វែង និងតំបន់ផ្សេងទៀតដែលមានអតីតខ្មែរក្រហមរស់នៅច្រើន ។

កិច្ចខំប្រឹងប្រែងជាច្រើនទៀតត្រូវតែបន្តធ្វើដើម្បីដោះស្រាយឧបសគ្គទាំងនេះ ហើយបង្កើតឲ្យមានការផ្សះផ្សាទាំងថ្នាក់ជាតិ និងបុគ្គលផ្ទាល់ ។ នេះមិនត្រឹមតែមានរួមបញ្ចូលនូវដំណើរការនិងការសម្រេចឲ្យបាននូវការរស់នៅចុះសម្រុងគ្នាដោយអហិង្សាប៉ុណ្ណោះទេ វាថែមទាំងរួមបញ្ចូលនូវការបណ្តុះការទុកចិត្តជឿជាក់គ្នាទៅវិញទៅមកក្នុងការបង្កើតអនាគតរួមមួយដែលផ្តោតទៅលើទំនួលខុសត្រូវ និងភាពជាមនុស្ស ។

មុនពេលដែលយើងអាចបណ្តុះវប្បធម៌យោគយល់ និងយល់ដឹងពីគ្នាជាដំបូងយើងត្រូវមានបរិយាកាសមួយដែលអនុញ្ញាតនិងលើកទឹកចិត្តឲ្យមានការសន្ទនាជាមុនសិន ។ ដូច្នេះ កិច្ចសន្ទនាដែលបើកចំហ និងពេញលេញមួយដែលមានបរិយាកាសអំណោយផលដល់ការសន្ទនាជាអន្តរជំនាន់ គឺជាអ្វីដែលគួរបន្តធ្វើ ។ កិច្ចសន្ទនានេះមិនត្រឹមតែគួរធ្វើឡើងជាមួយជនរងគ្រោះតែម្ខាងនោះទេ ប៉ុន្តែក៏គួរធ្វើជាមួយអតីតខ្មែរក្រហមដែរ ។ កិច្ចពិភាក្សាបើកចំហនេះ អាចធ្វើឡើងនៅកន្លែងធម្មតា ដូចជា នៅផ្ទះ ឬក្នុងភូមិ ឬ នៅកន្លែងផ្លូវការផ្សេងៗ ដូចជា សាលារៀន ឬក្នុងវេទិកាសាធារណៈ ។ ដើម្បីអនុញ្ញាតឲ្យអតីតខ្មែរក្រហមអាចបើកចំហរដោយគ្មានការភ័យខ្លាចចំពោះការសងសឹក កិច្ចខំប្រឹងប្រែងច្រើនទៀតចាំបាច់ត្រូវធ្វើឡើងដើម្បីធានាឲ្យបាននូវការយល់ដឹងជាសាធារណៈពីវិសាលភាពនៃសាលាក្តីខ្មែរក្រហម ដែលកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ។

ទោះបីជារយៈពេលក្រោយសាលាក្តីខ្មែរក្រហមត្រូវបានបញ្ចប់ គឺជាពេលវេលាដ៏សំខាន់បំផុតក្នុងការបង្កើតឲ្យមាននូវបរិយាកាសអំណោយផលសម្រាប់កិច្ចសន្ទនានេះ កិច្ចខំប្រឹងប្រែងដើម្បីកសាងទំនុកចិត្តគួរតែត្រូវបានលើកទឹកចិត្ត និងពង្រឹងចាប់ពីពេលនេះទៅ ។ នៅពេលមានការពិភាក្សាដោយចំហគ្រប់ជំនាន់កើតឡើង នោះគឺជាពេលដែលប្រជាជនកម្ពុជាអាចងើបចេញពីផ្នត់គំនិតជាជនរងគ្រោះ និងឈានទៅមុខរកអនាគតថ្មី ។ ប្រសិនបើគ្មានការដោះស្រាយជាមួយនឹងអតីតកាលដ៏យោរយៅរបស់ខ្លួនប្រកបប្រសិទ្ធភាពនោះទេ កម្ពុជានឹងប្រឈមការលំបាកក្នុងការដោះស្រាយបញ្ហានាពេលបច្ចុប្បន្ន និងអនាគតរបស់ខ្លួន ។

**ឌី ខេមរិទ្ធិ និង ត្រី ស៊ុយហៀង**

# រសាត់តាមខ្យល់

**ទឹកភ្នែកអ្នកម៉ែ**



ប៉ុក ប៊ុនសូម៉ាដ

រាត្រីនេះជារាត្រីរនោច ផ្ទៃមេឃងងឹតសូន្យសុង ដុំពពកខ្មៅអ័ព្ទកំពុងតែរសាត់អណ្តែតយ៉ាងខ្ជូលខ្ជាញ់ពាសពេញលំហអាកាស ផ្លេកបន្ទោរចាំងរស្មីប្រវាត់ភ្លឺព្រាកៗយ៉ាងញាប់រន្ថើន សំឡេងផ្គរលាន់ឮគងរំពងបន្តគ្នារហូតដល់ដើងមេឃម្ខាងគួរឲ្យព្រឺព្រួចកណ្តាលវេហាក៏ខ្ពស់សន្ធឹម ដួងព្រះខែនៅសល់តែមួយចំណិតដួង កំពុងបែងចាំងពន្លឺយ៉ាងស្រទន់ព្រឿងៗកាត់ស្បែងងឹតនៃរាត្រីជាមួយនឹងខ្យល់ដំនោរដែលកំពុងតែបក់ធ្លាក់មកយ៉ាងត្រជាក់ ស្រាប់តែក្នុងមួយរំពេចនោះ មានធ្លាក់ភ្លៀងមួយមេធំយ៉ាងគំហុក ភ្លៀងធ្លាក់ដូចហែកមេឃ ។

ខ្ញុំឈរតែម្នាក់ឯងប្រឈមនឹងមាត់បង្អួច ឈរសម្លឹងមើលតំណក់ទឹកភ្លៀងដែលកំពុងតែស្រក់ធ្លាក់ប៉ះស្លឹករុក្ខជាតិចាំងឆ្លុះនឹងពន្លឺដួងខែភ្លឺផ្លេកៗ ភ្លៀងធ្លាក់រណ្តំគ្នាឥតអាក់ដូនតិចដូនខ្លាំង ឮសូរដូចបទចម្រៀងបំពេររាត្រីសែនពិរោះដក់ចិត្ត ខ្យល់ដំនោរបក់បោកពុំឈប់ឈរបក់ចុងព្រឹក្សាឲ្យទោរទន់រេរាំទាំងកណ្តាលរាត្រី ដ៏សែនស្ងាត់ជ្រងំ ខ្ញុំកំពុងតែស្ទុងអារម្មណ៍លង់លក់ក្នុងសុបិនពីអតីតកាលមួយ ។

កាលពីគ្រាមុន ទាំងកណ្តាលយប់ស្ងាត់ ហើយមានធ្លាក់ភ្លៀងយ៉ាងខ្លាំងបែបនេះ ខ្ញុំតែងតែមានអារម្មណ៍ព្រឺព្រួចភ័យខ្លាច ក្រៅពីនឹកខ្លាចដល់ភាពអន្ធការនៃរាត្រីកាល ខ្លាចស្នូររន្ទះផ្គរលាន់ ខ្លាចពន្លឺផ្លេកបន្ទោរដ៏ប្រវាត់ ខ្ញុំនៅនឹកខ្លាចដល់រឿងរ៉ាវផ្សេងៗទៀតរាប់មិនអស់ ។

ក្នុងសភាពបែបនេះហើយ ដែលរៀងរាល់យប់ ខ្ញុំតែងតែដេកគ្រលុំភួយតាំងពីក្បាលរហូតដល់ចុងជើង ទោះជាដេកមិនលក់ដោយភាពស្អុះស្អាប់ ឬដោយបែកញើសរហាមជោកខ្លួនយ៉ាងណាក៏ដោយ ក៏ភ្នែកទាំងគូរបស់ខ្ញុំនៅបានប្រឹងធ្មេចរហូតទល់ភ្លឺ ។

កាលណោះ ខ្ញុំទើបតែនឹងបានចូលរៀនថ្នាក់ដំបូងនៅសាលាបឋមសិក្សានៅឡើយ ខ្ញុំមានចិត្តស្រឡាញ់ការរៀនសូត្រ ជាពិសេសខ្ញុំស្រឡាញ់ថ្នាក់រៀនរបស់ខ្ញុំយ៉ាងខ្លាំង ក្រោមដំបូលប្រក់ស្លឹកនៃអគារឈើបីបន្ទប់មួយខ្នង សង់ទទឹងថ្ងៃប្រឈមនឹងម្លប់គគីរដ៏ត្រឈុំត្រឈៃនៅជ្រុងខាងត្បូងនៃបរិវេណវត្តសារិការាម ទីនោះហើយដែលលោកគ្រូ ឈឹម ជោត គឺជាអ្នកដំបូងបង្អស់ដែលបានបង្ហាត់បង្រៀនខ្ញុំឲ្យចេះស្រឡាញ់អក្សរសាស្ត្រខ្មែរ ។

លោកគ្រូមានសណ្តានចិត្តល្អបរិសុទ្ធជ្រះថ្លាណាស់ លោកបានចំណាយលះបង់កម្លាំងកាយចិត្ត កម្លាំងថវិកាផ្ទាល់របស់លោកកសាងសាលារៀនមួយអគារនេះសម្រាប់ខ្មែរ ដែលមានឈ្មោះថាសាលាបឋមសិក្សា ឈឹម ជោតិបាល ។

ខ្ញុំតែងតែគោរពស្រឡាញ់ និងដឹងគុណលោកគ្រូរហូតជានិរន្តន៍ ព្រោះមានរឿងរ៉ាវ និងដំបូន្មានល្អៗច្រើនណាស់រាប់មិនអស់ដែលលោកបានអប់រំប្រៀនប្រដៅដល់រូបខ្ញុំ ហើយដែលជួយស្រឡះទៅវិញរឿងរ៉ាវ និងដំបូន្មានល្អៗទាំងនោះ ខ្ញុំពុំដែលបានឮទាល់តែសោះនៅក្រោមដំបូលផ្ទះរបស់ខ្ញុំ ។

ដោយសារហេតុផលផ្សេងៗទៀតជាច្រើន ដែលខ្ញុំតែងតែអន្ទោកអន្ទោលចង់ទៅសាលារៀន ភ្លាមៗទោះបីជាមិនទាន់ដល់ម៉ោង ឬទើបតែនឹងភ្ញាក់ពីដេកក៏ដោយ ។ រាល់ពេលដែលខ្ញុំបានទៅដល់ទីនោះ ហើយដែលពុំទាន់មាននរណាម្នាក់ទៅដល់នៅឡើយខ្ញុំសែនរំភើបក្នុងចិត្ត ខ្ញុំរីករាយត្រេកត្រអាលនឹងបរិយាកាសជុំវិញដ៏ស្ងប់ស្ងាត់ ។

ខ្ញុំផ្ទេកក្បាលថ្នមៗទៅលើតុ ភ្នែកទាំងគូរបស់ខ្ញុំចាប់ផ្តើមបិទសន្សឹមៗបន្តិចក្រោយមក ខ្ញុំក៏បានដេកលក់យ៉ាងស្កប់ស្កល់ ។ គ្មានអ្វីមករំខានខ្ញុំឡើយ ជួនកាលខ្ញុំដេកយល់សប្តិឃើញរឿងប្លែកៗ

តែគួរឲ្យសោកស្តាយដោយជាញឹកញយសុបិនរបស់ខ្ញុំទាំងនោះ វាហាក់ដូចជាច្របូកច្របល់ ខ្ញុំពុំដែលបានចងចាំ ឬនឹកឃើញទាល់តែសោះគ្រាដែលខ្ញុំបានភ្ញាក់ដឹងខ្លួនឡើង ។

ក្នុងថ្នាក់រៀន ដោយសារតែលោកគ្រូមានទម្លាប់និយាយតិចៗ និងជួនកាលស្រែកឲ្យពួកខ្ញុំខ្លាំងៗពេក ទើបពួកយើងបាននាំគ្នាដាក់ឈ្មោះឲ្យគាត់ដោយកំបាំងថា «លោកគ្រូដោតឡូឡា» ។

ពេលម៉ោងរៀនទាំងអស់គ្នា ក្នុងថ្នាក់ត្រូវមានសណ្តាប់ធ្នាប់រក្សារបៀបរៀបរយ និងភាពស្ងាត់ស្ងៀមយ៉ាងខ្ជាប់ខ្ជួន បើមិនដូច្នោះទេ នឹងត្រូវទទួលទណ្ឌកម្មបោចស្មៅសម្អាតផ្លាសាលា ឬក៏ឈរហាលថ្ងៃនៅពីមុខដងទង់ជាតិរាប់ម៉ោងជាពុំខាន ។

ក្នុងថ្នាក់រៀនរបស់ខ្ញុំ ដែលមានកូនសិស្សប្រុសស្រីជាងដប់នាក់ លោកគ្រូអង្គុយនៅនឹងតុធំមួយ ចំពីមុខពួកយើង ជាមួយនឹងភាពយ៉ាងម៉ឺងម៉ាត់ កែវភ្នែកទាំងគូដ៏មុតស្រួចរបស់គាត់ពួកយើងសឹងតែគ្មាននរណាម្នាក់ហ៊ានកម្រើកខ្លួនឡើយ ។

រាល់ពេលសម្រាកចេញលេង ខ្ញុំតែងតែដើរទៅលេងនៅឯផ្លាខាងក្រោយសាលាឆ្ងាយពីពួកគេ ដោយស្ងៀមស្ងាត់ ។ ជួនកាលខ្ញុំដើរហួសចូលទៅក្នុងព្រៃល្បោះ ដើរកាត់វាលកូនត្បែង កូនពួចទៅបេះផ្កាក្រវាន់ដែលកំពុងរីកចោលក្លិនក្រអូបពេញព្រៃ ។

ខ្ញុំពុំសូវចូលចិត្តលេងជាមួយក្មេងដទៃទៀតឡើយ ខ្ញុំខ្លាចណាស់ការទាស់ទែងវាយតប់គ្នាដែលមិត្តរួមថ្នាក់ ខ្ញុំយល់ថា ទោះជាមានការទាស់ទែងគ្នាខ្លះវារឿងធម្មតា ដែលពួកគេអាចបំភ្លេចបានយ៉ាងងាយនៅថ្ងៃបន្ទាប់ វាផ្ទុយស្រឡះពីរូបខ្ញុំដែលខ្ញុំពិបាកនឹងបំភ្លេចណាស់ទោះជារឿងដែលបណ្តាលឲ្យរលាត់ស្បែកខ្ញុំតែបន្តិចក៏ដោយ ក៏ខ្ញុំនៅតែចាំមិនភ្លេចអស់មួយជីវិត ។

ទាំងលោកគ្រូ ទាំងមិត្តរួមថ្នាក់ទាំងអស់គ្នា ពុំមាននរណាម្នាក់ចាប់អារម្មណ៍នឹងភាពឯកោរបស់ខ្ញុំឡើយ ហើយដោយខ្ញុំមិនអាចសរសេរ ឬគិតលេខឲ្យបានរហ័សដូចសិស្សផ្សេងខ្លះទៀតនោះ និងព្រោះតែខ្ញុំខិតខំផ្ចិតផ្ចង់ខ្លាំងពេក ធ្វើឲ្យលោកគ្រូទើសទាល់តឹងក្នុងចិត្តគាត់យ៉ាងខ្លាំង រហូតមានពេលខ្លះគាត់បានស្រែកសំឡុតឲ្យខ្ញុំខ្លាំងៗថា «ម៉េចក៏មិនសរសេរឲ្យលឿនឡើង!» ។ ការពិតខ្ញុំក៏មានចេតនានឹងសរសេរ ឬគិតលេខឲ្យបានរហ័សដូចសិស្សដទៃទៀតដែរ តែរាល់ពេលដែលខ្ញុំបានឮសូរសម្រែករបស់គាត់ ខ្ញុំភាន់ភាំង ខ្ញុំវង្វេងវង្វាន់ពោល គឺវិញ្ញាណទាំងអស់របស់ខ្ញុំ វាហាក់ដូចជាពុំមានស្ថិតនៅក្នុងខ្លួនខ្ញុំទៀតឡើយ ។

រៀងរាល់ថ្ងៃមុនពេលចេញទៅផ្ទះ សិស្សទាំងអស់ត្រូវក្រោកឈរឡើយដោយគោរព ហើយចាប់សូត្រមេសូត្ររត់មាត់ដែលម្នាក់ៗ ត្រូវស្រែកឲ្យបានខ្លាំងយ៉ាងណាដែលអាចខ្លាំងទៅបាន ។ សូត្រចប់សឹងតែមិនទាន់ផុតពីមាត់ ម្នាក់ៗត្រៀមជើងជាស្រេចក្នុងខណៈដែលលោកគ្រូគោះតុ «ដូង» ជាមួយនឹងរំពាត់ផ្តៅកញ្ចាស់មួយជាសញ្ញាឲ្យដឹងថា យើងអាចចេញទៅផ្ទះបានហើយ ពួកយើងរត់ព្រូចេញពីជួរតុតម្រង់ទៅកាន់មាត់ទ្វារ ។

តាមដងផ្លូវពីសាលាទៅផ្ទះ ដែលមានចម្ងាយប្រមាណជាងមួយគីឡូម៉ែត្រ ខ្ញុំដើរលេងៗយឺតៗ ដោយមិនចាំបាច់ប្រញាប់ប្រញាប់រួសរាន់ឲ្យឆាប់ដល់ផ្ទះដូចសិស្សដទៃទៀតឡើយ ។ អាខេមដែលរស់នៅនឹងភូមិត្រពាំងឫស្សី ក្បែរនោះបានស្រែកសួរខ្ញុំជាញឹកញយថា «អ្នកងមិនឃ្លានបាយឬទេ? ។ ពេលដែលខ្ញុំបានដើរមកដល់ស្ពានថ្មខ្លោងទ្វារវត្តសារិការាម អាខេម បែកផ្លូវឆ្ពោះទៅទិសខាងលិច ដែលមើលពីក្បាលស្ពានទៅឃើញដំបូលផ្ទះអ្នកភូមិលិមៗ ផុសចេញពីចុងឈើដ៏ខៀវស្រងាត់ ។

ខ្ញុំឈរទ្រឹងលើស្ពាន សម្លឹងមើលទឹកហូររដូវចម្រូតទឹកស្រកនៅសល់តែកន្លះមាត់អូរ ទឹកថ្លាយង់ មើលធ្លុះឃើញដល់បាតដី ហ្វូងមច្ឆាជាតិតូចៗចម្រុះពណ៌កំពុងតែប្រឹងហែលប្រណាំងគ្នាទាំងហ្វូងៗឡើងបញ្ច្រាសទឹកហូរ បក់កន្ទុយរវិចៗ គន់មើលយូរៗទៅគួរជាទីជាប់ចិត្ត ។ វាលស្រែទាំងសងខាងផ្លូវ ដែលទើបតែនឹងបានច្រូតកាត់ហើយថ្មីៗ តាមចន្លោះគុម្ពជញ្ជ្រាំងផ្កាថ្កូកទឹកពណ៌លឿងលាយឡំនឹងផ្កាម្អមស្រែតូចៗពណ៌ស្វាយរីករហង់ពាសវាលក្នុងទឹកស្រែដ៏ថ្លាខ្យង ដើរបណ្តើរខ្ញុំយកជើងទាត់គុម្ពជញ្ជ្រាំងស្រូវបែកទឹកខ្ចាយសំពោងលេងបណ្តើរពោះខ្ញុំចាប់ផ្តើមកូរដោយក្តីស្រេកឃ្លាន គ្រាដែលក្លិនម្អមស្រែដ៏ប្រហើរឈ្ងុយឈ្ងប់បានឈ្លបភាយមកប៉ះនឹងនាសាខ្ញុំ ។

ពេលដែលខ្ញុំបានមកដល់ផ្ទះ ហើយគ្រាដែលទ្វារផ្ទះត្រូវបានរបើកឡើង ក្នុងខណៈជាមួយគ្នានោះ បើមានធំក្លិន «ស្រា» ភាយមកប៉ះនឹងច្រមុះខ្ញុំ ទ្រូងខ្ញុំក៏ចាប់ផ្តើមញ័ររន្ធត់ ខ្ញុំហាក់ដូចជាបានដឹងថា «ច្បាស់ជាមានរឿងរ៉ាវអាស្រូវកើតឡើងទៀតជាមិនខាន»

ហើយ នៅពេលជាមួយគ្នានោះ បេះដូងខ្ញុំក៏ចាប់ផ្តើមលោតយ៉ាងញាប់លោតខុសសង្វាក់ ។ រាល់ៗលើកពេលដែលមានធំក្លិន "ស្រា" នៅក្នុងផ្ទះ ឪពុករបស់ខ្ញុំគាត់តែងតែនិយាយប៉ប៉ាច់ប៉ប៉ោចយ៉ាងច្រើនតែម្នាក់ឯង គាត់និយាយពីរឿងរ៉ាវផ្សេងៗរាប់រយជំពូក និយាយពុំឈប់ ដែលរូបខ្ញុំពិបាកនឹងយល់ពេកក្រៃ ពេលខ្លះជាមួយនឹងសម្រែកដ៏ខ្លាំងៗរបស់គាត់ ខ្ញុំស្តាប់ទៅគួរឲ្យរន្ធត់ភ័យខ្លាច ។

ថ្ងៃមួយជាមួយនឹងដំណើរដ៏ទ្រេតទ្រោត គាត់បានដើរសំដៅទៅកាន់អ្នកម៉ែ ដែលកំពុងតែអង្គុយយ៉ាងស្ងៀមស្ងាត់ក្បែរថាសបាយ ភ្នែកទាំងគូរបស់អ្នកម៉ែកំពុងតែសម្លឹងទៅកាន់រូបគាត់ដោយក្តីគោរព ជាមួយនឹងកំហឹងដែលកើតមកពីសុរា គាត់បានយារដៃទះកំភ្លៀងអ្នកម៉ែយ៉ាងអស់ទំហឹង ដោយគ្មានកំហុសអ្វីបន្តិចទាល់តែសោះ ។ ដោយក្តីឈឺចាប់ អ្នកម៉ែស្រែកទ្រហោយំ គាត់បានស្ទុះមកវាយដំអ្នកម៉ែកាន់តែខ្លាំងថែមទៀត ឃើញដូច្នោះ ខ្ញុំក៏ស្ទុះចូលទៅជួយអ្នកម៉ែ ពេលនោះគាត់ក៏បានគំរាមកំហែងបម្រុងនឹងវាយដំខ្ញុំទៀត ឮដូច្នោះក្រោមក្រសែភ្នែកដ៏គក់ស្លុតភ័យខ្លាច អ្នកម៉ែក៏បានស្ទុះមកស្រវាឱបខ្ញុំជាប់ ឱបផ្អឹបនឹងដើមទ្រូងរបស់គាត់ រួចហើយអ្នកម៉ែក៏បាននាំខ្ញុំរត់ទៅពួននៅឯផ្ទះអ្នកជិតខាងក្បែរនោះបាត់ទៅ ។ រឿងរ៉ាវអាស្រូវបែបនេះ បានកើតឡើងស្ទើរតែរាល់ថ្ងៃ ហើយមានពេលខ្លះទៀតគ្រាដែលគាត់ស្រវឹងជ្រុល គាត់លែងដឹងអ្វីទាំងអស់ ក្រៅពីដេរបញ្ចោរវាយដំធ្វើបាបអ្នកម៉ែ បាយទឹកសម្ល ដែលអ្នកម៉ែបានរៀបគ្របទុកជូនគាត់ពិសាត្រូវបានគាត់លើកទាំងថាសគ្រវែងចោលតាមមាត់បង្អួចទៅក្រៅផ្ទះ ។ ជាច្រើនលើកច្រើនសារ ដែលខ្ញុំត្រូវបានចូលដេកទាំងគ្មានបាយមួយគ្រាប់សោះក្នុងពោះ ខ្ញុំដេកពុំលក់ទេ ទោះជាខ្ញុំខំប្រឹងធ្មេចយ៉ាងណាក៏ដោយ ។ ខ្ញុំបើកភ្នែកសម្លឹងមើលដុំពពកដែលកំពុងតែរសាត់ទាំងផ្ទាំងៗគាត់តាមមាត់បង្អួច ហើយមានពេលខ្លះដោយធុញទ្រាន់នឹងពាក្យរអ៊ូរទាំច្រំដែលៗរបស់គាត់ខ្លាំងពេក ខ្ញុំក៏ទាញភួយមកទទូរតាំងពីក្បាលរហូតដល់ចុងជើង ។ ដល់ពេលពាក់កណ្តាលអធ្រាត្រស្ងាត់ ក្នុងពោះខ្ញុំចាប់ផ្តើមគួរឈឺផ្សារដោយក្តីស្រេកឃ្លាន ហើយពេលដែលខ្ញុំនឹកគិតអាណិតដល់ជីវិតដ៏អភ័ព្វរបស់អ្នកម៉ែ ខ្ញុំពួនយំខ្សឹកខ្សួលអណ្តឺតអណ្តកតែម្នាក់ឯង ព្រលឹមឡើង ខ្នើយខ្ញុំសើមជោកដោយដំណក់ទឹកភ្នែក ។ អ្នកម៉ែ បានស្រឡាញ់ថ្នាក់ថ្នមខ្ញុំ ដើម្បីរូបខ្ញុំ អ្នកម៉ែលះបង់អ្វីៗទាំងអស់ និងបានទ្រាំទ្រការលំបាកពុះពារគ្រប់ឧបសគ្គ ទោះបីជាសព្វថ្ងៃ អ្នកម៉ែកំពុងតែរស់នៅក្នុងស្ថានភាពដ៏វេទកម្មបែបនេះ ក៏ដោយ ។

ខ្ញុំសឹងតែអត់ដង្ហើមឲ្យស្លាប់ ពិសេស គ្រាដែលខ្ញុំបានឃើញអ្នកម៉ែស្រក់ទឹកភ្នែកម្តងៗ ជីវិតអ្នកម៉ែជាជីវិតមួយដែលទ្រុតទ្រោមគ្រាំគ្រា ហើយពីមួយថ្ងៃទៅមួយថ្ងៃអ្នកម៉ែនៅតែខាំមាត់អត់ធ្មត់ជានិច្ច ។ តែផ្ទុយទៅវិញ ថ្ងៃណាដែលឪពុករបស់ខ្ញុំគាត់អត់ស្រវឹង លោកទាំងពីរពុំដែលហាមាត់និយាយស្តីទៅរកគ្នាមួយម៉ាត់ឡើយ ហើយក្នុងសភាពបែបនេះជាការពិតណាស់ ក៏ពុំមានអ្នកណាម្នាក់និយាយមកកាន់ខ្ញុំដែរ ។ ថ្ងៃមួយ ពេលដែលខ្ញុំទើបតែនឹងត្រឡប់មកពីសាលារៀនវិញ ឪពុកខ្ញុំបានប្រើឲ្យខ្ញុំយកសំបុត្រគាត់មួយច្បាប់ទៅប្រគេនលោកគ្រូព្រះចៅអធិការវត្តត្រពាំងខ្ទៅ ដែលនៅចម្ងាយប្រមាណជាងពីរគីឡូម៉ែត្រពីផ្ទះ ។ ពេលដើរមកដល់ដើមផ្លូវប្រកចូលទៅវត្ត ដោយមានចម្ងល់ក្នុងចិត្ត ខ្ញុំក៏បានលួចបើកសំបុត្ររបស់គាត់អាន ។ ជាសំបុត្រដែលគាត់បានសរសេរផ្ទាល់ដៃ មានសេចក្តីយ៉ាងខ្លីថា ព្រះតេជគុណ ទូលព្រះបង្គំកំពុងតែអត្តខាត់ខ្លាំងណាស់ សូមព្រះអង្គមេត្តាជួយស្រោចស្រង់សត្វលោកដែលកំពុងតែលិចលង់ផង ។ ក្រោយពីថ្វាយបង្គំព្រះអង្គបីដងរួចហើយ ខ្ញុំក៏បានប្រគេនសំបុត្ររបស់ឪពុកខ្ញុំ ទៅព្រះអង្គលោកបានបើកសំបុត្រឡើងអានដោយស្ងៀមស្ងាត់ ជាមួយនឹងដង្ហើមធំយ៉ាងវែង លោកក៏បានមានសង្ឃដីកាមកកាន់ខ្ញុំថា អាត្មាក៏កំពុងតែអត់ខ្លាំងណាស់ដែរ រួចហើយព្រះអង្គក៏បានហូតយកក្រដាសប្រាក់មួយរយរៀលមួយសន្លឹកពីថង់យាមប្រកចូលទៅក្នុងស្រោមសំបុត្រដដែល ហើយហុចប្រគល់មកឲ្យខ្ញុំវិញ ។ ខ្ញុំក្រាបថ្វាយបង្គំលាព្រះអង្គ រួចប្រញាប់ស្រូតដំណើរត្រឡប់មកផ្ទះវិញ ។

ពេលមកដល់ ខ្ញុំឃើញគាត់ហាក់ដូចជាកំពុងរង់ចាំមើលផ្លូវខ្ញុំ ខ្ញុំបានជូនសំបុត្រទៅគាត់ភ្លាម រួចខ្ញុំក៏ដើរទៅចាក់ទឹកពីក្អមមួយត្រឡោកមកហូប ខ្ញុំហូបទឹកមិនទាន់បានរួចផុតពីមាត់ផង ខ្ញុំឃើញគាត់ដើរតម្រង់មករកខ្ញុំ ដៃគាត់ម្ខាងមានកាន់ដបស្រាមួយផង ។ ជាមួយនឹងក្រដាសប្រាក់មួយរយរៀលដែលបានមកពីព្រះចៅអធិការវត្តត្រពាំងខ្ទៅ គាត់បានប្រើខ្ញុំទៅទិញស្រាយកមកឲ្យគាត់ពិសា ខ្ញុំគ្រវីក្បាលបដិសេធដោយស្វ័យប្រវត្តិ ពេលនោះខ្ញុំក៏បានដឹងខ្លួនយ៉ាងច្បាស់ថា មុខជានឹងមានរឿងរ៉ាវអ្វីមួយកើតឡើងចំពោះ

ខ្ញុំជាពុំខាន ។ ខ្ញុំបានប្រមែប្រមូលនូវសេចក្ដីក្លាហានសព្វបែបយ៉ាង មុននឹងខ្ញុំបានឆ្លើយតបទៅគាត់វិញថា បើពុកប្រើខ្ញុំឲ្យទៅទិញស្ពីផ្សេង ខ្ញុំមិនប្រកែកទេ តែបើប្រើខ្ញុំឲ្យទៅទិញស្រាយកមកពិសាស្រវឹងធ្វើបាបម៉ែ ខ្ញុំមិនទៅទេ ។ នេះគឺជាលើកដំបូងហើយដែលខ្ញុំមិនខ្លាចប្រឈមមុខនឹងគាត់ក្នុងសភាពបែបនេះ ។

គ្រាន់តែបានឮខ្ញុំឆ្លើយថាដូច្នេះ គាត់ក៏បានស្រែកគំរាមមកខ្ញុំភ្លាមថា បើប្រើមិនទៅប្រយ័ត្នត្រូវដំបង ហើយគាត់បែរជាសួរមកកាន់ខ្ញុំ តើអញជាឪអ្ហែង ឬក៏អ្ហែងឪជាអញ? ខ្ញុំក៏បានតបទៅគាត់វិញថា បើពុកចង់វ៉ៃខ្ញុំរហូតដល់ស្លាប់ក៏ខ្ញុំមិនទៅដែរ ។ ដោយបានដឹងថា ពេលនេះខ្ញុំកំពុងតែរឹងទទឹងនឹងបំណងរបស់គាត់មែនទែនហើយនោះ ជាមួយនឹងអាការៈប្រឡោតខឹងយ៉ាងក្រេវក្រោធ គាត់ស្ទុះភ្លែតទាំងកំរោលទាញបានរំពាត់រនាបឫស្សីមួយបន្ទះក្បែរនោះ ហើយយាដៃយ៉ាងអស់ទំហឹងវាត់ "ផាំង" ពីក្រោយត្រូវចំកណ្ដាលខ្នងខ្ញុំ ខ្ញុំធ្លាក់ត្រឡោកទឹកពីដៃទាំងមិនដឹងខ្លួន ។ ពេលដែលគាត់កំពុងតែវាយវាត់ខ្ញុំយ៉ាងឆ្នាញ់ដៃ អ្នកម៉ែក៏បានចូលមកដល់ល្មម ឃើញសភាពបែបនេះ អ្នកម៉ែទម្លាក់កញ្ច្រែងបន្លែទៅម្ខាង ហើយស្ទុះចូលមកយ៉ាងត្រហេបត្រហប អ្នកម៉ែស្រវេស្រវាំបម្រុងជួយខ្ញុំ ឃើញដូច្នោះ គាត់ក៏បានទាញអូសខ្ញុំយ៉ាងទីណាត់ទីណែងឲ្យឆ្ងាយពីអ្នកម៉ែ ហើយគាត់បានស្រែកគំរាមកំហែងឲ្យអ្នកម៉ែថែមទៀត ។ ខ្ញុំឈរស្ងៀម ខាំមាត់បណ្ដោយឲ្យគាត់វាយវាត់តាមចំណង់ចិត្ត តែខ្ញុំគ្មានស្រក់ទឹកភ្នែកមួយតក់ឡើយ ឃើញដូច្នោះ គាត់រឹងរិតតែខឹងខ្លាំងថែមទៀត ហើយគ្រាដែលអ្នកម៉ែបានព្យាយាមចូលមកជួយខ្ញុំសាជាថ្មី គាត់បានរុញច្រានអ្នកម៉ែយ៉ាងកម្រោលចេញទៅម្ខាង ខ្ញុំបានឃើញអ្នកម៉ែប្រាសប្រាលចុះឡើង រួចអ្នកម៉ែក៏ស្រែកថ្ងូរហោយំ ។ **(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាឋ**

# ដំណឹងស្វែងរកឪពុកមា

*ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្ដាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្ដាយ ងួន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់ រួមមាន ៖ ១) សាប់ សេរីឈុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម) , ២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម) , ៣) សាប់ ធីគន្ធ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម) , ៤) សាប់ សុខារី ភេទស្រី, ៥) សាប់ វ៉ាន់នីន ភេទប្រុស, ៦) សាប់ ភូមិរិន្ទ ភេទស្រី ។*

*សូមបញ្ជាក់ថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស៊ឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោកក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។*

*អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខៈ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។*

***សូមអរគុណ!***

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

*រឿងពិតរបស់ ជា សីហា*

**(តពីលេខមុន)**

ខ្ញុំឃើញមានគ្រោះថ្នាក់របស់ពួកអ្នកតស៊ូ គឺជំងឺគ្រុនចាញ់ ។ ស្ទើរតែទាំងអស់គ្នាកើតជំងឺគ្រុនចាញ់ ។ មេបញ្ជាការឲ្យអ្នកតស៊ូវិលមកជំរំដើមវិញ ។ សារ៉ាន់ និងមិត្តរបស់គេចំនួនពីរបីនាក់ បានរត់មកជ្រកក្នុងជំរំខាវអ៊ីដាង ព្រោះ សារ៉ាន់ សង្កេតឃើញថា ការតស៊ូរបៀបនេះ ពុំមានផលប្រយោជន៍អ្វីដល់ជាតិទេ ផ្ទុយទៅវិញ គឺបម្រើផលប្រយោជន៍ឲ្យភ្នាក់ងារ សេ.អ៊ី.អា អាមេរិកាំងតែប៉ុណ្ណោះ ដែលគេចង់បានតែព័ត៌មានពីប្រទេសកម្ពុជា ។ សព្វថ្ងៃនេះ សារ៉ាន់ មានអាយុច្រើនហើយ ជំងឺឆ្អឹងខ្នងយាយីគាត់ជាញឹកញាប់ ប៉ុន្តែ គាត់នៅតែតស៊ូទ្រាំបម្រើការងារក្នុងអង្គការមនុស្សធម៌ខាងផ្នែកវេជ្ជសាស្ត្រផង និងសិប្បកម្មផង ។ គាត់បង្កើតមជ្ឈមណ្ឌលសម្រាប់តម្បាញសូត្រមួយនៅជិតផ្សារបាត់ដឹង ក្នុងខេត្តកំពង់ស្ពឺ សម្រាប់បង្ហាត់នារីខ្មែរឲ្យចេះមុខវិជ្ជា និងចេះប្រកបរបរត្បាញសូត្រ ។

នៅក្នុងជំរំឃុំឃាំងបូរីរ៉ាំ ថ្ងៃមួយមានសង្ឃរាកាតូលិកមួយអង្គបានសុំច្បាប់អនុញ្ញាតពីតម្រួតឲ្យខ្ញុំចេញទៅមុខជំរំដើម្បីជួយរៀបចំមុងភ្លួយ ដែលមាននៅក្នុងរថយន្តរបស់គាត់ ។ រថយន្តរបស់គាត់ជាប្រភេទរថយន្តគ្រួសារមានទ្វារប្រាំ ។ ទៅដល់រថយន្តគាត់ចាក់សោបើកទ្វារក្រោយចំហឡើង ។ គាត់ទាញខ្ញុំឲ្យឈ្ងោកចូលទៅក្នុងរថយន្តរបស់គាត់ ។ ខ្ញុំនឹកក្នុងចិត្តថា តើគាត់ចង់ឲ្យខ្ញុំធ្វើអ្វីនៅក្នុងរថយន្តនេះ ។ តម្រួតម្នាក់នៅឈរត្រង់មាត់ទ្វារជំរុំតាមមើលខ្ញុំពីក្រោយ ។ ស្រាប់តែគាត់និយាយភាសាបារាំងមកកាន់ខ្ញុំថា "តើឯងហ្នឹងដែលសរសេរសំបុត្រទៅស្ថានទូតបារាំង? ខ្ញុំឆ្លើយជាភាសាបារាំងទៅវិញថា "បាទ ! គឺខ្ញុំនេះហើយ" ។ គាត់និយាយបន្តទៀតថា "ឯងត្រូវចាកចេញពីជំរំនេះជាបន្ទាន់ បើមិនដូច្នេះទេ កាលបើតម្រួតសៀមដឹងថា ឯងជាអ្នកប្តឹងទៅស្ថានទូតនោះ ឯងពិតជាចៀសមិនរួចពីសេចក្តីស្លាប់ឡើយ ។ ដូច្នេះ ឯងត្រូវសួរហើយកត់ឈ្មោះដោយស្ងាត់ៗនរណាដែលចង់ទៅប្រទេសបារាំង ។ ថ្ងៃស្អែកខ្ញុំនឹងមកយកបញ្ជីឈ្មោះទាំងនោះ ។ សង្ឃរាកាតូលិកអង្គនោះ បើករថយន្តចេញទៅ ។ ចំណែកខ្ញុំ ខ្ញុំវិលចូលមកក្នុងជំរំវិញ ។ ថ្ងៃនោះ ខ្ញុំដើរសាកសួរកត់ឈ្មោះមនុស្សដែលខ្ញុំទុកចិត្តបានជាច្រើនសិបនាក់ ។ ស្អែកឡើង ខ្ញុំប្រគល់បញ្ជីឈ្មោះនោះ ជូនទៅលោកឪពុកនោះ នៅពេលគាត់មកដល់ជំរំ ។ លោកទទួលបញ្ជីឈ្មោះនោះដោយលាក់លៀមបំផុត ។

ពួកមន្ត្រីរបស់មន្ទីរវប្បធម៌ខេត្តបូរីរ៉ាំតែងតែមកទាក់ទងក្រុមរបាំពួកយើងឲ្យទៅសម្តែង ។ ពួកយើងប្រកែក ព្រោះតែពួកយើងទទួលការជិះជាន់ពីពួកទាហានសៀមដែលមកចាប់បង្ខំពួកយើងយកចេញទៅពីថ្ងៃមុន ។

ប្រមាណមួយអាទិត្យក្រោយពេលដែលខ្ញុំប្រគល់បញ្ជីឈ្មោះជូនលោកឪពុកនោះមក មានមន្ត្រីស្ថានទូតបារាំងមកហៅឈ្មោះយើងដែលមាននៅក្នុងបញ្ជី ។ ចំនួនឈ្មោះក្នុងបញ្ជីមានជាច្រើនសិបនាក់ ប៉ុន្តែចំនួនអ្នកស្ម័គ្រចិត្តទៅប្រទេសបារាំងពិតប្រាកដមានតែ២៣នាក់តែប៉ុណ្ណោះ អ្នកផ្សេងទៀតប្រែចិត្តលែងទៅវិញ ព្រោះចិត្តចង់វិលទៅស្រុកកំណើតនៅពេលមានឱកាស ។ ខ្ញុំបាននាំកូនធម៌ដែលជាកូនប្រុសបង្កើតរបស់ប្អូនធម៌ខ្ញុំឈ្មោះ រឿង ទៅជាមួយ ។ យើងទាំង២៣នាក់ នាំគ្នាដើរចេញពីជំរំឃុំឃាំង ។ ខ្ញុំនឹកដល់វាសនាទៅអនាគតរបស់ជនរួមជាតិខ្ញុំដែលនៅក្នុងជំរំនោះនៅឡើយ ។ ស្រាប់តែសំឡេងជេរប្រទេចពីខាងក្នុងជំរំមកប៉ះដល់ត្រចៀករបស់ខ្ញុំ ។ ខ្ញុំនឹកមិនដល់សោះថា តើគេជេរប្រមាថពួកខ្ញុំអំពីរឿងអ្វី? ។ ក្នុងចំណោមពាក្យជេរប្រទេចទាំងនោះ មានមួយឃ្លាខ្ញុំស្តាប់បានថា "ពួកអាក្បត់ជាតិ អារត់ចោលជាតិ អាកំសាក" ។ ទើបខ្ញុំយល់ថា មិត្តខ្ញុំទាំងនោះទទួលបានការសន្យាពីខ្ញុំថាទៅតស៊ូជាមួយគ្នា ឥឡូវខ្ញុំមិនគោរពតាមពាក្យសន្យាកាលពីថ្ងៃមុននោះ ។ យើងមកស្នាក់នៅជំរំស្ងួនភ្លូង ក្រុងបាងកកបានប្រមាណមួយអាទិត្យ ។ រៀងរាល់ថ្ងៃ លោកឪពុកមកមើលយើង នៅពេលនោះហើយទើបខ្ញុំបានស្គាល់ព្រះនាមរបស់លោកពីអ្នកភៀសខ្លួនផ្សេងទៀត គឺលោកពុក រ៉ូប៊ែររ៉ីណោ ។ មុន

ពេលខ្ញុំ និងកូនធម៌ចេញដំណើរ លោកឪពុកបានយកខោវែងមួយមកឲ្យខ្ញុំ ព្រោះខ្ញុំមានតែខោខ្លីមួយរហែករយ៉ីខ្វះទៅ ហើយនិងប្រាក់ ៥០ដុល្លារ ។ លោកឪពុកនេះហើយបានខំខ្នះខ្នែងជួយភរិយា និងកូនខ្ញុំទាំង៧នាក់ឲ្យបានទៅប្រទេសបារាំងក្នុងរយៈពេលដ៏ខ្លី ។ នៅឆ្នាំ ២០១៣ លោកឪពុក វ៉ិណោ បានលាចាកលោកនេះទៅដោយរោគជរា ។ ខ្ញុំសូមថ្វាយបង្គំដោយគោរពបំផុត និងដោយដឹងគុណបំផុតចំពោះវិញ្ញាណក្ខន្ធរបស់លោកឪពុកដែលស្ថិតនៅឋានសួគ៌ ។

ប្រទេសបារាំងស្ថិតក្នុងបេះដូងរបស់ខ្ញុំ

យន្តហោះអ៊ែរហ្វ្រង់ បានដឹកយើងចេញពីអាកាសយានដ្ឋានដនមឿន នាក្រុងបាងកកសំដៅទៅកាន់ក្រុងប៉ារីស ។ យើងទៅដល់អាកាសយានដ្ឋានស្ហាលដឺហ្គោល នៅជិតក្រុងប៉ារីស វេលាម៉ោង៥ព្រឹក ក្រោមអាកាសធាតុដ៏ត្រជាក់ដល់ឆ្អឹង ។ ផ្កាព្រិលធ្លាក់រោយរាយពេញទីលានអាកាសយានដ្ឋានបង្កើតជាកម្រាលទឹកកកសក្បុស ។ ខ្ញុំត្រេកត្រអាលនឹងទស្សនីយភាពដ៏ត្រកាលនេះ ។ ខ្ញុំឈរប្រឈមនឹងបង្អួចកញ្ចក់នៃសាលរង់ចាំក្នុងអាកាសយានដ្ឋាន ភ្នែកខ្ញុំសម្លឹងទៅក្រៅមើលផ្កាព្រិលធ្លាក់ដោយឥតឈប់ឈរ ។ វិញ្ញាណរបស់ខ្ញុំអណ្តែតអណ្តូងទៅក្នុងលំហ ភាន់ភាំងស្មារតីមិនដឹងកោះមិនដឹងត្រើយ ។ ពីម្សិលមិញ ខ្ញុំទទួលរងទុក្ខនៅឋាននរក ថ្ងៃនេះខ្ញុំមកដល់ឋានសួគ៌ ។ អ្វីៗនៅជុំវិញខ្លួនខ្ញុំធំៗ ហើយប្លែកៗ ។ ពុំមែនឋានសួគ៌ក្នុងក្តីស្រមៃនោះទេ គឺឋានសួគ៌លោកិយ៍ដែលមនុស្សស្ថាបនា ។ ខ្ញុំនឹកឃើញដល់អ្នកគ្រូបារាំងដែលគាត់បង្រៀនខ្ញុំអំពីសាធារណរដ្ឋបារាំង អំពីអរិយធម៌របស់ជនជាតិបារាំងដែលជាមហាអំណាចមួយនៅក្នុងសកលលោក ។ ឥឡូវនេះ ខ្ញុំពិតជាមកដល់ប្រទេសបារាំងហើយ ។ តើរដ្ឋាភិបាលបារាំងនឹងយកខ្ញុំទៅធ្វើអ្វីយកខ្ញុំទៅណា? ខ្ញុំគិតថា ទៅដល់ទីណាក៏ដោយ យ៉ាងហោចណាស់ក៏គ្រាន់បើជាងនៅក្នុងជំរំឃុំឃាំងប្រទេសថៃដែរ ។ ចិត្តខ្ញុំកំពុងលង់ក្នុងគំនិតរវើរវាយ ទាល់តែគេប្រាប់ឲ្យទៅជួបជុំគ្នានៅកន្លែងផ្សេងមួយទៀត ទើបខ្ញុំភ្ញាក់ដឹងខ្លួនប្រមូលអារម្មណ៍ឲ្យនឹងនមកវិញ ។ ខ្ញុំដើរសំដៅទៅទីកន្លែងដែលគេបង្ហាញដៃខ្ញុំចាប់អូសដៃកូនធម៌របស់ខ្ញុំឲ្យទៅជាមួយ ។ មន្ត្រីការពារបាទក្រហមរួសរាយរាក់ទាក់គួរជាទីកក់ក្តៅក្រៃលែង ។ មន្ត្រីកាកបាទក្រហមបានសួរសំពីអត្តសញ្ញាណរបស់យើងម្នាក់ម្តងៗ ដោយចេញលិខិតឲ្យយើងម្នាក់មួយសន្លឹកសម្រាប់ប្រើប្រាស់ជាផ្លូវការ ។ នៅជ្រុងម្ខាងនៃសាលមានបុរសបួននាក់ស្លៀកពាក់តាមបែបជនជាតិអឺរ៉ុបបញ្ជាក់ថា ជាអ្នកស្រុកអាយ គឺអ្នករស់នៅប្រទេសបារាំងនេះ ។ សម្លៀកបំពាក់បែបនេះ ខ្ញុំមិនដែលឃើញផ្ទាល់ភ្នែកដូចពេលនេះទេខ្ញុំធ្លាប់ដែលឃើញតែក្នុងភាពយន្តបារាំងអំឡុងឆ្នាំ១៩៥០ ។ រូបខ្ញុំត្រូវបានមន្ត្រីកាកបាទក្រហមឲ្យជួយធ្វើការបកប្រែភាសា ។ ការប្រជុំចែកលិខិតបញ្ជាក់ជាផ្លូវការបានចប់សព្វគ្រប់ ។ គេឲ្យយើងនៅរង់ចាំដើម្បីចេញដំណើរពីអាកាសយានដ្ឋាន ។ ខ្ញុំឮសំឡេងហៅថា បង! ខ្ញុំងាកមើលទៅរកម្ចាស់សំឡេង ស្រាប់តែបុរសទាំងបួននោះស្ទុះមកឱបខ្ញុំដោយអំណរ ។ ខ្ញុំភាន់ភាំងរកនឹកមិនឃើញពីអត្តញ្ញាណរបស់បុរសទាំងនោះ ពីព្រោះម្យ៉ាងយើងបែកគ្នា ខានឃើញគ្នាអស់រយៈពេលយូរតាំងពីចុងឆ្នាំ១៩៧២ គឺបន្ទាប់ពីពេលដែលរដ្ឋការសាធារណរដ្ឋផ្លាស់ខ្ញុំឲ្យទៅធ្វើការនៅបាត់ដំបង ដោយមូលហេតុចូលរួមដឹកនាំបាតុកម្មប្រឆាំងរដ្ឋាភិបាលលោក សឺង ង៉ុកថាញ់ ។ ម្យ៉ាងទៀត មកពីការប្រែប្រួលរូបរាង និងសម្លៀកបំពាក់ដែលពួកគេបានមកនៅអឺរ៉ុបអស់រយៈពេលយូរមកហើយ ។ មួយភ្លែតក្រោយមក ទើបខ្ញុំស្គាល់បុរសទាំងបួននាក់នោះយ៉ាងច្បាស់ ព្រោះជាមិត្តជិតស្និទ្ធរបស់ខ្ញុំ ។ មិត្តខ្ញុំគេនាំគ្នាប្តូរសម្លៀកបំពាក់ឲ្យខ្ញុំ ឲ្យមានសណ្ឋានស្រដៀងនឹងពួកគេ ព្រមទាំងឲ្យប្រាក់ដ៏សន្ធឹកចំនួន៣.០០០ហ្វ្រង់ថែមទៀត ។ តើពុំមែនជារឿងអស្ចារ្យទេឬដែលរូបខ្ញុំធ្លាក់ខ្លួនស្មើនឹងសត្វតិរច្ឆានទៅហើយតាំងពីពួកកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមមកគ្រប់គ្រងប្រទេសកម្ពុជា គឺថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មកដល់រយៈពេលជាប់ឃុំឃាំងនៅប្រទេសថៃពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ ដល់ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ ស្រាប់តែស្អែកឡើង ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ គឺត្រឹមតែមួយថ្ងៃក្រោយមក ខ្ញុំក្លាយខ្លួនជាមនុស្សថ្មីម្នាក់ដែលមានរូបរាងជាមនុស្សទាន់សម័យ មានសេរីភាព មានសេចក្តីថ្លៃថ្នូរនៅលើទឹកដីនៃអរិយប្រទេសមួយ ។

មិត្តទាំងបួននាក់ ដែលបានទៅទទួលខ្ញុំនៅអាកាសយានដ្ឋានស្ហាដឺហ្គោល គឺលោក ណែវ សែ, លោក ប៉ែន វ៉ាណូ, លោក កង វ៉ែន និងលោក នូវ សាម៉ូវ ។ លោក នូវ សាម៉ូវ បានលាចាក លោកនេះតាំងពីអំឡុងឆ្នាំ១៩៨០មកម្ល៉េះ ។ សូមវិញ្ញាណក្ខន្ធរបស់លោកបានទៅសោយក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ប្រមាណជាម៉ោង៧កន្លះព្រឹក រថយន្តធំមួយបានដឹកពួកយើងចេញពីអាកាសយានដ្ឋានសំដៅទៅមជ្ឈមណ្ឌលអ៊ែរប្រ៊ៃជាទីស្នាក់នៅសម្រាប់ជនភៀសខ្លួន ។ ទីនោះហាក់ដូចជាកន្លែងរង់ចាំដើម្បីបែងចែកពួកយើងទៅតាមទីកន្លែងផ្សេងៗទៀត នៅតាមបណ្តាខេត្តនានាក្នុងប្រទេសបារាំង ។ នៅទីនោះគេផ្តល់បន្ទប់ស្នាក់នៅស្អាតបាតសមរម្យ និងអាហារបារាំងមួយថ្ងៃ៣ពេលដោយបរិបូរ ។

ក្នុងរយៈពេលមួយខែនៅមជ្ឈមណ្ឌលអ៊ែរប្រ៊ៃ មានសកម្មភាពផ្សេងៗដែលអ្នកទទួលខុសត្រូវរបស់មជ្ឈមណ្ឌល និងអង្គការនានាបានរៀបចំឡើង ដើម្បីជាប្រយោជន៍ដល់អ្នកភៀសខ្លួន មានការត្រួតពិនិត្យសុខភាព ការចែកថ្នាំសម្រាប់បំបាត់សត្វល្អិតនៅក្នុងពោះវៀន ការបញ្ចាំងភាពយន្ត ឬការសម្តែងរបាំរបស់ជនជាតិនីមួយៗតាមស្ម័គ្រចិត្ត ដើម្បីកំដរបរិយាកាសនៃការស្នាក់នៅ និងធ្វើឲ្យមានទំនាក់ទំនងរវាងអ្នកភៀសខ្លួនដូចគ្នាផង និងរវាងអ្នកភៀសខ្លួន និងភ្ញៀវដែលមកសួរសុខទុក្ខផង ។ រយៈពេលមួយខែ អាចជាពេលវេលាមួយសម្រាប់ផ្សាំអ្នកភៀសខ្លួននឹងអាកាសធាតុសែនត្រជាក់នៃប្រទេសបារាំងនៅឆ្នាំនោះ ។ ក្រៅពីនោះ ក៏មានអ្នកចិត្តល្អនាំយកខោអាវជំនំមកផ្តល់ឲ្យអ្នកភៀសខ្លួនដែរ ។ នៅទីនោះហើយដែលខ្ញុំបានស្គាល់រាប់អានស្ត្រីចំណាស់ម្នាក់ឈ្មោះ ម៉ូនីកបែលឡុង ។ គាត់បានជួយខ្ញុំជាច្រើននៅក្នុងជីវភាពរបស់ខ្ញុំ និងកូនចិញ្ចឹម ។ បើគ្មានរូបគាត់នៅពេលនោះ ខ្ញុំពិតជាជួបការលំបាកច្រើន ។ ដោយសារគាត់ នៅពេលនោះ ខ្ញុំមិនជួបការលំបាកច្រើនទេ ។ ដោយសារគាត់ខ្ញុំបានផ្សាំជីវិតខ្ញុំនៅក្នុងសង្គមបារាំង បានស្គាល់មជ្ឈដ្ឋាននានារបស់បារាំង បានពឹងពាក់ និងបានចូលរួមកិច្ចការមនុស្សធម៌នានារបស់សហគមន៍សម្រាប់ជនភៀសខ្លួនខ្មែរ ។ ដោយមានជំនួយពីគាត់ ខ្ញុំដើរប្រមូលខោអាវជំនំ និងបរិក្ខារផ្សេងៗសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃយកមកចែកជូនអ្នកភៀសខ្លួនខ្មែរដែលខ្វះខាត ។ ការងារទាំងនេះ ខ្ញុំបានធ្វើដោយទៀងទាត់ជាមួយគាត់អស់រយៈជាច្រើនឆ្នាំ ។ គាត់ និងខ្ញុំតែងនិយាយគ្នាថា «យើងត្រូវធ្វើខ្លួនឲ្យមានប្រយោជន៍» យូរៗទៅពាក្យនេះជាពាក្យគន្លឹះនៃមិត្តភាពរបស់យើង ។ នៅពេលគាត់មានសុខភាពទ្រុឌទ្រោម គាត់ចាកចេញពីក្រុងប៉ារីសទៅនៅទីក្រុងទូកក៍ជិតក្រុងដូវីល ។ នៅទីនោះហើយដែលគាត់បានលាចាកលោកនេះដោយស្ងប់ស្ងៀមតែម្នាក់ឯង ។

នៅអ៊ែរប្រ៊ៃ បានមួយខែទើបគេដឹកជនភៀសខ្លួនឲ្យទៅនៅមជ្ឈមណ្ឌលផ្សេងៗតាមបណ្តាខេត្តនានាក្នុងប្រទេសបារាំង ។ រូបខ្ញុំ និងកូនចិញ្ចឹមបានទៅនៅមជ្ឈមណ្ឌលមួយឈ្មោះថា ឡាញី នៅមិនឆ្ងាយប៉ុន្មានពីទីក្រុងប៉ារីស ។ នៅទីនោះ មជ្ឈមណ្ឌលបានផ្តល់អំណោយជាប្រាក់កាសបន្តិចបន្តួចសម្រាប់បរិភោគ និងធ្វើដំណើរ ។ យើងត្រូវការធ្វើដំណើរដើម្បីធ្វើក្រដាសស្នាម ដើម្បីរកជំនួយ ដើម្បីទៅលេងផ្ទះមិត្តភក្តិ និងបងប្អូន ។ អស់រយៈពេល២ខែនៅឡាញី ខ្ញុំចាប់ផ្តើមមានការអផ្សុក និងមានជំងឺ នឹកស្រុក នឹកប្រពន្ធកូន នឹកម្តាយ នឹកបងប្អូន នឹកមិត្តសម្លាញ់ ។ មានមិត្តរបស់ខ្ញុំម្នាក់ឈ្មោះ ណេវសែ បានជួយរកការងារឲ្យខ្ញុំធ្វើនៅមន្ទីរពេទ្យបាលមួយជាមួយគាត់នៅឯប៊ូហ្សេម៉ុង ។ ដោយមេត្តាធម៌របស់លោកប្រធានមន្ទីរពេទ្យបាលផង និងដោយលោកយោគយល់ដល់មិត្តខ្ញុំដែលជាបុគ្គលិកដ៏ល្អរបស់គាត់ ទើបគាត់អនុញ្ញាតឲ្យខ្ញុំធ្វើការជាអ្នកយាមប្រចាំការនៅពេលយប់ ។ គាត់ផ្តល់បន្ទប់ស្នាក់នៅឲ្យខ្ញុំ និងកូនចិញ្ចឹមក្នុងមន្ទីរពេទ្យបាលនៅជិតមិត្ត ណេវសែ និងគ្រួសារដែរ ។ ខ្ញុំទទួលបានប្រាក់ខែក្រាស់ក្រែលល្មមអាចផ្គត់ផ្គង់ជីវភាពខ្ញុំ និងកូនបានសមរម្យ ។ ខ្ញុំចងចាំមិនភ្លេចនូវគុណបុណ្យរបស់លោកវេជ្ជបណ្ឌិត ហ្សូស្សូម ប្រធានមន្ទីរពេទ្យបាលប៊ូហ្សេម៉ុង និងមិត្ត ណេវសែ ព្រមទាំងភរិយាឈ្មោះ យ៉ា ។ មិត្តណេវសែ និងភរិយាបានទំនុកបម្រុងជីវភាពរបស់ខ្ញុំដោយស្មោះអស់ពីពោះពុងដូចបងប្អូនបង្កើត ។

ចាប់ពីថ្ងៃដែលខ្ញុំបានទៅដល់ប្រទេសបារាំងភ្លាម កាតព្វកិច្ចជាចម្បងដែលខ្ញុំបានតាំងចិត្តទុកមុនពេលចេញដំណើរមកប្រទេសបារាំងថា ខ្ញុំនឹងស្រែកប្រាប់សកលលោកអំពីអំពើព្រៃផ្សៃយង់ឃ្នងរបស់របបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមដែលកំពុងឆ្លូតវក់នឹងការសម្លាប់ជាតិឯង ។ ក្រោមការជួយជ្រោមជ្រែងពីមិត្តភក្តិ និងសមាគមបារាំងខ្លះ កាតព្វកិច្ចរបស់ខ្ញុំកំពុងតែត្រូវបានបំពេញដោយខ្លាំងក្លា នៅក្នុងប្រទេសបារាំង ហើយមានគម្រោងថា នឹងទៅស្រែកប្រាប់ប្រជាជន និងរដ្ឋាភិបាលនៅអឺរ៉ុបទាំងមូលថែមទៀត ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានអស់លោកបញ្ញវន្តខ្មែរនៅប្រទេសបារាំងដែលមាននិន្នាការនយោបាយដូចគ្នា បានហៅខ្ញុំឲ្យទៅប្រជុំនៅផ្ទះរបស់ខ្មែរម្នាក់នៅក្រុងប៉ារីស ដើម្បីពិភាក្សារកជំហររួមគ្នាចំពោះព្រឹត្តិការណ៍ដែលកំពុងកើតមាននៅឯស្រុក

យើងស្រាប់តែភ្នាក់ងារសារព័ត៌មានរ៉យទ័រម្នាក់ បានទូរស័ព្ទមកម្ចាស់ផ្ទះដើម្បីជូនព័ត៌មាន និងសួរអំពីមតិរបស់ខ្មែរនៅស្រុកបារាំងអំពីជ័យជម្នះ ដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមរំដោះបានភ្នំពេញនៅថ្ងៃនេះហើយ ។ យើងមានចិត្តកន្ទះរាគ្រប់គ្នា ។ ចិត្តមួយ គឺយើងប្រឆាំងនឹងខ្មែរក្រហម ចិត្តមួយទៀត យើងបារម្ភខ្លាចវៀតណាមយកប្រទេសយើងធ្វើជាខេត្តរបស់គេដូចក្នុងសតវត្សរ៍ទី១៩ ។ យើងពិភាក្សាគ្នារកជំហរមួយដោយប្រុងប្រយ័ត្ន ព្រោះយើងយល់ថា ខ្មែរយើងកំពុងរងគ្រោះយ៉ាងធ្ងន់ ហើយគ្មានជម្រើសណាមួយដែលយើងត្រូវប្រកាន់យកទេ ព្រោះ «ចុះទឹកក្រពើឡើងលើខ្លា» ។ ជាបណ្ដោះអាសន្នយើងត្រូវមានជំហរមួយ គឺប្រឆាំងនឹងរបបខ្មែរក្រហមផង និងប្រឆាំងវត្តមានរបស់កងទ័ពវៀតណាមនៅលើទឹកដីកម្ពុជាផង ។ ជំហរមិនដាច់ស្រេចរបស់យើង ព្រោះតែយើងជាអ្នករងគ្រោះ ជាអ្នកបាក់ស្បាត និងជាទស្សនិកជន ។ ទោះបី យើងមិនបានស្ថិតនៅក្នុងប្រទេស ហើយមិនបានទទួលរងនូវទុក្ខវេទនាដោយផ្ទាល់ក្ដី ក៏យើងទទួលនូវការឈឺចាប់តាមផ្លូវចិត្តដ៏ខ្លាំងក្លាណាស់ដែរ ។ ទឹកភ្នែកនៃការឈឺចាប់ហូរធ្លាក់ពីភ្នែកយើងស្ទើរតែគ្រប់ពេលដែលយើងនឹកដល់ ។ ទឹកភ្នែកនោះ ហូររហូតមកដល់ថ្ងៃនេះ ព្រោះតែរន្ធទឹកភ្នែករីកធំពេក ដែលសន្ទុះមិនអាចបិទជាប់តាំងពីពេលនោះមក ។ នៅពេលនោះ ខ្ញុំរមែងនឹកគិតថាក្នុងមួយថ្ងៃៗ តើខ្មែរស្លាប់ប៉ុន្មាននាក់ទៀត ព្រោះតែសង្គ្រាម? តើប្រពន្ធ កូន ម្ដាយ និងបងប្អូនខ្ញុំស្លាប់ឬរស់? បើរស់ រស់នៅឯណា? ។ សំណួរទាំងប៉ុន្មានខាងលើនេះ ស្ថិតជាប់ក្នុងខួរក្បាលរបស់ខ្ញុំ ។ សម្រាប់រឿងនេះ យើងត្រូវធ្វើអ្វីមួយជាជាងដេកកើតទុក្ខឥតប្រយោជន៍ ។ ខ្ញុំបានចូលរួមធ្វើសហគមន៍មួយ រួចហើយរួមចំណែកបង្កើតមជ្ឈមណ្ឌលសម្រាប់ជួបប្រជុំរវាងខ្មែរ និងខ្មែរ រវាងខ្មែរ និងបារាំង ដើម្បីរកគំនិតសម្រាប់ធ្វើវិភាគទានក្នុងការដោះស្រាយបញ្ហាខ្មែរ ។ យើងបានចូលគាល់សម្ដេច នរោត្តម សីហនុ (ព្រះបរមរតនកោដ្ឋ) នៅក្រុងប៉ារីស ដើម្បីសូមយាងព្រះអង្គធ្វើជាមគ្គុទ្ទេសក៍នៃចលនារំដោះជាតិមួយ ។ យើងកៀរគរខ្មែរភៀសខ្លួនបានជាច្រើនពាន់នាក់ មកជួបជុំនៅ «ផ្ទះបាល់តា» ដើម្បីសម្ដែងសាមីភក្ដិថ្វាយចំពោះព្រះអង្គ ប៉ុន្តែនៅទីបំផុតព្រះអង្គសព្វព្រះទ័យយាងទៅចោលយើង ហើយស្ដេចយាងទៅក្រុងឆាងស៊ូអ៊ិន ប្រទេសកូរ៉េខាងជើងដើម្បីគង់នៅទីនោះ ។ យើងពុំយល់ពីព្រះតម្រិះរបស់ព្រះអង្គឡើយ ប៉ុន្តែ យើងទទួលបានដំណឹងជាពាក្យលេចឮក្រៅផ្លូវការថា ព្រះអង្គមិនទុកព្រះទ័យលើពួកយើងទេ ព្រោះព្រះអង្គចាត់ពួកយើងថា ជាអ្នកសាធារណរដ្ឋទៅវិញ ។ ពួកយើងខកចិត្តជាខ្លាំងចំពោះព្រះឥរិយាបថនេះ ។ ដោយនឹកដល់មហាករុណាធិគុណរបស់ព្រះអង្គ យើងនៅតែគម្កល់ព្រះអង្គទុកជាទីសក្ការៈរបស់យើងជានិច្ច ។

អត់មានព្រះអង្គជាមគ្គុទ្ទេសក៍ យើងខិតខំធ្វើអ្វីៗតាមមធ្យោបាយដែលយើងមាន យើងបណ្ដុះគំនិតជាតិនិយមឲ្យដល់កូនខ្មែរគ្រប់រូប យើងធ្វើសិក្ខាសាលាប្រជុំគ្នាធ្វើបុណ្យតាមគន្លងព្រះពុទ្ធសាសនា យើងបង្កើតសារព័ត៌មានប្រចាំសប្ដាហ៍មួយជាភាសាខ្មែរ និងបារាំង ។

ដោយមានសហការល្អពីបញ្ញវន្តជំនាន់ចាស់ និងថ្មី សារព័ត៌មានរបស់យើងមានដំណើរជាប្រក្រតីក្នុងការជូននូវព័ត៌មានដល់អ្នកអាននៅក្រៅប្រទេសកម្ពុជាអំពីបញ្ហាដែលទាក់ទងនឹងប្រទេសកម្ពុជា និងសហគមន៍ខ្មែរនៅក្រៅប្រទេស ។ ក្រៅពីព័ត៌មាន ក៏មានអត្ថបទជាចំណេះដឹងទូទៅ ជាការបញ្ចេញ មតិ ឬវិចារណកថា ។ ខ្ញុំត្រូវស្រាវជ្រាវរកព័ត៌មានពីសារព័ត៌មាន ឬទស្សនាវដ្ដីបរទេសមកបកប្រែជាភាសាខ្មែរ និងបារាំង ។ ខ្ញុំវាយអង្គុលីលេខហើយកាត់អត្ថបទបិទលើទំព័ររហូតដល់ពេញគ្រប់ទំព័រ ។ ខ្ញុំ ធ្វើទាំងយប់ ទាំងថ្ងៃ ស្ទើរតែគ្មានពេលទុកសម្រាកតម្រូវការផ្ទាល់ខ្លួនទៀតផង ។ ប្រតិបត្តិការនេះអស់ ទាំងកម្លាំងកាយ និងថវិកាផ្ទាល់ខ្លួនថែមទៀត ។ យើងទទួលអត្ថបទពីគ្រប់និន្នាការនយោបាយដើម្បីសម្ដែងមតិលើកលែងតែអត្ថបទដែលមានខ្លឹមសារជាពាក្យឃោសនា ។ សារព័ត៌មានរបស់យើងជាវេទិកាចំហសម្រាប់ខ្មែរ ឬបារាំងដែលចង់សម្ដែងមតិអំពីបញ្ហារបស់ខ្មែរ ។ ការងាររបស់ខ្ញុំមិនត្រឹមតែប៉ុណ្ណោះទេ ថែមទាំងទទួលកិច្ចការជាប្រធានមជ្ឈមណ្ឌលខ្មែរនៅប្រទេសបារាំងទៀតផង ព្រោះតែអតីតប្រធានមជ្ឈមណ្ឌលត្រូវទៅធ្វើការនៅធនាគារអភិវឌ្ឍន៍អាស៊ីនៅហ្វីលីពីន ទើបសមាជិកទាំងខ្មែរ និងបារាំងបានជ្រើសតាំងរូបខ្ញុំឲ្យជំនួស ។ ខ្ញុំពុំអាចប្រកែកបានទេ ព្រោះតែចង់រក្សាជំហរអព្យាក្រឹតរបស់មជ្ឈមណ្ឌលយើងឲ្យបានគង់វង្ស ។

***(នៅមានត)***

**ឋា សីហា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬥ Preah Sihanouk Blvd ⬥ Phnom Penh ⬥ Cambodia ⬥ Tel: (855) 23 211 875 ⬥ Fax: (855) 23 210 358 ⬥ dccam@online.com.kh ⬥ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬥ Number 186, 2015 ⬥ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.